# ការវាយតម្លៃអំពើពុករលួយ
# ក្នុងវិស័យឯកជននៅកម្ពុជា









**ស្អាតស្អំ**

រួមគ្នាប្រឆាំងអំពើពុករលួយ

# មាតិកា


បញ្ជីតារាង ប្រអប់ និងរូបភាព iii

អារម្ភកថា v

សេចក្តីសង្ខេប vii

ហេតុអ្វីបានជាមានការសិក្សានេះ? ១

**១. ប្រសិទ្ធភាពសេវាសាធារណៈ និងចំណាយក្រៅផ្លូវការៈ ទិដ្ឋភាពទូទៅ ៣**

១.១. ទិដ្ឋភាពរួមនៃចំណាយក្រៅផ្លូវការ ៣

១.២. សេវាឃុំ/សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ៧

១.៣. ទស្សនៈរបស់អ្នកប្រើប្រាស់ចំពោះប្រសិទ្ធភាពសេវា ១០

១.៤. សេវាសាធារណៈមូលដ្ឋាន និងចំណាត់ថ្នាក់លើភាពស្មោះត្រង់របស់មន្ត្រី ១៤

**២. ការយល់ដឹងរបស់ប្រជាជន និងមូលហេតុនៃកម្រៃក្រៅផ្លូវការ ១៧**

២.១. ការយល់ដឹងរបស់អ្នកប្រើប្រាស់ចំពោះកម្រៃក្រៅផ្លូវការ ១៧

២.២. មូលហេតុនៃការកម្រៃក្រៅផ្លូវការ ២០

**៣. វិសាលភាពនៃកម្រៃក្រៅផ្លូវការ និងផលប៉ះពាល់ ២៧**

៣.១. វិសាលភាពនៃកម្រៃក្រៅផ្លូវការ ២៧

៣.២. កម្រៃក្រៅផ្លូវការជាចំណូលបន្ថែមលើប្រាក់បៀវត្សរ៍ ៣៥

៣.៣. កម្រៃក្រៅផ្លូវការ និងថវិការឃុំ/សង្កាត់ ៣៨

៣.៤. កម្រៃក្រៅផ្លូវការ និងជីវភាពប្រចាំថៃរបស់ប្រជាជន ៣៩

**៤. វិធានបន្ទាប់ឆ្ពោះទៅសេវាសាធារណៈថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាព៖ ទស្សនៈរបស់អ្នកដែលពាក់ពន្ធ័ ៤៣**

៤.១. សេវាឃុំ/សង្កាត់ ៤៣

៤.២. សេវាកម្មសាលាបឋមសិក្សា ៤៩

៤.៣. សេវាមណ្ឌលសុខភាព ៥២

**អនុសាសន៍គោលនយោបាយ និងសេចក្តីសន្និដ្ឋាន ៥៥**

**ឯកសារយោង ៥៩**

**សេចក្តីបន្ថែម ១៖ វិធីសាស្ត្រក្នុងការសិក្សា A១**

**សេចក្តីបន្ថែម ២៖ ការប៉ាន់ប្រមាណពីចំនួននៃកម្រៃក្រៅផ្លូវការសរុបប្រចាំឆ្នាំ A៩**

**សេចក្តីបន្ថែម ៣៖ កម្រងសំណួរស្ទង់មតិ A១៥**

# បញ្ជីតារាង ប្រអប់ និងរូបភាព

## បញ្ជីតារាង


តារាង ១.១: ការវាយតម្លៃប្រសិទ្ធភាពនៃសេវាសាធារណៈថ្នាក់មូលដ្ឋាន

តារាង ១.២: ការយល់ដឹងអំពីដំណើរការនៃការតវ៉ា

តារាង ១.៣: តើអ្នកយល់ថាសេវាសាធារណៈមានភាពស្មោះត្រង់ប៉ុណ្ណា?

តារាង ២.១: ការយល់ដឹងនៃកម្រៃក្រៅផ្លូវការមុនការប្រើប្រាស់សេវា

តារាង ២.២: តើអ្នកដឹងទេថាតើកម្រៃដែលអ្នកបង់ជាកម្រៃផ្លូវការ ឬក្រៅផ្លូវការ?

តារាង ២.៣: តើអ្នកផ្តល់សេវាយកកម្រៃក្រៅផ្លូវការទៅប្រើដើម្បីអ្វី?

តារាង ៣.១: កម្រៃផ្លូវការ និងការបង់ពិតប្រាកដឱ្យទៅសេវាឃុំ/សង្កាត់នីមួយៗ

តារាង ៣.២: ការប៉ាន់ប្រមាណនូវកម្រៃក្រៅផ្លូវការប្រចាំឆ្នាំក្នុងទីក្រុងភ្នំពេញ

តារាង ៣.៣: តម្លៃផ្លូវការនៃសេវាមណ្ឌលសុខភាពមួយចំនួន

តារាង ៣.៤: ការប៉ាន់ប្រមាណថវិកាប្រចាំឆ្នាំរបស់ឃុំ/សង្កាត់នីមួយៗនៅឆ្នាំ ២០០៦

តារាង ៤.១: កម្រៃផ្លូវការ និងចំនួននៃសេវាឃុំ/សង្កាត់នីមួយៗ


## បញ្ជីប្រអប់


ប្រអប់ ១.១: "អំពើពុករលួយ" ឬក៏ "កម្រៃក្រៅផ្លូវការ"?

ប្រអប់ ២.១: មណ្ឌលសុខភាពនៅក្នុងខេត្តកំពង់ធំ

ប្រអប់ ៤.១: តើប្រាក់បៀវត្សរ៍ចំនួនប៉ុន្មានទើបគ្រប់គ្រាន់សម្រាប់គ្រូបង្រៀនកម្រិតបឋមសិក្សា?


## បញ្ជីរូបភាព


រូបភាព ១.១: តើសាលាឃុំ/សង្កាត់ឱ្យដំណឹងដល់អ្នកជាមុនដែរឬទេអំពីរយៈពេលក្នុងការទទួលយកសេវា?

រូបភាព ១.២: ការយល់ស្របរបស់ប្រជាជនក្នុងការបង់កម្រៃបន្ថែមដើម្បីទទួលបានសេវាលឿន

រូបភាព ១.៣: កម្រិតនៃភាពលំបាកក្នុងការសុំទទួលយកសេវា

រូបភាព ១.៤: ការបង់កម្រៃក្រៅផ្លូវការទៅកាន់សាលាឃុំ/សង្កាត់តាមរយៈអ្នករត់ការ

រូបភាព ២.១: ការយល់ដឹងអំពីលក្ខណៈនៃការបង់កម្រៃនៅថ្នាក់បឋមសិក្សា

រូបភាព ៣.១: ការបង់ក្រៅផ្លូវការប្រចាំឆ្នាំនៃឃុំ/សង្កាត់នីមួយៗ

រូបភាព ៣.២: តើអ្នកត្រូវបង់ថ្លៃសាលាសម្រាប់ឱ្យកូនរបស់អ្នកបានចូលរៀនថ្នាក់បឋមសិក្សាដែរឬទេ?

រូបភាព ៣.៣: ការប៉ាន់ប្រមាណនូវចំណូលប្រចាំខែរបស់មន្ត្រីឃុំ/សង្កាត់
រូបភាព ៣.៤: ការប៉ាន់ប្រមាណប្រភពចំណូលរបស់គ្រូបង្រៀនថ្នាក់បឋមសិក្សា
រូបភាព ៣.៥: ភាគរយនៃគ្រូថ្នាក់បឋមសិក្សាដែលបង្រៀនថ្នាក់ក្រៅម៉ោងដើម្បីបន្ថែមលើប្រាក់បៀវត្សរ៍របស់ពួកគាត់
រូបភាព ៣.៦: ប្រភាគនៃកម្រៃក្រៅផ្លូវការនៅក្នុងការចំណាយរបស់ប្រជាជន
រូបភាព ៣.៧: តើវាមានលក្ខណៈធ្ងន់ធ្ងរបែបណាចំពោះកម្រៃ ដែលត្រូវបង់ឱ្យសេវាទាំងបីបើធៀបនឹងប្រាក់ចំណូលរបស់ប្រជាជន
រូបភាព ៤.១: ការយល់ស្របរបស់ប្រជាជនក្នុងការបង់កម្រៃក្រៅផ្លូវការដែលក្លាយជាផ្លូវការ
រូបភាព ៤.២: ភាគរយនៃប្រជាជនដែលយល់ស្របក្នុងការជួយដល់ការអភិវឌ្ឍមូលដ្ឋាន
រូបភាព ៤.៣: ការបង់ដែលប្រជាជនអាចធ្វើបានទៅឱ្យការអភិវឌ្ឍមូលដ្ឋាន

# អារម្ភកថា

របាយការណ៍ស្តីពី *"សេវាសាធារណៈថ្នាក់មូលដ្ឋាន : ប្រសិទ្ធភាពសេវា និងកម្រៃក្រៅផ្លូវការ"* គឺជាជំហានទីពីរ របស់ **វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា** (វ.ស.ក.) ក្នុងការសិក្សាអំពីបញ្ហាអភិបាលកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការសិក្សានេះ ត្រូវបានធ្វើឡើងបន្ទាប់ពីរបាយការណ៍ដំបូងមួយរបស់ វ.ស.ក ស្តីពី *"ការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា"* ដែលបានបញ្ចប់ទៅនៅខែ កក្កដា ឆ្នាំ ២០០៦។ គម្រោងសិក្សាទាំងពីរនេះ គឺជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវ *"វិមជ្ឈការ និងអភិបាលកិច្ច"* របស់ វ.ស.ក។

ការសិក្សាស្រាវជ្រាវរបស់ វ.ស.ក. គឺជាផ្នែកមួយយ៉ាងសំខាន់នៃតួនាទីជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យមួយ ដែលផ្តោតទៅលើបញ្ហាចំបងនានាដែលកម្ពុជាកំពុងជួបប្រទះ។ វ.ស.ក. មានបេសកម្មផ្សព្វផ្សាយព័ត៌មានដែលអាចជឿទុកចិត្តបានដល់អ្នកពាក់ព័ន្ធទាំងឡាយ និងបង្កើននូវការយល់ដឹងអំពីគោលនយោបាយអភិវឌ្ឍ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយនិរន្តភាព និងអភិបាលកិច្ចល្អ។

វ.ស.ក. សូមថ្លែងអំណរគុណជ្រាលជ្រៅចំពោះ ម្ចាស់ជំនួយរួមមាន អង្គការ DANIDA និង អង្គការ PACT-Cambodia ដែលបានផ្តល់ការឧបត្ថម្ភគាំទ្រយ៉ាងកក់ក្តៅដល់គម្រោងសិក្សាស្រាវជ្រាវនេះ សំដៅបង្កើតបាននូវព័ត៌មានអិតចាំបាច់ដល់ប្រព័ន្ធនៃការផ្តល់សេវាសាធារណៈថ្នាក់មូលដ្ឋាននៅក្នុងប្រទេសកម្ពុជា និងពីបញ្ហានានាដែលកើតមាននៅតាមមូលដ្ឋាន រួមទាំងបញ្ហាដែលបណ្តាលមកពីការបង់កម្រៃក្រៅផ្លូវការផងដែរ។

វ.ស.ក. ក៏សូមអរគុណផងដែរ ដល់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ គ្រូបង្រៀនបឋមសិក្សា បុគ្គលិកមណ្ឌលសុខភាព និងប្រជាជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានផ្តល់ការសហការព្រមទាំងគំនិត និងបទពិសោធន៍ល្អៗសម្រាប់ការសិក្សានេះ។

ការចូលរួមចំណែកពីសំណាក់អ្នកតាក់តែងគោលនយោបាយរបស់រដ្ឋាភិបាល និងអ្នកជំនាញជាតិ និងអន្តរជាតិផ្សេងៗ ក៏បានចូលរួមជាគំនិតយោបល់ល្អៗសម្រាប់ការសិក្សាស្រាវជ្រាវនេះផងដែរ។ វ.ស.ក សូមថ្លែងអំណរគុណជាពិសេស ចំពោះ **ឯកឧត្តម ជា ចេដ្ឋ** ប្រធានគណៈកម្មាធិការ ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សម្រាប់ ការរៀបចំឱ្យមានឡើងនូវកិច្ចប្រជុំដ៏មានសារប្រយោជន៍ជាមួយនឹងសមាជិកព្រឹទ្ធសភា និងតំណាងមកពីក្រសួងពាក់ព័ន្ធនានាដើម្បី ពិភាក្សាអំពីលទ្ធផលនៃការសិក្សាក្នុងជំហ៊ានដំបូង។

ជាទីបញ្ចប់ វ.ស.ក. សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះបុគ្គលិកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាទាំងអស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងគាំទ្រទាំងកំលាំងកាយចិត្តដើម្បីសម្រេចបាននូវរបាយការណ៍នេះប្រកបដោយជោគជ័យ។

**សុក ហាច**

នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

# សេចក្តីសង្ខេប

សេវាសាធារណៈមានសារៈសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាលក្នុងការអនុវត្តនូវយុទ្ធសាស្រ្តរបស់ខ្លួន និងផ្តល់នូវសេវាចាំបាច់ដល់ប្រជាពលរដ្ឋ។ ដើម្បីបំពេញនូវតម្រូវការដល់សហគមន៍មូលដ្ឋានអោយបានល្អ យន្តការនៃសេវាសាធារណៈមូលដ្ឋានចាំបាច់ត្រូវពង្រឹង ដើម្បីបង្កើននូវអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងសុខុមាលភាពសេដ្ឋកិច្ច និងសង្គមដល់ប្រជាជន។

ក្នុងបរិបទនៃការបង្កើនអភិបាលកិច្ចល្អ អំពើពុករលួយ និងសំណូកដែលមានលក្ខណៈជា ប្រព័ន្ធក្នុងសេវាសាធារណៈ ត្រូវបានចាត់ទុកជា ឧបសគ្គចំបងចំពោះដំណើរការអភិវឌ្ឍន៍របស់កម្ពុជា។ រដ្ឋាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិល តែងបានខិតខំរិះរកនូវយុទ្ធសាស្រ្តល្អៗដើម្បីកែច្នៃស្ថានការណ៍បច្ចុប្បន្នឱ្យអោយប្រសើរឡើង។ ជាលទ្ធផល កំណែទម្រង់មួយចំនួនរបស់រាជរដ្ឋាភិបាលបាន ទទួលជោគជ័យគួរឱ្យកត់សំគាល់ជាពិសេស កំណែទម្រង់ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើ ឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ក្រោមការ ឧបត្ថម្ភពីអង្គការ DANIDA និង PACT Cambodia ក្នុងគោលបំណងរកឱ្យឃើញពីផលប៉ះពាល់ផ្ទាល់នៃការផ្តល់សេវាសាធារណៈថ្នាក់ឃុំ/សង្កាត់ទៅលើ ជីវភាពប្រជាជន និងតថភាពនៃការបង់កម្រៃក្រៅ ផ្លូវការនាពេលបច្ចុប្បន្ន ដើម្បីរិះរកវិធីសាស្រ្តល្អៗ សម្រាប់កំណែទម្រង់ស្ថាប័ន។

ការសិក្សានេះ ផ្តោតទៅលើសេវាសាធារណៈសំខាន់ៗបីនៅថ្នាក់ឃុំ/សង្កាត់រួមមានៈ សេវាសាលាឃុំ/សង្កាត់ សេវាអប់រំថ្នាក់បឋមសិក្សា និងសេវាមណ្ឌលសុខភាព ។ ជាទូទៅ សេវាទាំងបី នេះមានទំនាក់ទំនង និងប៉ះពាល់ដល់ជីវភាពប្រចាំ ថ្ងៃរបស់ប្រជាជនខ្លាំងជាងគេ។

របាយការណ៍នេះ នឹងបង្ហាញ ពីលទ្ធផលរួមនៃការស្រាវជ្រាវ ព្រមទាំងឆ្លុះបញ្ចាំង ពីលក្ខណៈមូលហេតុ និងផលប៉ះពាល់នៃកម្រៃក្រៅផ្លូវការលើជីវភាពរបស់ប្រជាជននៅក្នុងឃុំបីប្រភេទ ផ្សេងគ្នាៈ ឃុំនៃទីរួមខេត្ត/ក្រុង ឃុំនៃ ទីរួមស្រុក និងឃុំតាមទីជនបទ។ លើសពីនេះនឹងមានការលើកឡើង ផងដែរពីអនុសាន៍ជាក់ស្តែង មួយចំនួនសំដៅទប់ស្កាត់ការបង់កម្រៃក្រៅផ្លូវការនៅក្នុងសេវាទាំងបី។

## ការយល់ដឹងអំពីកម្រៃក្រៅផ្លូវការ

ការយល់ដឹងរបស់ប្រជាជន អំពីតម្លៃ សេវា មានកម្រិតខុសប្លែកគ្នា ពីសេវាមួយទៅមួយ ដោយហេតុថារបៀបនៃការបង់ថ្លៃសេវានៅក្នុង វិស័យទាំងបី ត្រូវកំណត់ឡើងតាមវិធីសាស្រ្តដោយឡែកៗពីគ្នា។

ទោះបីជាការសិក្សានៅថ្នាក់បឋមសិក្សា ជាគោលការណ៍ពុំតម្រូវឱ្យមានការបង់ប្រាក់ក្តី ៤១% នៃអ្នកផ្តល់ចម្លើយ នៅមានការយល់ច្រលំថាតើ កម្រៃដែលពួកគាត់បានបង់ទៅឱ្យសាលានោះ ជា កម្រៃផ្លូវការ ឬក្រៅផ្លូវការ។

សម្រាប់សេវាពីរទៀត តម្លៃផ្លូវការនៃ សេវាឃុំ/សង្កាត់ ត្រូវបានកំណត់តែចំពោះសេវាមួយចំនួនប៉ុណ្ណោះ ខុសពីសេវាតាមមណ្ឌលសុខភាព ដែលសេវាទាំងអស់សុទ្ធតែមានតម្លៃផ្លូវការ។ ការស្ទង់មតិបង្ហាញឱ្យឃើញថានៅក្នុងសេវាមណ្ឌលសុខភាព ដែលមានការបិទផ្សាយថ្លៃសេវាជាសាធារណៈ អ្នកប្រើប្រាស់សេវាមានការយល់ដឹងពីតម្លៃផ្លូវការច្រើនជាងក្នុងសេវាឃុំ/សង្កាត់ ដែលជាទូទៅពុំមានការបិទផ្សាយពីថ្លៃសេវា។

ជាការពិត កង្វះព័ត៌មានអំពីតម្លៃផ្លូវ ការនាំឱ្យមានការភ័ន្តច្រលំពីសំណាក់អ្នកប្រើប្រាស់ និងបង្កលក្ខណៈងាយស្រួលដល់ការបង់កម្រៃក្រៅផ្លូវការ។ យ៉ាងណាក្តី លទ្ធផលនៃការស្ទង់មតិបង្ហាញអោយឃើញថា ថ្វីត្បិតតែជាការ ចាំបាច់ការយល់ដឹងពីតម្លៃផ្លូវការតែមួយមុខ ពុំមែនជាលក្ខខ័ណ្ឌគ្រប់គ្រាន់សម្រាប់ជៀស វាង ការទាមទារឺការបង់កម្រៃក្រៅផ្លូវការនោះទេ។

## មូលហេតុនៃការបង់កម្រៃក្រៅផ្លូវការ

នៅក្នុងសេវាទាំងបីមូលហេតុនៃការបង់កម្រៃក្រៅផ្លូវការពុំមានលក្ខណៈខុសគ្នាខ្លាំងនោះទេ។ ទាក់ទិននឹងសេវាឃុំ/សង្កាត់ អ្នកផ្តល់ បទសម្ភាសន៍បានទទួលស្គាល់ថា ភាគច្រើនប្រជាជនខ្លួនឯងជាអ្នកបង់កម្រៃបន្ថែមក្នុងគោលបំណង ដើម្បីអរគុណដល់មន្រ្តីឃុំ/សង្កាត់ បង្កើតទំនាក់ទំនងល្អទៅថ្ងៃខាងមុខ និងដើម្បីទទួលបានការផ្តល់សេវាឆាប់រហ័ស។ យ៉ាងណាក្តី ពេលខ្លះប្រជាជនបង់កម្រៃក្រៅផ្លូវការ ដោយសារតែមន្រ្តី ឃុំ/សង្កាត់ធ្វើការតម្រូវតែម្តង។

មូលហេតុទាំងនេះលេចឡើងស្រដៀងគ្នានៅក្នុងសេវាសាធារណៈពីរផ្សេងទៀត ។ ដោយឡែក ក៏មានករណីធ្ងន់ធ្ងរមួយចំនួនក្នុងវិស័យបឋមសិក្សា ដែលគ្រូបង្រៀនមានរហូតដល់ធ្វើការពិន័យសិស្សសម្រាប់ការមិនបានបង់កម្រៃក្រៅផ្លូវការ។ ការពិន័យអាចមានចាប់ពីការស្តីបន្ទោស ទម្លាក់ពិន្ទុ រហូតដល់មិនអនុញ្ញាតិឱ្យឡើងថ្នាក់ក៏មាន។

បញ្ហារួមដែលនាំទៅរកការបង់កម្រៃក្រៅផ្លូវការក្នុងសេវានីមួយៗ គឺដោយសារប្រាក់បៀវត្សរ៍ទាបរបស់មន្រ្តីថ្នាក់មូលដ្ឋាន។ ឆ្លើយ តបទៅនឹងសំណួរ ថាតើមន្រ្តីទាំងនោះនឹងឈប់ ទទួលយកកម្រៃបន្ថែមដែរ ឬទេ ប្រសិនបើពួកគេទទួលបាននូវប្រាក់បៀវត្សរ៍សមរម្យនោះ ប្រជាពលរដ្ឋ និងមន្រ្តីឃុំ/សង្កាត់បានផ្តល់ទាំង ចម្លើយវិជ្ជមាន និងអវិជ្ជមាន។

អ្នកដែលឆ្លើយថា "នឹងឈប់" យល់ឃើញថាការយកកម្រៃក្រៅផ្លូវការជាជម្រើស ចុងក្រោយបង្អស់សម្រាប់មន្ត្រីខណៈដែលពួកគាត់មានប្រាក់បៀវត្សរ៍ទាបសម្រាប់ឧបត្ថម្ភដល់គ្រួសារ។ ផ្ទុយទៅវិញ អ្នកដែលឆ្លើយថា "នឹងមិន ឈប់" ជឿជាក់ថាការយកកម្រៃក្រៅផ្លូវការបាន ក្លាយមកជាទម្លាប់របស់មន្ត្រីសាធារណៈបាត់ទៅហើយ។

## វិសាលភាព និងផលប៉ះពាល់នៃកម្រៃក្រៅផ្លូវការ

យោងតាមទិន្នន័យនៃការស្រាវជ្រាវរបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាទំហំនៃកម្រៃក្រៅផ្លូវការប្រចាំឆ្នាំ ដែលបង់ចូលរដ្ឋបាលឃុំ-សង្កាត់ នៅក្នុងប្រទេសកម្ពុជាមានប្រមាណ ៥ ទៅ ៦ លានដុល្លារអាមេរិក។ បើយោងតាម ទិន្នន័យនៃការស្រាវជ្រាវពីអំពើពុករលួយរបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមឃើញថា ចំនួននេះ មានទំហំតិចជាង ១០% នៃកម្រៃក្រៅផ្លូវការ សរុបប្រចាំឆ្នាំ ដែលបង់ដោយប្រជាជនទៅសេវាសាធា-រណៈ គ្រប់កម្រិតដែលមានប្រមាណ ៦៦ លានដុល្លារ នៅឆ្នាំ ២០០៥។

ជាលក្ខណៈម៉ាក្រូ កម្រៃក្រៅផ្លូវការ ដែលបង់ចូលឃុំ/សង្កាត់ទូទាំងប្រទេស មានកំរិតទាប ពោលគឺមិនដល់ ១% នៃថវិការដ្ឋ សរុប ឬប្រហែល 0.១%នៃផលិតផលក្នុងស្រុក សរុប(ផ.ស.ស)ប៉ុណ្ណោះ។ ប៉ុន្តែផលប៉ះពាល់នៃ កម្រៃក្រៅផ្លូវការទាំងនេះមិនតិចទេ សម្រាប់ ប្រជាពលរដ្ឋក្រីក្រ។ត

យោងតាមលទ្ធផលស្រាវជ្រាវកម្រៃក្រៅផ្លូវការ ដែលមាននៅក្នុងវិស័យបឋមសិក្សាភាគច្រើនប្រមូលផ្តុំនៅទីក្រុងភ្នំពេញ និងទីរួម ខេត្ត។ កម្រៃក្រៅផ្លូវការនៅតាមតំបន់ទីជនបទ ហាក់ពុំត្រូវបានមើលឃើញដោយសារមូលហេតុ ចំបងបីៈ ទី១ គ្រួសារនៅតាមជនបទជាទូទៅក្រីក្រ និងមិនមានលទ្ធភាពបង់កម្រៃក្រៅផ្លូវការ។ ទី២ គ្រូបង្រៀននៅតាមទីជនបទភាគ ច្រើនប្រកបការងារកសិកម្មដែលអាចឱ្យពួកគាត់អាចរកចំណូល និងអាហារសម្រាប់បង្គ្រប់។ ទី៣ គ្រូបង្រៀន និងប្រជាជនតាមជនបទហាក់មានទំនាក់ទំនងជិតស្និទ ខ្លាំងជាងតាមទីប្រជុំជន ដោយសារតែមានប្រជាជនតិច។

ដោយឡែក ពុំមានសញ្ញាញជាក់លាក់ណាមួយកំណត់ពីកម្រៃក្រៅផ្លូវការនៅតាមមណ្ឌលសុខភាពនោះទេ។ មូលហេតុគឺដោយសារ ទំហំសេវាកម្មនៅទីនោះមានកំរិតតូច ហើយតម្លៃដែលជាទូទៅទាបត្រូវបានគេបិទផ្សាយជា សាធារណៈនៅតាមមណ្ឌលសុខភាពភាគច្រើន។ លើសពីនេះទៀត ប្រជាជនប្រើប្រាស់សេវាមណ្ឌល សុខភាព ក៏ដោយសារតែពួកគាត់មិនមានលទ្ធ ភាពទៅកាន់មន្ទីរពេទ្យបង្អែក ឬគ្លីនិកឯកជន។

### *កម្រៃក្រៅផ្លូវការជាចំណូល បន្ថែមលើប្រាក់បៀវត្សរ៍*

អ្នកផ្តល់ចម្លើយភាគច្រើន ជាមន្ត្រីរាជការក៏ដូចប្រជាជនដែរ យល់ឃើញថាមូលហេតុចំបងនៃកម្រៃក្រៅផ្លូវការទាក់ទិនយ៉ាងជិតស្និទទៅនឹងតម្រូវការមូលដ្ឋានរបស់មន្ត្រីសាធារណៈ។ ក្នុងន័យនេះឃើញថាកម្រៃក្រៅផ្លូវការបង្កើតបាន ជាចំណូលបន្ថែមដ៏សំខាន់មួយទៅលើប្រាក់បៀវត្សរ៍បច្ចុប្បន្នរបស់មន្ត្រី ជាពិសេសសម្រាប់មន្ត្រី ឃុំ/សង្កាត់ និងគ្រូបឋមសិក្សានៅតាមទីក្រុង។

ផ្អែកលើចំនួនសរុបនៃកម្រៃក្រៅផ្លូវការទូទាំងប្រទេស ចំនួនប្រមាណ ៣៦ ដុល្លារ អាចជាចំណូលបន្ថែមទៅលើប្រាក់បៀវត្សរ៍ប្រចាំខែរបស់មន្ត្រីឃុំ/សង្កាត់ដែលសព្វថ្ងៃមានប្រមាណជា ១៨ ដុល្លារ។ ផ្អែកលើចំនួនជាក់ស្តែងនៃកម្រៃក្រៅផ្លូវការក្នុងឃុំ/សង្កាត់នីមួយៗចំនួនបន្ថែមនេះ ខុសប្លែកគ្នាខ្លាំងរវាងទីប្រជុំជន និងជនបទ។ យ៉ាងណាក្តី ក្នុងការអនុវត្តជាក់ស្តែងការបែងចែកប្រាក់ក្រៅផ្លូវការទាំងនោះពុំបានធ្វើឡើងដោយស្មើភាពគ្នាដល់មន្ត្រីឃុំ-សង្កាត់ទាំងអស់នោះទេ ភាគច្រើនត្រូវចែកទៅឱ្យស្មៀន និងមេឃុំដែលជាអ្នកមានអំណាចរដ្ឋបាលច្រើនជាងគេ។

ទាក់ទិនទៅនឹងកម្រៃក្រៅផ្លូវការ តាមសាលាបឋមសិក្សានៅទីក្រុងភ្នំពេញគ្រូបង្រៀនម្នាក់ៗអាចទទួលបានទឹកប្រាក់ប្រមាណ ជា ៤៦ ដុល្លារ បន្ថែមលើប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគាត់ ដែលសព្វថ្ងៃមានប្រមាណ ៣០ ដុល្លារ។ បន្ថែមពីលើនេះ គ្រូបង្រៀននីមួយៗ អាចរកចំណូលបានប្រមាណ ៧៥ ដុល្លារក្នុងមួយខែពីការបង្រៀនបន្ថែមម៉ោង ។ ប៉ុន្តែ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា ប្រមាណត្រឹមតែ ៣៣% នៃគ្រូបង្រៀនតាមទីក្រុង និង ៩% នៃគ្រូបង្រៀននៅតាមជនបទប៉ុណ្ណោះ អាចបង្រៀនបន្ថែមម៉ោងដើម្បីរកកម្រៃបន្ថែម។

### ***កម្រៃក្រៅផ្លូវការ និងថវិកាឃុំ/សង្កាត់***

ក្នុងនាទីជារដ្ឋបាលវិមជ្ឈការ ឃុំ/សង្កាត់ទទួលបានប្រភពចំណូលផ្លូវការបីសំខាន់ៗៈ ប្រាក់វិភាជពីរដ្ឋាភិបាលកណ្តាលចំណូលផ្ទាល់ខ្លួន និងប្រាក់បដិភាគចូលរួមដោយប្រជាពលរដ្ឋតាមមូលដ្ឋាន។ យ៉ាងណាក្តី ប្រព័ន្ធហិរញ្ញវត្ថុឃុំ/សង្កាត់នាពេលបច្ចុប្បន្នពឹងផ្អែកយ៉ាងខ្លាំងទៅលើថវិកា ដែលផ្ទេរមកពីរដ្ឋបាលកណ្តាលខណៈពេលដែលប្រភពពីរទៀតនៅទន់ខ្សោយខ្លាំងដោយសារតែមូលហេតុផ្លូវច្បាប់ និងការអនុវត្តមួយចំនួន។

ក្នុងឆ្នាំ ២០០៦ ថវិកាដែលផ្ទេរពី រដ្ឋាភិបាលទៅឱ្យឃុំ/សង្កាត់ចំនួន ១ ៦២១ មាន ប្រមាណ ១៩ លានដុល្លារ។ ១ ភាគ ៣ នៃថវិកានេះ ប្រើសម្រាប់ចំណាយរដ្ឋបាល ហើយចំណែក ដែលនៅសល់សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។ ចំនួនថវិកាជាមធ្យម ដែលផ្ទេរទៅឱ្យឃុំនីមួយៗ មានប្រមាណ ១១ ៧០០ ដុល្លារ។

ជាមធ្យម កម្រៃផ្លូវការប្រចាំឆ្នាំដែល ប្រមូលដោយឃុំ/សង្កាត់នីមួយៗ មានចំនួន ៤៤០ ដុល្លារនៅទីក្រុងភ្នំពេញ ៣០០ ដុល្លារ នៅ តាមទីរួមខេត្ត/ក្រុង ១៧០ ដុល្លារ នៅតាមទី រួមស្រុក និង ១០០ ដុល្លារ តាមទីជនបទ។ ដោយឡែក ចំណែកនៃប្រាក់បដិភាគដែលបង់ ចូលក្នុងគម្រោងអភិវឌ្ឍន៍នីមួយៗ

ជាមធ្យម មានប្រមាណ ៨% នៅតាមសង្កាត់ក្នុងទីក្រុង ភ្នំពេញ ៥% នៅតាមទីរួមខេត្ត/ក្រុងដទៃ និង ៣% តាមឃុំនៃទីរួមស្រុក និងតំបន់ជនបទ។

ក្រៅពីចំណូលផ្លូវការទាំងនេះ កម្រៃក្រៅផ្លូវការផ្តល់បានជាចំណែកបន្ថែមយ៉ាងសំខាន់មួយ បើរាប់បញ្ចូលទៅក្នុងថវិកាឃុំ-សង្កាត់ នីមួយៗ។ ជាទូទៅ ចំណែកនៃកម្រៃក្រៅផ្លូវការមានកម្រិតខ្ពស់នៅតាមសង្កាត់ ក្នុង ទីក្រុងភ្នំពេញ (៣៨%) ហើយថយចុះនៅតាម ទីរួមខេត្ត (៣១%) ទីរួមស្រុក (២០%) និងតំបន់ជនបទ (១២%)។

### *កម្រៃក្រៅផ្លូវការ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន*

ជាទូទៅលទ្ធផលនៃការស្រាវជ្រាវមិនបានរកឃើញថា កម្រៃក្រៅផ្លូវការមានផលប៉ះពាល់ខ្លាំងដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន នោះទេ។ ជាមធ្យមក្នុងមួយឆ្នាំ ប្រជាជនម្នាក់បង់ប្រហែលជា ៩000 រៀល (២,២៥ដុល្លារ) ទៅឱ្យឃុំ/សង្កាត់ជាកម្រៃក្រៅផ្លូវការ។ បើធៀបនឹងការចំណាយប្រចាំឆ្នាំរបស់ពួកគេ ចំណែកជាមធ្យមនៃកម្រៃក្រៅផ្លូវការដែលបង់ដោយប្រជាជនម្នាក់មានទំហំខុសគ្នារវាងតំបន់ជនបទ និងទីប្រជុំជន ពោលគឺ 0,២% នៅតាមជនបទ និង 0,៥% នៅទីរួមខេត្ត/ក្រុង។

ទោះជាយ៉ាងណាក្តី ទម្លាប់នៃការ បង់កម្រៃក្រៅផ្លូវការជាបន្ទុកដ៏អវិជ្ជមានមួយ សម្រាប់ប្រជាជនដែលមានជីវភាពខ្សត់ខ្សោយ ហើយនឹងធ្វើឱ្យតម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាថ្នាក់មូលដ្ឋានមាន ភាពមិនល្អ។

## ជំហានបន្ទាប់ឆ្ពោះទៅរកប្រសិទ្ធភាពនៃសេវាមូលដ្ឋានៈ សំណូមពរពីអ្នកពាក់ព័ន្ធនានា

ទាក់ទិនទៅនឹងប្រសិទ្ធភាពសេវាថ្នាក់មូលដ្ឋាន ការបង្កើនបៀវត្សរ៍របស់មន្ត្រីឱ្យដល់កម្រិតសមរម្យមួយត្រូវបានមើលឃើញថា ជាបុរេលក្ខខណ្ឌសម្រាប់ឱ្យកំណែទម្រង់ដទៃអាចទទួលបានផ្លែផ្កាពេញលេញ។

### *ការដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាតម្លៃផ្លូវការ និងការបង្កើនបៀវត្សរ៍របស់មន្ត្រី*

ទាក់ទងនឹងការបង្កើនបៀវត្សរ៍របស់ មន្ត្រីឃុំ/សង្កាត់ ជម្រើសបីសំខាន់ៗត្រូវបានលើកឡើងៈ ដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាតម្លៃផ្លូវការ បង្កើនថវិកាឧបត្ថម្ភពីថវិកាជាតិ និង បង្កើនប្រភពចំណូលផ្ទាល់របស់ឃុំ/សង្កាត់ តាមរយៈការពង្រីកសមត្ថកិច្ចក្នុងការផ្តល់សេវា មូលដ្ឋាន។

ការដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាផ្លូវការមិនត្រឹមតែអាចចូលរួមពង្រីកថវិកា ឃុំ/សង្កាត់ប៉ុណ្ណោះទេ ថែមទាំងជួយធ្វើឱ្យដំណើរការ និងការគ្រប់គ្រងបង់ថ្លៃសេវាកាន់តែមានតម្លាភាពទៀតផង។ ព្រមគ្នា

ជាមួយនឹង ការយល់ឃើញបែបនេះ មន្ត្រីឃុំ/សង្កាត់ ក៏បាន សំដែងចេញផងដែរនូវក្តីបារម្ភទៅលើបញ្ហាថា តើរដ្ឋាភិបាលនឹងអនុញ្ញាតិឱ្យប្រើប្រាស់កម្រៃទាំងនោះ ដើម្បីបង្កើនប្រាក់បៀវត្សរ៍របស់ពួកគាត់ឬយ៉ាងណា។

ទោះជាយ៉ាងណាក្តី ចំនួនទឹកប្រាក់ ដែលអាចបំលែងឱ្យទៅជាផ្លូវការទាំងនោះ ក៏នឹងមិនអាចគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់មន្ត្រីឃុំ/សង្កាត់បានទាំងស្រុងនោះទេ ជាពិសេសចំពោះឃុំដាច់ស្រយ៉ាលដែលជាទូទៅការផ្តល់សេវាមិនមានភាពញឹកញាប់។

ក្នុងបរិបទនៃការតាក់តែងច្បាប់ ទាក់ទិននឹងរដ្ឋបាលដែនដីនាពេលខាងមុខនេះមានសង្កាត់នៅតាមទីក្រុង និងឃុំនៅទីរួមខេត្តមួយចំនួនជឿជាក់ថាសង្កាត់របស់ពួកគាត់នឹងអាចរស់បានបើទោះជាមិនមានការផ្ទេរថវិកាពីរដ្ឋបាលកណ្តាលក្តី ប្រសិនបើពួកគេអាចប្រមូលបាននូវកម្រៃសេវាផ្សេងៗ និងពន្ធថ្នាក់មូលដ្ឋានមួយចំនួននោះ។ ផ្ទុយទៅវិញ ឃុំតាមជនបទភាគច្រើននៅតែមិនជឿថាពួកគេអាចរស់បានដោយខ្លួនឯងឡើយ។

ប្រភពចំណូលដែលមន្ត្រីឃុំរំពឹងថា គួរត្រូវបានផ្តល់ឱ្យនោះ គឺសំដៅជាពិសេសលើសកម្មភាពសេដ្ឋកិច្ចនៅជុំវិញទីផ្សារតាមមូលដ្ឋានរបស់ពួកគាត់ពន្ធលើមធ្យោបាយធ្វើដំណើរ ពន្ធលើដីដែលមិនប្រើប្រាស់ និងពន្ធលើអាជីវកម្មតូចតាចដទៃទៀត។ ក្នុងករណីមួយចំនួន ឃុំ/សង្កាត់ ជឿថាពួកគេនឹងអាចប្រមូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងអជ្ញាធរថ្នាក់លើដោយហេតុថា ពួកគាត់អាចក្តាប់ស្ថានការណ៍ក្នុងសហគមន៍របស់ពួកគាត់បានជិតដិតជាង។

ទាក់ទងនឹងសេវាបឋមសិក្សា និងមណ្ឌលសុខភាព ការបង្កើនប្រាក់បៀវត្សរ៍ឱ្យដល់កម្រិតសមរម្យមួយនឹងជួយទប់ស្កាត់ការយកកម្រៃក្រៅផ្លូវការដោយគ្រូបង្រៀន និងបុគ្គលិកមណ្ឌលសុខភាព ។ ជាងនេះទៀត វាក៏ជាការលើកទឹកចិត្តពួកគាត់ឱ្យផ្តល់សេវាបានល្អ ជាងមុនដល់សហគមន៍ផងដែរ។

### *ការបង្កើនការយល់ដឹងរបស់ប្រជាជន និងពង្រឹងក្រមសីលធម៌*

នៅពេលដែលប្រាក់បៀវត្សរ៍ និង ថវិកាមូលដ្ឋានមានលក្ខណៈសមរម្យហើយនោះ ការបង្កើនចំណេះដឹងរបស់ប្រជាជនអំពីតម្លៃផ្លូវការ និងការពង្រឹងក្រមសីលធម៌ដល់មន្ត្រីថ្នាក់មូលដ្ឋានចាំបាច់ត្រូវរឹតបណ្តឹង។

តាមរយៈការពិភាក្សាជាក្រុម និងបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធតាមមូលដ្ឋាន ការបិទផ្សាយពីតម្លៃផ្លូវការជាសាធារណៈត្រូវតែមានជាចាំបាច់។ "តារាងព័ត៌មាន" អំពីតម្លៃសេវាគួរត្រូវបានបង្កើតឡើងនៅទីកន្លែងដែលអ្នកប្រើប្រាស់ងាយមើលឃើញ។

ដើម្បីលុបបំបាត់ ឬកាត់បន្ថយនូវកម្រៃក្រៅផ្លូវការ ក្រមសីលធម៌ បទបញ្ជា រដ្ឋបាល និង ជាពិសេសវិធានការពិន័យចាំបាច់ត្រូវបានបង្កើតឡើង ហើយអនុវត្តឱ្យបានម៉ឺងម៉ាត់។

តាមយោបល់អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ការដាក់ចេញនូវក្រមវិជ្ជាជីវៈ ឬបទបញ្ញានានាគួរផ្តោតជាពិសេសទៅលើវិធីសាស្ត្រក្នុងការផ្លាស់ប្តូរទម្លាប់ និងចិត្តគំនិតរបស់មន្ត្រីរាជការពីការបំពេញការងារបែប ជាអ្នកគ្រប់ គ្រងឱ្យទៅជាបម្រើសេវាសាធារណៈវិញ ដោយឈរលើគោលការណ៍អតិថិជនជាធំ ។

សម្រាប់ការអប់រំថ្នាក់បឋមសិក្សា និងសេវាសុខភាព ការយកចិត្តទុកដាក់គួរផ្តោតលើការដាក់ចេញនូវគោលនយោបាយដែលត្រឹមត្រូវសមរម្យ ការបង្កើនសមត្ថភាពបុគ្គលិក និងការបំពាក់សម្ភារៈឱ្យបានគ្រប់គ្រាន់ ។ ដោយឡែក បុគ្គលិកមណ្ឌលសុខភាពគួរត្រូវបានបណ្តុះបណ្តាលខាងវិជ្ជាជីវៈឱ្យបានពេញលេញ និងជាប្រចាំដើម្បីទទួលបានចំណេះដឹង និងជំនាញសម ស្របទៅនឹងតម្រូវការថ្មីនៅតាមសហគមន៍ ។

## អនុសាសន៍ និងសេចក្តីសន្និដ្ឋាន

ការបង្កើនដែនអន្តរាគមន៍ និងតួនាទីរបស់ឃុំ/សង្កាត់ទៅក្នុងសេវាមូលដ្ឋានទាំងបី នឹងអាចជួយបង្កើនគុណភាពសេវាមូលដ្ឋានឱ្យកាន់តែប្រសើរឡើង។ ដោយឡែក ការអប់រំថ្នាក់បឋមសិក្សា និងសុខភាពថ្នាក់មូលដ្ឋានទាមទារឱ្យមានជំនាញបច្ចេកទេស ដែលសព្វថ្ងៃមិនមាននៅឡើយតាមសាលាឃុំ/សង្កាត់ ។

តាមរយៈការសិក្សានេះ ការបង្កើនប្រសិទ្ធភាពសេវាសាធារណៈមូលដ្ឋានដោយ គ្មានការបង់កម្រៃក្រៅផ្លូវការ គឺជារឿងដែលអាចធ្វើទៅបាន ប្រសិនបើឃុំ/សង្កាត់ទាំងអស់មានថវិកាគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់មន្ត្រី និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ ជាលក្ខណៈម៉ាក្រូ កម្រៃក្រៅផ្លូវការមានទំហំតិចតួចណាស់ពោលគឺមិនដល់ ១%នៃថវិការដ្ឋ ប៉ុន្តែ ផ្តល់ផលប៉ះពាល់គួរឱ្យកត់សំគាល់ទៅលើប្រជាជនក្រីក្រ ទាក់ទិននឹងប្រសិទ្ធភាពនៃសេវាកម្ម ។

យ៉ាងណាក្តី ការដាក់កម្រៃក្រៅ ផ្លូវការឱ្យទៅជាផ្លូវការ ក៏នៅមិនទាន់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពមន្ត្រីនោះឡើយទេ ។ចាំបាច់ត្រូវពង្រឹងស្វ័យភាពហិរញ្ញវត្ថុដល់ឃុំ-សង្កាត់ពោលគឺអំណាច និងសមត្ថភាពក្នុងការប្រមូលពន្ធមូលដ្ឋាន គឺជាការចាំបាច់ ។ ច្បាប់គ្រប់គ្រងរដ្ឋបាលដែនដីគួរកំណត់ឱ្យបានច្បាស់ពីតួនាទីទាំងនេះ ។

គោលនយោបាយដែលកើតចេញពី ការគិតគូរដ៏ល្អិតល្អន់មួយគួរត្រូវបានដាក់ចេញ ដើម្បីធ្វើការសាកល្បងដាក់តម្លៃសេវារដ្ឋបាលទាំងឡាយឱ្យទៅជាផ្លូវការ និងផ្ទេរការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួនទៅឱ្យឃុំ/សង្កាត់ ។ យ៉ាងណាមិញ ត្រូវមានការសិក្សាជាក់លាក់បន្ថែមទៀតលើគម្រោងសាកល្បងនេះ ដែលអាចផ្តល់នូវចំណេះដឹងជាក់ស្តែងចាំបាច់ត្រូវអនុវត្តទៅដល់ឃុំ/សង្កាត់ ដទៃៗទៀតជាបន្តបន្ទាប់ ។

ដើម្បីឱ្យគម្រោងសាកល្បងមួយនេះ   អាចរៀបចំឡើងបានល្អចាំបាច់ទាមទារឱ្យមានការផ្ដល់ចំណេះដឹងគ្រប់គ្រាន់មួយអំពីទំហំនិងលក្ខខណ្ឌនៃការងារ   ដែលត្រូវធ្វើសម្រាប់ជាគន្លឹះដល់អ្នកចេញគោលនយោបាយក្នុងការចាត់វិធានការជាក់ស្ដែងបន្ត។

# ហេតុអ្វីបានជាមានការសិក្សានេះ?

បណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើនកំពុងជួបប្រទះនូវបញ្ហាអំពើពុករលួយ ដោយសារតែមិនមាននូវតម្លាភាព និងគណនេយ្យភាពក្នុងប្រព័ន្ធអភិបាលកិច្ច ហើយនិងការអនុវត្តមិនបានល្អនូវវិធានការប្រឆាំងអំពើពុករលួយ។ គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា គឺយុទ្ធសាស្ត្រចតុកោណ ដែលមានអភិបាលកិច្ចល្អជាមូលដ្ឋានគ្រឹះ។ អភិបាលកិច្ចល្អនេះ គឺជាមធ្យោបាយមួយដ៏ប្រសើរដែលក្នុងនោះ អាជ្ញាធរសាធារណៈត្រូវបានបង្កើតឡើងដើម្បីបម្រើ ត្រួតពិនិត្យ និងបែងចែកធនធានសង្គមប្រកបដោយប្រសិទ្ធភាព និងសមធម៌។

អំពើពុករលួយដែលមានលក្ខណៈជាប្រព័ន្ធក្នុងសេវាសាធារណៈនៅកម្ពុជា ត្រូវបានគេចាត់ទុកថាជាបញ្ហាដ៏ចំបង ដែលរារាំងដល់ការអភិវឌ្ឍប្រទេស តាមរយៈការធ្វើឱ្យខូចខាតនូវសុឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយនឹងប្រជាពលរដ្ឋ។ ផ្អែកលើបញ្ហាចំបងៗមួយចំនួន ដែលផ្តល់ផលប៉ះពាល់ដល់សេវាសាធារណៈ *--ប្រាក់បៀវត្សរ៍ទាប ជំនាញតិច និងដូច្នេះ សមត្ថភាពទាប--* ដំណោះស្រាយដែលល្អគួរតែរួមបញ្ចូលនូវការបង្កើនចំណូលអោយបានច្រើនជាងមុន ដើម្បីគាំទ្រកំណែទម្រង់ទៅលើការបង់ថ្លៃសេវាសាធារណៈនិងជំរុញអោយមានការផ្តល់សេវាដែលប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ថ្មីៗនេះ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាបានចងក្រងជាឯកសារមួយ ស្តីពីការសិក្សាលើអំពើពុករលួយនៅក្នុងវិស័យឯកជន[1]រួចមកហើយ ទាក់ទិនទៅនឹងការរីករាលដាល និងឥទ្ធិពលអវិជ្ជមាននៃបញ្ហាទាំងនេះ។ ចំណែកឯការសិក្សាថ្មីនេះវិញ មានគោលបំណងផ្តោតទៅលើការយកកម្រៃក្រៅផ្លូវការនានា ដែលមាននៅតាមសេវាសាធារណៈថ្នាក់មូលដ្ឋាន ជាពិសេសសេវាឃុំ/សង្កាត់។ មកដល់ពេលនេះ អាជ្ញាធរឃុំ/សង្កាត់ មិនទាន់អាចធានាបាននូវដំណោះស្រាយមួយចំពោះបញ្ហាប្រមូលថ្លៃសេវាសាធារណៈ ដែលមិនមានតម្លាភាព និងការបង្កើនគុណភាពសេវាទាំងនោះនៅឡើយទេ។

សេវានានានៅតាមការិយាល័យឃុំ/សង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា គឺជាសេវាចំបងនៅថ្នាក់មូលដ្ឋានដែលមានសារៈសំខាន់បំផុតសំរាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន បើផ្អែកលើចំនួនដងនៃការប្រើប្រាស់សេវា។ ការធ្វើអោយសេវាទាំងនោះកាន់តែមានតម្លាភាព និងគណនេយ្យភាព និងការបង្កើនគុណភាពសេវាទាំងនេះ នឹងជួយលើកកំពស់ធនធានមនុស្ស និងសុខុមាលភាពសង្គមនៅកម្ពុជាអោយកាន់តែប្រសើរឡើង។ ជាមួយគ្នានឹងការពិនិត្យពីសេវាទាំងបីនេះ ការសិក្សានឹងផ្តោតជាសំខាន់ទៅលើសេវានៅសាលាឃុំ/សង្កាត់។ ការិយាល័យឃុំ/សង្កាត់ស្ថិតនៅក្រោម ទំនួលខុសត្រូវផ្ទាល់របស់រដ្ឋបាលមូលដ្ឋាន

[1] វ.ស.ក. (២០០៦)

ដូច្នេះការសិក្សានេះនឹងផ្តល់មូលដ្ឋានគ្រឹះ សម្រាប់រាជរដ្ឋាភិបាលក្នុងការសាកល្បងគោលនយោបាយថ្មៃប្រឌិតរបស់ខ្លួននៅកំរិតមូលដ្ឋាន។

ការសិក្សាស្រាវជ្រាវនេះអាចកើតមានឡើង ដោយយោងទៅលើតម្រូវការចាំបាច់ក្នុងការកំណត់នូវវិធានការណ៍ដែលអាចធ្វើទៅបានមួយចំនួន ក្នុងការលុបបំបាត់ចំណាយក្រៅផ្លូវការលើសេវាថ្នាក់មូលដ្ឋានជាពិសេសរដ្ឋាបាលថ្នាក់ឃុំ/សង្កាត់ និងជាជំនួយដល់មន្ត្រីស៊ីវិលថ្នាក់ឃុំក្នុងការកែប្រែការ ប្រតិបត្តិអោយកាន់តែប្រសើរឡើង។

របាយការណ៍នេះទទួលបានមូលនិធិគាំទ្រដោយអង្គការ DANIDA និង Pact Cambodia។ របាយការណ៍នេះ នឹងផ្តល់នូវលទ្ធផលជាក់ស្តែងស្តីពី លក្ខណៈ មូលហេតុ និងវិសាលភាពនៃចំណាយក្រៅផ្លូវការដែលបង់ដោយប្រជាជនទៅលើសេវាសាធារណៈនៅថ្នាក់ឃុំ។ លទ្ធផលទាំងនេះ អាចជាមូលដ្ឋានបទពិសោធន៏គោលនយោបាយជាក់ស្តែង ក្នុងការសាកល្បងដាក់អោយកម្រៃក្រៅផ្លូវការទាំងនោះទៅជាផ្លូវការព្រោះជាយុទ្ធសាស្ត្រមួយដែលទាំងអ្នកប្រើប្រាស់(ប្រជាជន) និងអ្នកផ្តល់សេវា (អជ្ញាធរមូលដ្ឋាន) សុទ្ធតែគិតថាអាចធ្វើបាន និងសមស្រប។

# ជំពូកទី ១
# ប្រសិទ្ធភាពសេវាសាធារណៈ និងចំណាយក្រៅផ្លូវការ៖ ទិដ្ឋភាពទូទៅ

ជំពូកនេះនឹងផ្តល់ជាទិដ្ឋភាពទូទៅដែលទាក់ទងនឹងចំណាយក្រៅផ្លូវការ ជាមួយនឹងការវិភាគជាក់លាក់មួយអំពីការផ្តល់សេវាមួយចំនួននៅថ្នាក់មូលដ្ឋាន។ ជំពូកនេះនឹងបង្ហាញផងដែរ ពីប្រសិទ្ធភាពនៃសេវាថ្នាក់មូលដ្ឋានជាមួយនឹងការយល់ឃើញរបស់ប្រជាជនទៅលើភាពស្មោះត្រង់របស់អ្នកផ្តល់សេវាទាំងនោះ។

## ១.១. ទិដ្ឋភាពរួមនៃចំណាយក្រៅផ្លូវការ

បញ្ហាអំពើពុករលួយត្រូវបានគេលើកយកមកពិភាក្សាយ៉ាងខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាល សង្គមស៊ីវិល និងម្ចាស់ជំនួយកំពុងគិតគូរ និងរិះរកយុទ្ធសាស្ត្រនានា ដើម្បីកែច្នៃស្ថានការណ៍បច្ចុប្បន្នឱ្យប្រសើរឡើង។ ប្រទេសកម្ពុជាទទួលចំណាត់ថ្នាក់លេខ ១៥១ ក្នុងចំណោមប្រទេស ១៦៣ នៅឆ្នាំ ២០០៦ បើតាមសន្ទស្សន៍អំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ ដែលចំណាត់ថ្នាក់នេះមានការធ្លាក់ចុះ ពីចំណាត់ថ្នាក់ចាស់ឆ្នាំ ២០០៥ ចំនួន ២១ លេខ។ តួរលេខនេះបង្ហាញពីភាពធ្ងន់ធ្ងរ និងភាពរីករាលដាលនៃអំពើពុករលួយ[២]។

ការពិភាក្សាគោលនយោបាយបានលើកឡើង តាមការវាយតម្លៃរបស់របាយការណ៍ស្រាវជ្រាវមួយចំនួន ដោយរបាយការណ៍ការស្រាវជ្រាវខ្លះផ្តោតទៅលើការយល់ឃើញរបស់ប្រជាជន និងឥទ្ធិពលហិរញ្ញវត្ថុដោយផ្ទាល់ទៅលើជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ[៣] និងរបាយការណ៍ផ្សេងទៀតសិក្សាទៅលើឥទ្ធិពលលើវិស័យឯកជន[៤]។ ទោះជាយ៉ាងណាក៏ដោយ ចំណុចស្នូលនៃការពិភាក្សា គឺផ្តោតទៅលើតម្រូវការឱ្យមានការធ្វើអន្តរាគមន៍កម្រិតម៉ាក្រូ ដើម្បីកែលំអនីតិរដ្ឋ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បរិយាកាសវិនិយោគ និងភាពប្រកួតប្រជែងជាដើម។ ដូច្នេះ កិច្ចពិភាក្សាបានផ្តោតខ្លាំងទៅលើបញ្ហាជាច្រើន ដូចជាបញ្ហាលំបាកជុំវិញបទបញ្ញត្តិ (ច្បាប់ប្រឆាំងអំពើពុករលួយ) និងស្ថាប័នថ្នាក់ជាតិមួយចំនួន (អង្គភាពប្រឆាំងអំពើពុករលួយ ឯករាជ្យភាពនៃតុលាការពាណិជ្ជកម្ម)។ ទោះបី ចំណុចទាំងនេះជាចំនុចចាំបាច់ក្តី ប៉ុន្តែ វានៅមានការខ្វះខាតជាច្រើន ជាពិសេស ការយកចិត្តទុកដាក់លើគំនិតផ្តួចផ្តើមអោយមានការដោះស្រាយអំពី

---

[២] អាចរកបាននៅ http://www.icgg.org/corruption.cpi_2006.html

[៣] ឧទាហរណ៍ចំបងគឺ ម.អ.ស - 2005A

[៤] ការស្រាវជ្រាវថ្មីបំផុតរបស់ វ.ស.ក. ២០០៦

ផលប៉ះពាល់នៃអំពើពុករលួយលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ គំនិតផ្តួចផ្តើមបែបនេះទាមទារឱ្យមានការយកចិត្តទុកដាក់ធ្វើឡើង ដោយហេតុថា :

១. ការមិនយកចិត្តទុកដាក់លើភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ *ដោយផ្ទាល់* នៃសំណូក និងចំណាយក្រៅផ្លូវការនៅកំរិតរដ្ឋបាលមូលដ្ឋាននេះ នឹងជាមូលហេតុចំបងដែលអំពើពុករលួយធ្វើឱ្យប៉ះពាល់ខ្លាំងដល់កិច្ចសន្យាសង្គមនានារវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ ទោះជាយ៉ាងនេះក្តី ឃើញថាកម្ពុជាហាក់ដូចជានៅមានការលេចធ្លោនៅក្នុងតំបន់នៅឡើយ ទាក់ទងទៅនឹងទំនុកចិត្តរបស់ប្រជាជនលើស្ថាប័នរដ្ឋ[៥]។

២.ម្យ៉ាងទៀតនៅថ្នាក់មូលដ្ឋាននេះហើយដែលកិច្ចប្រឹងប្រែងកំណែទម្រង់កម្ពុជាសព្វថ្ងៃ ទទួលបានជោគជ័យគួរអោយកត់សំគាល់ ដែលក្នុងចំណោមកំណែទម្រង់ស្ថាប័នទាំងអស់កំណែទម្រង់វិមជ្ឈការទទួលការជោគជ័យ និងមានប្រសិទ្ធភាពល្អជាងគេ។ ចំណុចសំខាន់ឃុំ/សង្កាត់ទទួលបានស្វ័យតភាពពីរដ្ឋបាលថ្នាក់ជាតិ។ លើសនេះទៅទៀត ភាពខុសគ្នានៃស្ថានភាពនៅតាមមូលដ្ឋាន និងការណ៍ដែលមានឱកាសស្វែងរកផលលាភតិចតួចផ្តល់នូវវិសាលភាពបន្ថែមសំរាប់ការសាកល្បង និងការស្វែងយល់គោលនយោបាយថ្មីៗ ជាជាងការផ្លាស់ប្តូរនយោបាយរបស់ស្ថាប័នរដ្ឋថ្នាក់ខ្ពស់ជាងនេះដោយផ្ទាល់ ដែលការប៉ះទង្គិចខាងអំណាចអាចបង្កជាបញ្ហា និងឧបសគ្គច្រើន។

ឈរលើគោលការណ៍នេះ រដ្ឋបាលមូលដ្ឋានដែលគួរចាប់អារម្មណ៍ជាគេគឺ រដ្ឋបាលឃុំ/សង្កាត់ ដែលនៅជិតស្និតទៅនឹងសហគមមូលដ្ឋាន និងជាអ្នកទទួលខុសត្រូវ និងចូលរួមដោយផ្ទាល់ក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ។ លើសនេះទៅទៀត រដ្ឋបាលឃុំ/សង្កាត់ ជាអជ្ញាធរស្វ័យត ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋ ។ ដូច្នេះ កម្រិតនៃការឆ្លើយតបរបស់អាជ្ញាឃុំ-សង្កាត់ចំពោះតម្រូវការប្រជាជន (ទំនួលខុសត្រូវ ការអើពើ ការដឹងសុខទុក្ខ ក៏ដូចជាការគ្រប់គ្រងទូទៅជាដើម) អាចមានទំហំខុសគ្នា បើប្រៀបធៀបទៅនឹងអជ្ញាធរក្រោមថ្នាក់ជាតិដទៃទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលថ្នាក់ជាតិ រួមមានអាជ្ញាធរស្រុក និងខេត្ត/ក្រុងជាដើម។

ជាងនេះទៅទៀត នៅមានភស្តុតាងជាច្រើនដែលបង្ហាញថា ប្រជាជនកម្ពុជាមិនបានចាត់ទុករដ្ឋាភិបាលថា ជាអ្នកតំណាងឱ្យផលប្រយោជន៍សម្ហហភាព ឬជាអ្នករ៉ាប់រងភារកិច្ចក្នុងការផ្តល់សេវាសាធារណៈនៅឡើយទេ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលត្រូវបានមើលឃើញថាជាកំលាំងខាងក្រៅមួយ ដែលអាចបង្កឧបសគ្គ និងដែលគួរតែចៀសវាងទៀតផង។ ដើម្បីជំរុញឱ្យមាន និងបង្កើនល្បឿននៃការផ្លាស់ប្តូរវិរិយាបទបែបនេះ រដ្ឋបាលឃុំ/សង្កាត់ដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយផ្ទាល់មានតួនាទីសំខាន់ជាងគេក្នុងដំណើរ

---

[៥] សូមមើល ម.អ.ស ២០០៥ ទំព័រ ៤៥-៤៩ និង Hean et all ( 2004) ទំព័រទី ៨

ការផ្តើមកំណែទម្រង់។ យ៉ាងនេះក្តី ការយល់ឃើញរបស់សាធារណៈជនចំពោះអាជ្ញាធរថ្នាក់ឃុំ/សង្កាត់ ដែលនៅជាប់នឹងពួកគាត់នេះ ក៏នៅមិនទាន់មានលក្ខណៈជាវិជ្ជមានប៉ុន្មានដែរទេ រឺក៏អាចថាអវិជ្ជមានផង តែយ៉ាងហោចណាស់ក៏ហាក់នៅប្រសើរជាងអជ្ញាធរ ដែលនៅឆ្ងាយជាងនេះ[៦]។ ដូចគ្នានេះដែរ ការជួបសម្ភាសន៍ជាមួយនឹងសាធារណជន និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់[៧]ជាច្រើន បានបង្ហាញថាទស្សនៈរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលឃុំ/សង្កាត់ មានភាពរីកចំរើនរគួរឱ្យកត់សំគាល់ចាប់តាំងពីពេលដែលមានការផ្លាស់ប្តូរឱ្យមានការជ្រើសតាំងថ្នាក់ដឹកនាំឃុំ/សង្កាត់ តាមរយៈ ការបោះឆ្នោតមក។ លទ្ធផលនៃសិក្សានេះក៏បានបញ្ជាក់ពីការរីកចំរើនទាំងនេះផងដែរ ចាប់តាំងពីការបោះឆ្នោតឃុំ/សង្កាត់ ២០០២ មក ដែលក្នុងនោះ ៨៥ ភាគរយនៃអ្នកឆ្លើយតបយល់ថា ការអភិវឌ្ឍថ្នាក់មូលដ្ឋាននៅក្នុងសហគមន៏របស់ពួកគាត់មានការរីកចម្រើនច្រើនជាងមុន។

បន្ថែមពីលើនេះទៅទៀត ការសិក្សាអត្ថបទបរទេសមួយចំនួនបានបញ្ជាក់នូវគំនិតទុទិដ្ឋិនិយម ក៏ដូចជាក្តីសង្ឃឹម ចំពោះទំនាក់ទំនងរវាងអំពើពុករលួយ និងរដ្ឋាភិបាលបែបវិមជ្ឈការ[៨]។ *"...ស្តីពីវិមជ្ឈការនិងអំពើពុករលួយចង្អុលបង្ហាញតាមទិសដៅផ្សេង១គ្នា និងមិនបានផ្តល់នូវសេចក្តីសន្និដ្ឋានដែលមានលក្ខណៈច្បាស់លាស់នៅឡើយទេ"* (**Fjeldstad** ទំព័រ ១៧)។ ដូច្នេះ ការសិក្សាដ៏ពិស្តារមួយស្តីអំពី *"អន្តរទំនាក់ទំនង់ជាក់ស្តែងរវាងស្ថាប័នរដ្ឋ និងសង្គម"* គួរតែត្រូវរៀបរៀងឡើង ដើម្បីស្វែងរកមធ្យោបាយនានា ដែលអាចមានឥទ្ធិពលលើ និងបានប្រយោជន៏ដល់គ្នាទៅវិញទៅមក (**Ibid** ទំព័រ ២០)។ ការសិក្សានេះគួររួមបញ្ចូលទាំងរចនាសម្ព័ន្ធផ្លូវការ និងបណ្តាញក្រៅផ្លូវការនៃប្រព័ន្ធចៅហ្វាយនាយ និងការគាបសង្កត់ខាងសង្គមផងដែរ ដើម្បីកាត់បន្ថយបាននូវការកេងចំណេញលើអជ្ញាធរថ្នាក់មូលដ្ឋានពីសំណាក់អ្នកមានអំណាចមួយចំនួន។ ភស្តុតាងនានា ក៏បានបង្ហាញផងដែរថា រដ្ឋបាលឃុំ/សង្កាត់ជាច្រើនមិនសូវជាមានការរារាំងរឺរំខានពីសំណាក់អ្នកមានអំណាចប៉ុន្មានទេ[៩] (គំហើញខាងក្រោមក៏បញ្ជាក់ពីស្ថានភាពនេះផងដែរ)។ នេះអាចបញ្ជាក់បានថា រដ្ឋបាលថ្នាក់ឃុំ/សង្កាត់អាចជាចំណុចពិសេសមួយ។ ក៏ប៉ុន្តែ ដើម្បីដឹងថាពួកគាត់មានលក្ខណៈពិសេសយ៉ាងណា ការសិក្សាដ៏ល្អមួយទាក់ទងទៅនឹងប្រសិទ្ធភាពនៃទម្លាប់នៃការបង់កម្រៃក្រៅ-ផ្លូវការ និងមតិយោបល់ មួយចំនួនរបស់អ្នកផ្តល់ និងអ្នកប្រើប្រាស់សេវា គឺជាការចាំបាច់។

គោលបំណងនៃការសិក្សានេះគឺដើម្បីស្វែងយល់អំពី តើការផ្តល់សេវាថ្នាក់ឃុំ/សង្កាត់មានការប៉ះពាល់ដល់ជីវភាពប្រជាជន និងភាពពិតជាក់ស្តែងនៃចំណាយក្រៅផ្លូវការនាពេលបច្ចុប្បន្នមានកំរិត និងរបៀបណាខ្លះ ដើម្បីស្វែងរកអានុសាសន៏ល្អ១ សំរាប់ការផ្លាស់ប្តូរស្ថាប័ន។

---

[៦] Ninh et al. (2005) ទំព័រ ១៩ CSD (2005A), ទំព័រ ៤៥

[៧] សំរាប់លទ្ធផលប្រហាក់ប្រហែលនេះ សូមមើល Rusten et al ។ (2003) Ninh et al. (2005)

[៨] សូមមើល Fjeldstad, O ។២០០៣ ធនាគាពិភពលោក ២០០៥

[៩] សូមមើល Ninh et al. (2005)

### ប្រអប់ ១.១: "អំពើពុករលួយ" រឺ "ចំណាយក្រៅផ្លូវការ" ?

នៅក្នុងកថាខណ្ឌខាងលើពាក្យ "អំពើពុករលួយ" ត្រូវបានជំនួសដោយពាក្យ "កម្រៃក្រៅផ្លូវការ"។ ពាក្យ "កម្រៃក្រៅផ្លូវការ" ជាចំណាយដែលច្បាប់មិនតម្រូវអោយប្រជាជនបង់នៅពេលទទួលសេវាសាធារណៈ ដែលរួមមានដូចជា ថ្លៃទឹកតែ លុយសំរាប់ទឹកប៊ិច និងលុយរង្វាន់ ដែលទាំងនេះវាផ្ទុយនឹង "តម្លៃផ្លូវការ" ដែលត្រូវបានតំរូវដោយច្បាប់។ "កម្រៃក្រៅផ្លូវការ" គឺជា "អំពើពុករលួយ" ក្នុងន័យថា ជាការប្រើប្រាស់នូវអំណាចសាធារណៈសំដៅទទួលផលប្រយោជន៍បុគ្គល[១]។ ទោះជាយ៉ាងណាក្តី ដោយពិនិត្យមើលលើបញ្ហាធំៗមួយចំនួន --ប្រាក់បៀវត្សរ៍ទាប ជំនាញ និងសមត្ថភាពទាប-- ដែលប៉ះពាល់សេវាសាធារណៈនាពេលបច្ចុប្បន្នគ្រប់ជាន់ថ្នាក់ ជាពិសេសនៅកំរិតថ្នាក់ឃុំ/សង្កាត់ កម្រៃក្រៅផ្លូវការមិនអាចជៀសផុតនោះបានទេ។ លទ្ធផលនៃការសិក្សាបានបង្ហាញថា ធាតុពិតជាក់ស្តែងទាំងនេះត្រូវបានទទួលស្គាល់ដោយអ្នកប្រើប្រាស់ ក៏ដូចជាអ្នកផ្តល់សេវាផងដែរ។ ការប្រើពាក្យថា "អំពើពុករលួយ" ដែលមានអត្ថន័យខ្លាំងទាក់ទងនឹងភាពចង់មានចង់បាន និងការស្វែងរកលាភសក្ការៈដោយមិនចេះអៀនខ្មាសនោះ ហាក់មានភាពអយុត្តិធម៌ ចំពោះអ្នកដែលផ្តល់សេវាថ្នាក់មូលដ្ឋានដែលពុំទទួលបានប្រាក់បៀវត្សសមរម្យសម្រាប់ចិញ្ចឹមជីវិតបានផងនោះ។

ការសិក្សានេះបានពិនិត្យលើតែសេវាបីដែលផ្តល់នៅថ្នាក់ឃុំ/សង្កាត់ប៉ុណ្ណោះ គឺសេវាផ្តល់ដោយសាលាឃុំ/សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព។ មូលហេតុពីរសំរាប់ការផ្តោតតែទៅលើសេវាទាំងបីនេះគឺ:

១. ការសិក្សានឹងធ្វើការស្រាវជ្រាវទៅសេវាទាំងបីនេះ ដែលមាននៅពាសពេញទូទាំងប្រទេសទាំងមូលដោយមិនកម្រិតយកត្រឹមតែករណីសិក្សាពីរបីប៉ុណ្ណោះទេ។ ការកំណត់យកដែនសិក្សាដែលមានទំហំធំបែបនេះ ជាមូលហេតុដែលនាំឱ្យមានការជ្រើសយកមកសិក្សាជាក់លាក់នូវសេវាត្រឹមតែបីប៉ុណ្ណោះ។

២. ជាទូទៅ សេវារដ្ឋបាលនៅសាលាឃុំ/សង្កាត់ និងមណ្ឌលសុខភាព និងសេវានៅសាលាបឋមសិក្សាត្រូវបានចាត់ទុកថាជាសេវាសាធារណៈថ្នាក់មូលដ្ឋាន ដែលមានទំនាក់ទំនង និងច្រើនជាងគេទៅលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។

ទោះជាយ៉ាងនេះក៏ដោយ ស្ថាប័នដែលផ្តល់សេវាទាំងបីនេះមានភាពខុសគ្នា។ សាលាបឋមសិក្សា និង មណ្ឌលសុខាភាព មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមព្រឹក្សាឃុំ-សង្កាត់ទេ គឺមានតែសាលាឃុំប៉ុណ្ណោះ។ កម្មវិធីកំណែទំរង់វិស័យសាធារណៈ និងអភិបាលកិច្ចបែបប្រជាធិប្បតេយ្យរបស់វិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជាបានពិនិត្យមើលតួនាទី ដែលក្រុមព្រឹក្សាឃុំ/សង្កាត់អាចធ្វើបានទាក់ទងទៅនិងការផ្តល់សេវាឃុំ/សង្កាត់នេះ។ ចំពោះសេវានៅសាលាបឋមសិក្សា និងមណ្ឌលសុខភាព តួនាទីរបស់

ក្រុម ប្រឹក្សាឃុំ/សង្កាត់ ត្រូវបានវាយតម្លៃថាអាចធ្វើទៅបានត្រឹមតែការផ្តល់នូវជំនួយការ[១០] ការពិនិត្យមិនមែនផ្នែកបច្ចេកទេសនិងការវាយតម្លៃគុណភាពសេវាប៉ុណ្ណោះ។ ការត្រួតពិនិត្យខាងក្រោយនេះអាចរួមបញ្ចូលនូវសកម្មភាពទាំងឡាយដែលទាក់ទងនឹងចំណាយក្រៅផ្លូវការ។ ដូចគ្នានឹងសេវាមួយចំនួន ដែលធ្វើការស្រាវជ្រាវដោយវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា ដែលរួមមានការថែរក្សាផ្លូវលំ ការបោះចោលកាក់សំណល់រឹងជាដើម ក្រុមប្រឹក្សាឃុំ/សង្កាត់អាចដើរតួនាទីដោយផ្ទាល់ ដោយសារតែបច្ចេកវិទ្យានៅក្នុងការផ្តល់សេវានេះមានលក្ខណៈសាមញ្ញ និងសមាមាត្រទៅនឹងសមត្ថភាពរបស់ពួកគាត់។

ដូច្នេះ សេវារដ្ឋបាលរបស់សាលាឃុំ/សង្កាត់ទេ ដែលជាចំណុចចំបងនៃការសិក្សានេះ។ ឯសេវាពីរទៀតដែលត្រូវបានដាក់រួមបញ្ចូលនេះ គឺដោយសារតែសេវាទាំងពីរនេះអាចធ្វើជាចំនុចគោលក្នុងការប្រៀបធៀបសម្រួលដល់ការធ្វើបរិបទតាមមូលដ្ឋាន និងបង្កើនភវូនីយភាពសំរាប់ជាអនុសាសន៍ល្អក្នុងការអន្តរាគមន៍ជាគោលនយោបាយ។

## ១.២. សេវាឃុំ/សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព

តម្លៃសេវាសាធារណៈទាំងបីខាងលើ មានរចនាសម្ព័ន្ធខុសៗគ្នា។ ការបង្រៀននៅសាលាបឋមសិក្សាជាគោលការណ៍ គឺមិនយកប្រាក់ទេ។ សេវាខ្លះដែលផ្តល់ដោយរដ្ឋបាលឃុំ/សង្កាត់អាចតម្រូវឱ្យអ្នកប្រើប្រាស់បង់កម្រៃជាលក្ខណៈផ្លូវការ ប៉ុន្តែ ខ្លះទៀតទាមទារការបង់ជាលក្ខណៈក្រៅផ្លូវការ ។ ចំណែកឯមណ្ឌលសុខភាពវិញគឺតម្រូវឱ្យអ្នកប្រើប្រាស់បង់កម្រៃគ្រប់សេវាដែលផ្តល់ជូនជាផ្លូវការ។

### *១.២.១. សាលាឃុំ/សង្កាត់*

បន្ទាប់ពីដាក់បញ្ចូលនូវប្រព័ន្ធវិមជ្ឈការនៅក្នុងឆ្នាំ ២០០២ សាលាឃុំសង្កាត់ជាអ្នកទទួលខុសត្រូវលើភារកិច្ចទាក់ទងការគ្រប់គ្រងទូទៅ និងការអភិវឌ្ឍជីវភាពសហគមន៍តាមមូលដ្ឋាន[១១]។ តួនាទីផ្តល់សេវាទាំងនេះ រួមបញ្ចូលភារកិច្ចជាច្រើន ដូចជាវិស័យផ្លូវថ្នល់ក្នុងមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធតូចៗប្រព័ន្ធស្រោចស្រព អាគារសិក្សា និងការថែរក្សាទ្រព្យសម្បត្តិសាធារណៈ ប៉ុន្តែមិនបានរួមបញ្ចូលនូវវិស័យអប់រំនិងសុខភាពសាធារណៈទេ។

ក្រៅពីការទទួលខុសត្រូវខាងការគ្រប់គ្រងទូទៅនិងការអភិវឌ្ឍខាងលើ ការចុះអត្រានុគោលដ្ឋានស៊ីវិលគឺជាសេវាចាំបាច់តែមួយគត់ដែលក្រុមប្រឹក្សាឃុំអាចប្រមូលបាននូវចំណូលផ្លូវការផ្ទាល់ពីប្រជាជន ដែល

---

[១០] ការប្រមូលផ្តុំសំរាប់ការចាក់វ៉ាក់សាំងការពារ និងការចុះឈ្មោះកុមារចូលរៀន

[១១] ការទទួលខុសត្រូវទាំងនេះ រួមបញ្ចូលសុវត្ថិភាពមូលដ្ឋាន សណ្តាប់ធ្នាប់សាធារណៈ ការការពារបរិស្ថាន និងធនធានធម្មជាតិ ការជំរុញអោយមាន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការងារទូទៅរបស់ឃុំ និងការផ្តល់សេវាសាធារណៈចាំបាច់ៈ មាត្រាទី ៦១ នៃអនុក្រិត្យស្តីពីវិមជ្ឈការអំណាច ការងារ និងតួនាទីចំពោះក្រុមព្រឹក្សាឃុំ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ២០០៥។

ប្រើប្រាស់សេវា។ ថ្លៃសេវាដែលប្រមូលពីសេវាចុះបញ្ជីអត្រានុគោលដ្ឋាន គឺជាប្រភពចំណូលផ្ទាល់របស់ឃុំ/សង្កាត់យ៉ាងសំខាន់។ ក្របខណ្ឌច្បាប់បច្ចុប្បន្ន មិនបានកំនត់អោយបានច្បាស់ពីថ្លៃសេវានៅមូលដ្ឋានណាខ្លះ ដែលសាលាឃុំអាចប្រមូលបាន[១២] នៅឡើយទេ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តន៏ជាក់ស្តែង សាលាឃុំ/សង្កាត់ផ្តល់សេវារដ្ឋបាលដល់ប្រជាជននៅតាមមូលដ្ឋានជាថ្នូរនឹងកម្រៃក្រៅផ្លូវការមួយចំនួន បើទោះបីជាសេវាទាំងនោះមិនត្រូវបានច្បាប់ រឺបទបញ្ញាតិកំនត់អោយបានច្បាស់ក៏ដោយ។ ជាទូទៅ ភាពមិនច្បាស់លាស់ទាំងនេះនាំទៅដល់ការយល់ច្រឡំ និងការយល់ដឹងទាបពីចំណាយផ្លូវការសំរាប់សេវា ដោយបង្កើតអោយមានបរិយាកាសមួយ ដែលអនុគ្រោះដល់បង់ចំណាយក្រៅផ្លូវការ។ នៅក្នុងការសិក្សានេះ ចំណាយក្រៅផ្លូវការរួមបញ្ចូលនូវការបង់ចំណាយគ្រប់ប្រភេទ ដែលលើសពីការចំណាយផ្លូវការទៅលើសេវាចាំបាច់ ក៏ដូចជាការបង់ចំណាយសរុបសំរាប់សេវាជាក់ស្តែងផ្សេងៗដែលមិនតម្រូវឱ្យបង់។

### ***១.២.២. សេវាបឋមសិក្សា***

ការអភិវឌ្ឍប្រកបដោយចិរភាព កំនត់និយមន័យដោយសូចនាករណ៏បី: កំណើនសេដ្ឋកិច្ច អាយុរស់នៅជាមធ្យម និងអត្រាអ្នកចេះអក្សរ (Amartya SEN 1998)។ ជាមួយនឹងសូចនាករណ៏ទាំងនេះ ការអភិវឌ្ឍធនធានមនុស្សត្រូវបានចាត់ទុកថាជាគន្លឹះសំខាន់មួយសំរាប់ការអភិវឌ្ឍសុខុមាលភាពសង្គម។

គ្រួសារនៅតាមជនបទ ជួបប្រទះបញ្ហាលំបាកជាច្រើនក្នុងការបញ្ជូនកូនទៅសាលា ដោយសារតែពួកគេមិនមានលទ្ធភាពបង់ថ្លៃសាលា និងនៅដាច់ឆ្ងាយពីសាលា។ ដោយទទួលស្គាល់ពីបញ្ហានេះរាជរដ្ឋាភិបាលកម្ពុជានៅពេលថ្មីៗ បានបង្កើតផែនការយុទ្ធសាស្រ្តជាច្រើន ដូចជា ការអប់រំសំរាប់ជនគ្រប់រូបការពង្រីកការអប់រំមូលដ្ឋានសំរាប់ជនគ្រប់រូប កម្មវិធីគាំពារវិស័យអប់រំ និងកម្មវិធីសកម្មភាពជាអទិភាព ដើម្បីធានាអោយកុមារដែលមានអាយុគ្រប់ចូលរៀនជាពិសេសនៅជនបទ មានលទ្ធភាពទទួលបានការអប់រំមូលដ្ឋានដោយមិនមានបង់ប្រាក់។

ក្រៅពីកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាច្រើនក៏បានរួមចំណែកនៅក្នុងការធ្វើអោយប្រសើរឡើងនូវការអប់រំមូលដ្ឋាន តាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសំភារៈសិក្សា ហើយក៏រួមចំណែកក្នុងការលាតត្រដាងពីឧបសគ្គជាសារវន្តរបស់កុមារក្រីក្រ ដែលរារាំងលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋាន។ ការវាយតម្លៃអំពើពុករលួយរបស់ ម.អ.ស ឆ្នាំ ២០០៥ បានរកឃើញថា អំពើពុករលួយនៅក្នុងវិស័យអប់រំសាធារណៈ មានចំនួន ៣៧ លានដុល្លាក្នុងមួយឆ្នាំ។ ចំនួននេះមានប្រហែល ៥៥ ភាគរយ នៃ

---

[១២] យោងតាមក្រសួងមហាផ្ទៃ សេវាចាំបាច់ និងថ្លៃសេវាកំពុងត្រូវបានរៀបចំនៅក្នុងដំណើរពង្រៀងច្បាប់អង្គភាពស្តីអំពីវិមជ្ឈការ និងវិសហមជ្ឈការ នៃអនុរដ្ឋាបាលថ្នាក់ជាតិ

អំពើពុករលួយសរុបក្នុងសេវាសាធារណៈ។ ទោះជាយ៉ាងណាក្តី លទ្ធផលរកឃើញនេះមិនបានកំនត់ភាពខុសគ្នារវាងការអប់រំកំរិតបឋមសិក្សា វិទ្យាល័យ និងឧត្តមសិក្សានោះទេ។ ចំណែកឯការសិក្សានេះ គឺផ្តោតជាសំខាន់ទៅលើតែសាលាបឋមសិក្សាតែប៉ុណ្ណោះ ដូច្នេះការលទ្ធផលនៃការសិក្សានេះ និងលទ្ធផលរបស់ ម.អ.ស មិនអាចធ្វើការប្រៀបធៀបដោយផ្ទាល់បានទេ។

ការសិក្សា "ការស្ទាប់ស្ទង់ពីការតាមដានចំណាយសាធារណៈឆ្នាំ ២០០៥" របស់ធនាគាពិភពលោក បង្ហាញថា នាយកសាលាប្រហែល ៦៤ ភាគរយ បានរាយការណ៍ថា ពួកគាត់បានបង់កម្រៃសម្របសម្រួល (បង់ជាលក្ខណៈក្រៅផ្លូវការ) ដល់មន្ត្រីមន្ទីរអប់រំស្រុក ជាថ្នូរនិងការចំណាយមូលនិធិកម្មវិធីសកម្មភាពអទិភាពនានា។ ទោះបីជាការកម្រៃសេវានេះមានចំនួនតិចតួចក៏ដោយ (ពី១០០០ ទៅ ៤០០០រៀល)ក៏វាជា ឧបសគ្គចំបងមួយរារាំងដល់ការសំរេចបាននូវប្រសិទ្ធភាពល្អប្រសើរនៃប្រព័ន្ធអប់រំកំរិតបឋមសិក្សាទាំងមូល។

ជារួម ការស្រាវជ្រាវទៅលើវិស័យអប់រំសាធារណៈមានចំនួយច្រើន ប៉ុន្តែភាគច្រើនគឺគោលដៅទាំងនៃការស្រាវជ្រាវទាំងនោះមានភាពទូលំទូលាយពេក។ ដូច្នេះ ការសិក្សានេះនឹងព្យាយាមស្វែងរកលទ្ធផលជាក់លាក់មួយដែលផ្តោតសំខាន់ចំពោះ លក្ខណះ បុព្វហេតុ និង កំរិតនៃចំណាយក្រៅផ្លូវការ នៅក្នុងការអប់រំបឋមសិក្សា។

### ១.២.៣. សេវាមណ្ឌលសុខភាព

សុខុមាលភាពប្រជាជនត្រូវបានចាត់ទុកជាទូទៅថាជាសូចនាករទីពីរ សំរាប់ការអភិវឌ្ឍ។ ប្រទេសកម្ពុជាក៏ដូចប្រទេសកំពុងអភិវឌ្ឍដ៏ទៃទៀត ត្រូវប្រឈមមុខនឹងបញ្ហាសុខភាពរបស់ប្រជាជនជាច្រើន ដែលមានឥទ្ធិពលលើអាយុរស់នៅជាមធ្យមរបស់ពួកគាត់។ ទោះបីជាសេវាសុខភាពរបស់ប្រទេសកម្ពុជាមានការរីកចំរើនក្នុងរយះពេលទស្សវត្សចុងក្រោយនេះក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនជាពិសេសរស់នៅជនបទនៅតែមានការពិបាកក្នុងការទទួលបាននូវសេវាសុខភាពមូលដ្ឋាននៅឡើយ ដោយសារតែមិនមានមណ្ឌលសុខភាព គ្រប់គ្រាន់នៅតាមឃុំនីមួយៗ។

ចំណាយក្រៅផ្លូវការ និងភាពលំអៀងពីសំណាក់បុគ្គលិកមណ្ឌលសុខភាព ជាឧបសគ្គដ៏ចំបងរារាំងប្រជាជនក្រីក្រក្នុងការទទួលបានសេវាថែទាំសុខភាព។ ការវាយតម្លៃអំពើពុករលួយរបស់ ម.អ.ស ឆ្នាំ ២០០៥ បានរកឃើញថា មានសំណូកនៅក្នុងសុខភាពសាធារណៈគ្រប់កំរិតមានចំនួនប្រហែល ១.៣ លានដុល្លាអាមេរិក។ ចំណែកឯលទ្ធផលសិក្សាដែលនឹងបង្ហាញក្នុងផ្នែកបន្ទាប់នេះ គឺកម្រិតត្រឹមតែចំណាយក្រៅផ្លូវការ ដែលមាននៅតាមមណ្ឌលសុខភាពតែប៉ុណ្ណោះ។

## ១.៣. ឧសស្រនះរបស់អ្នកប្រើប្រាស់ចំពោះប្រសិទ្ធភាពសេវា

មតិវាយតំលៃពីគុណភាពសេវា រីតរិយាបទអ្នកផ្តល់សេវា និងមតិវាយតំលៃចំណាយក្រៅផ្លូវការ មានការជាប់ទាក់ទងគ្នាយ៉ាងស្អិតរមួត។ ទំនាក់ទំនងនេះ គឺបង្កើតឡើងដោយទ្រឹស្តីជាច្រើន ដែលទាក់ទងនឹងអំពើពុករលួយ[១៣] ប៉ុន្តែវាមានភាពសមស្របទៅនឹងទិន្នន័យជាក់ស្តែងនៅកម្ពុជា។

ការស្ទង់មតិរបស់ ម.អ.ស បង្ហាញថា ទំនាក់ទំនងយ៉ាងជិតស្អិតរវាងគុណភាពសេវា និងចំណាត់ថ្នាក់ សុច្ចរិតភាពរបស់ស្ថាប័ន។ ម.អ.ស ក៏បានបង្ហាញផងដែរថាចំណាត់ថ្នាក់សុច្ចរិតភាព ត្រូវបានប្រែប្រួលទៅតាមផលធៀបរវាងចំណាយផ្លូវការ និងក្រៅផ្លូវការ[១៤] ជាមួយនឹងចំណាត់ថ្នាក់គុណភាពនៃសេវា។ ទិន្នន័យទាំងនេះបង្ហាញថា បុព្វហេតុដើមគឺមានទិសដៅពីការអនុវត្តទៅភាពសុច្ចរិតជាជាងតាមវិធីផ្សេងទៀត។ ដូច្នេះ ដើម្បីស្វែងយល់ពីអត្ថន័យនៃរបៀប ដែលអ្នកប្រើប្រាស់សេវានៅក្នុងប្រទេសកម្ពុជាបង់ចំណាយក្រៅផ្លូវការសំរាប់សេវាជាកលាក់ណាមួយអោយបានត្រឹមត្រូវ វាសំខាន់ណាស់ក្នុងការមើលការចំណាយទាំងនោះ ជាមួយនឹងគុណភាពនៃការផ្តល់សេវាទាំងនោះ។

តារាងខាងក្រោមជាចម្លើយដែលបំពេញដោយអ្នកប្រើប្រាស់សេវាចំនួន ៨៥៩ នាក់ ចំពោះសំនួរអំពីគុណភាពប្រតិបត្តិសេវាទាំងបីខាងលើ :

**តារាង ១.១: ការវាយតម្លៃលើការប្រតិបត្តិសេវាថ្នាក់មូលដ្ឋាន (គិតជាភាគរយ)**

| | សាលាឃុំ | សាលាបឋមសិក្សា | មណ្ឌលសុខភាព |
|---|---|---|---|
| **មានប្រសិទ្ធភាព** | **៥៥%** | **៦៣%** | **៤៩%** |
| **ពេលខ្លះមានប្រសិទ្ធភាព ពេលខ្លះមិនមាន** | ៣៦% | ៣២% | ៤១% |
| **មិនមានប្រសិទ្ធភាព** | ៨% | ៥% | ៧% |
| **គ្មានចំលើយ** | ១% | 0% | ៣% |
| **សរុបអ្នកឆ្លើយតប** | ៨៥៩ | ៨៥៩ | ៨៥៩ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

អ្នកប្រើប្រាស់សេវាជាច្រើន ត្រូវបានគេសាកសួរពីមតិយោបល់ទៅលើសេវាទាំងឡាយដែលបានទទួល។ តារាង១.១ បង្ហាញថា ការវាយតម្លៃ[១៥] នៃគុណភាពសេវាដែលគេផ្តល់នោះ គឺមិនមានភាពខុសប្លែកគ្នាខ្លាំងរវាងសេវាទាំងបីនោះទេ ប៉ុន្តែមានភស្តុតាងនៃចំណាត់ថ្នាក់មួយដែលអាចវាយតំលៃថា សេវា

---

[១៣] សូមមើល Lambsdorff,J ២00១

[១៤] ប្រសិនបើមួយផ្នែកតូចនៃចំណាយសរុបដែលទាមទារគឺជាចំណាយផ្លូវការ សេវាកម្មទំនងជាត្រូវបានចាត់ទុកថាជាអំពើពុករលួយ

១៥ ប្រសិនបើ យើងធ្វើរបាយការណ៍លទ្ធផលទៅកាន់អ្នកប្រើប្រាស់សេវាទាំងអស់, នេះមានន័យថា វាមិនមានភាពខុសគ្នាខ្លាំងទេរវាងលទ្ធផលនៅឃុំតាមទីរួមខេត្ត, តាមទីរួមស្រុក ក៏ដូចជាតាមជនបទ។ ពេលដែលលទ្ធផលទាំងនោះ ខុសគ្នាខ្លាំងរវាងប្រភេទឃុំទាំង អស់នោះ យើងនឹងធ្វើរបាយការណ៍អោយពួកគាត់ ដាច់ដោយឡែកពីគ្នា។

សាលាបឋមសិក្សាគឺល្អជាងគេ បន្ទាប់មកទៀតគឺសេវាថ្នាក់ឃុំ/សង្កាត់ និងចុងក្រោយគឺសេវាមណ្ឌលសុខភាព។ នេះគឺដូចគ្នាទៅនឹងលំដាប់ថ្នាក់ដែលត្រូវបានបង្ហាញនៅក្នុងកំរិតគុណភាពសេវា ម.អ.ស[១៦] ផងដែរ។

តាមការសង្កេតក្នុងពេលពិភាក្សាជាក្រុមបានបង្ហាញថា លទ្ធផលជាវិជ្ជមានខាងលើនៃការបំរើសេវានេះ គឺឋិតនៅក្នុងបរិបទមួយ ដែលអ្នកផ្តល់សេវាបានប្រតិបត្តិនូវតួនាទីរបស់ខ្លួនក្រោមលក្ខខណ្ឌការងារដ៏លំបាក រួមជាមួយនឹងភាពមិនគ្រប់គ្រាន់នៃប្រាក់ខែ។ សមាជិកម្នាក់នៅក្នុងការពិភាក្សាជាក្រុមបានលើកឡើងថា *"ខ្ញុំគិតថាសេវាដែលពួកគាត់ផ្តល់ គឺល្អគ្រប់គ្រាន់ហើយ បើធៀបនឹងប្រាក់ខែយ៉ាងទាបរបស់ពួកគាត់។ ប្រសិនបើខ្ញុំជារូបគាត់វិញ ខ្ញុំមិនប្រាកដថាតើខ្ញុំនឹងអាចទ្រាំធ្វើការ រឺក៏ផ្តល់នូវគុណភាពសេវាដូចគ្នាជាមួយនឹងប្រាក់ទាបដូចនេះបានរឺទេ"*។

អាំងឌីកាទ័រមួយទៀតដែលបញ្ជាក់ពីគុណភាពនៃសេវាផងដែរគឺ ការយល់ដឹងអំពីនីតិវិធីក្នុងការប្តឹងតវ៉ា (មានតែសាលាឃុំទេដែលមាន "ហិបគណនីភាព" មួយច្បាស់លាស់សំរាប់ការតវ៉ា រឺសំនួរ) រឺការដែលអាចធ្វើការតវ៉ាបាន (ការតវ៉ាផ្ទាល់មាត់ទៅកាន់នាយកសាលា រឺប្រធានមណ្ឌលសុខភាព)។ តារាង ១.២ បង្ហាញពីភាពយល់ដឹងដែលមានកំរិតទៅលើសេវាទាំងនោះ ជាមួយនឹងចំណាត់ថ្នាក់ដូចដែលបានវាយតម្លៃលើប្រសិទ្ធភាពការបំរើសេវា : មានការយល់ដឹងច្រើនពីលទ្ធភាពនៃការធ្វើការតវ៉ាចំពោះសេវាសាលាបឋមសិក្សា ចំណែកឯសេវាមណ្ឌលសុខភាពនោះមានតិចតួចជាងគេ។

**តារាង ១.២: ការយល់ដឹងពីនីតិវិធីនៃការតវ៉ា**

| | ការិយាល័យឃុំ/សង្កាត់ | សាលាបឋមសិក្សា | មណ្ឌលសុខភាព |
|---|---|---|---|
| **បាទ-ចាស** | ២៩% | ៣៥% | ២២% |
| **ទេ** | ៦៩% | ៦៣% | ៧៣% |
| **គ្មានចំលើយ** | ២% | ២% | ៥% |
| **ការឆ្លើយតបសរុប** | ៨៥៩ | ៨៥៩ | ៨៥៩ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

សំនួរបន្តបន្ទាប់មួយចំនួន ត្រូវបានសាកសួរទៅកាន់អ្នកដែលដឹងពីលទ្ធភាពដើម្បីធ្វើការតវ៉ាបាន។ លទ្ធផលបានបង្ហាញថា ១ ភាគ ៣ នៃអ្នកដែលដឹងពីនីតិវិធីនៃការតវ៉ាចំពោះសេវាឃុំ បានប្រើប្រាស់នីតិវិធីទាំងនោះ និងមានតែ ១ ភាគ ៤ ប៉ុណ្ណោះ នៃអ្នកដែលដឹងពីវិធីតវ៉ានឹងសេវាសាលាបឋមសិក្សា រឺមណ្ឌលសុខភាពបានប្រើប្រាស់នូវនីតិវិធីទាំងនោះ។ ក្នុងចំណោមអ្នកដែលប្រើប្រាស់នូវវិធីតវ៉ានោះ អ្នកដែលតវ៉ាទៅសាលាបឋមសិក្សា រឺមណ្ឌលសុខភាព (៤ នាក់ ក្នុងចំណោម ៥ នាក់) ទទួលបានលលទ្ធផលពេញចិត្តជាងអ្នក ដែលធ្វើការតវ៉ាទៅសាលាឃុំ/សង្កាត់ (២ នាក់ ក្នុងចំណោម ៣ នាក់)។ បើក្រឡេកមើលលើមូល

---

[១៦] CSD (2005), p.26

ហេតុដែលនាំអោយប្រជាជនមិនធ្វើការតវ៉ាវិញ សាលាបឋមសិក្សាមានភាពលេចធ្លោជាងគេ ដោយមានតែអ្នកប្រើសេវា ១ នាក់ប៉ុណ្ណោះ ក្នុងចំណោម ១០ នាក់ ដែលបានលើកឡើងថា "មិនហ៊ានធ្វើការតវ៉ា" បើប្រៀបធៀបទៅ សេវានៅសាលាឃុំ/សង្កាត់ និងមណ្ឌលសុខភាព ដែលមានអ្នកលើកឡើងដូច នេះមានចំនួន ១ នាក់ ក្នុងចំណោម ៥ នាក់។

ចំពោះសេវាសាលាឃុំ ទស្សនៈវិស័យនៃការប្រតិបត្តិពីរបន្ថែមត្រូវបានរកឃើញគឺ តម្លាភាព និងគណនេយ្យភាព ដែលទាក់ទងនឹងរយៈពេល និងការលំបាកទទួលបាននូវសេវាដែលខ្លួនត្រូវការ។

បច្ចុប្បន្ននេះ រយៈពេលផ្តល់សេវា មិនទាន់ត្រូវបានប្រកាសជាទូទៅនៅឡើយទេ ដែលជាទូទៅមន្ត្រីឃុំជាអ្នកកំណត់ និងអាស្រ័យលើពេលវេលាទំនេររបស់អង្គាធរឃុំផ្ទាល់តែម្តង។ យោងតាមការសិក្សាបង្ហាញថា មានអ្នកឆ្លើយតប ៤២ ភាគរយ តែងតែទទួលបានការប្រាប់ជាមុនពីរយៈពេលដែលត្រូវមកទទួលសេវា ខណៈដែល ៣៥ ភាគរយ ទៀតបង្ហាញថា មានពេលខ្លះពួកគេបានទទួលការជូនដំណឹងដែរ។ ចំណែកឯ ២៣ ភាគរយ ទៀតបានតវ៉ាថា ពួកគេមិនដែលបានដឹងជាមុននោះទេ។

**រូបភាព ១.១: តើការិយាល័យឃុំ មានប្រាប់អ្នកជាមុនពីរយៈពេល ត្រូវមកទទួលសេវាដែលបានស្នើសុំនោះទេ?**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

ក្នុងចំណោមអ្នកដែលបានដឹងជាមុននោះ មានប្រមាណពាក់កណ្តាលបានទទួលស្គាល់ថា ការិយាល័យឃុំផ្តល់សេវាដែលបានសុំនោះទាន់ពេលវេលា ប៉ុន្តែមានពាក់កណ្តាលទៀតបានរិះគន់ថា ពួកគេទទួលយឺតជាងការសន្យា។ ជាទូទៅរយៈពេលដែលយឺតនោះមានក្នុងចន្លោះពី ៣ ទៅ ៥ ថ្ងៃ។

អ្នកប្រើប្រាស់សេវា ក៏ត្រូវបានសាកសួរផងដែរថា តើអ្នកហ៊ានចំណាយបន្ថែមទេ បើចង់បានសេវាឆាប់? ក្នុងចំណោម ៤ នាក់ មានអ្នកប្រើប្រាស់សេវា ៣ នាក់ អះអាងថា ហ៊ានបង់ដើម្បីបានសេវាលឿន។ លទ្ធផលពីការសិក្សាបង្ហាញថាចំណាយក្រៅផ្លូវការ គឺជាការអនុវត្តមួយដែលពួកគាត់ទទួលយក។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នេះមិនមានន័យថា ប្រជាពលរដ្ឋពេញចិត្តនឹងបង់ចំណាយក្រៅផ្លូវការនោះទេ ប៉ុន្តែពួកគាត់ចង់បានសេវាដែលលឿន និងសាមញ្ញជាងនេះ ជាជាងរងចាំសំរាប់ថ្ងៃថោកជាមួយនឹងរយៈពេលយូរ។

**រូបភាព ១.២: គ្រួសារដែលយល់ព្រមបង់ចំណាយបន្ថែមដើម្បីទទួលបានសេវាឆាប់រហ័ស**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា-សីហា ឆ្នាំ ២០០៦*

ទាក់ទងសំនួរដែលសាកសួរពីកំរិតនៃការលំបាក និងងាយស្រួលក្នុងការស្នើសុំសេវាពីការិយាល័យឃុំក្នុងចំណោមអ្នកប្រើប្រាស់សេវា ៣ នាក់ មាន ១ នាក់លើកឡើងថា មានការពិបាកនឹងទទួលណាស់។

**រូបភាព ១.៣: តើមានការលំបាក ឬងាយស្រួលកំរិតណា ដើម្បីបានសេវាពីការិយាល័យឃុំ?**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

## ១.៤. សេវាសាធារណៈមូលដ្ឋាន និងចំណាត់ថ្នាក់លើភាពស្មោះត្រង់របស់មន្ត្រី

នៅចុងបញ្ចប់នៃបញ្ជីសំនួរដែលបំពេញដោយអ្នកប្រើប្រាស់សេវា អំពីកិត្តិនៃភាពស្មោះត្រង់របស់មន្ត្រីបម្រើការក្នុងសេវាថ្នាក់មូលដ្ឋានទាំងបី ពាក់ព័ន្ធទៅលើការយកកំរៃ និងគុណភាពនៃការផ្ដល់សេវា។ តារាង ១.៣ ខាងក្រោមនឹងបង្ហាញយ៉ាងច្បាស់ពីលំដាប់នៃចំណាត់ថ្នាក់មួយ ក្នុងនោះសេវាអប់រំថ្នាក់បឋមសិក្សាបានជាប់ចំណាត់ថ្នាក់ល្អបំផុត ឯការិយាល័យឃុំទទួលបានចំណាត់ថ្នាក់អន់បំផុត។

ចំណាត់ថ្នាក់នេះ បង្ហាញថា (ដោយមានទំនាក់ទំនងជាមួយនឹងការរកឃើញរបស់ ម.អ.ស ឆ្នាំ ២០០៥) សមាមាត្រនៃតម្លៃផ្លូវការធៀបនឹងតម្លៃក្រៅផ្លូវការសំរាប់អ្នកផ្ដល់សេវាប្រភេទណាមួយ គឺជាកត្តាកំណត់យ៉ាងសំខាន់ដល់ភាពស្មោះត្រង់របស់អ្នកផ្ដល់សេវានោះ។ ក្នុងការកំណត់ចំណាត់ថ្នាក់នេះ ក្រៅពីគុណភាពសេវា គឺនៅមានកត្តាកំណត់ជាច្រើនទៀត។ ដូចក្នុងករណីសេវាមណ្ឌលសុខភាពចំនុចខ្លះ មានប្រសិទ្ធភាពតិចជាងសេវារបស់ការិយាល័យឃុំ(សូមមើលតារាង ១.១) ប៉ុន្តែតារាងតម្លៃរបស់ការិយាល័យឃុំមានតម្លាភាព តិចជាងនៅមណ្ឌលសុខភាពទៅវិញ។ ម្យ៉ាងទៀត ទំនុកចិត្តលើមន្ត្រីឃុំ ហាក់ដូចជាមានកិត្តិទាបជាងឆ្ងាយ បើធៀបទៅគ្រូបង្រៀននៅថ្នាក់បឋមសិក្សា និងបុគ្គលិកនៅមណ្ឌលសុខភាព។ បើទោះជាមិនមានទិន្នន័យណាដែលអាចប្រៀបធៀបបានសំរាប់សេវាពីរដទៃទៀតក៏ដោយចំនួន ១/៣ នៃអ្នកប្រើប្រាស់សេវាបានរាយការណ៍ថា លទ្ធភាពទទួលបានសេវាពីការិយាល័យឃុំគឺ "ពិបាក" (សូមមើលរូបភាព ១.៣) សូម្បីតែព័ត៌មានដែលផ្ដល់ (ដូចជាព័ត៌មានដែលទាក់ទងនឹងពេលកំណត់ទទួលសេវា) ក៏មិនទៀតទាត់ដែរ (ដូចបានបង្ហាញខាងលើ) ចំណែកឯដំណោះស្រាយចំពោះការតវ៉ានានា ក៏បំពេញចិត្តបានតិចជាងសេវាពីរទៀតដែរ (ដូចបានបង្ហាញខាងលើ) ។

**តារាង ១.៣: ការវាយតម្លៃទៅលើភាពស្មោះត្រង់របស់មន្ត្រីផ្ដល់សេវា**

| | ខ្ពស់ | មធ្យម | ទាប | សរុប* |
|---|---|---|---|---|
| បឋមសិក្សា | **៥៧%** | ៣១% | ១២% | ៨៥១ |
| មណ្ឌលសុខភាព | ២៣% | **៥២%** | ២៥% | ៨៤៥ |
| ការិយាល័យឃុំ | ១៨% | ២៣% | **៥៩%** | ៨៥២ |

* *អ្នកដែលមិនបានឆ្លើយនឹងសំនួរនេះមិនត្រូវបានបូកបញ្ចូលទេ*

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

កត្តាផ្សេងទៀតដែលបង្ហាញពីភាពខុសគ្នារវាងអ្នកផ្ដល់សេវានេះ គឺថាពេលខ្លះដើម្បីទទួលបានសេវាពីការិយាល័យឃុំ ពួកគាត់ត្រូវចំណាយតាមរយៈអ្នករត់ការ។

### រូបភាព ១.៤: ការបង់ចំណាយក្រៅផ្លូវការនៅការិយាល័យឃុំ តាមរយៈអ្នករត់ការ




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

បើយោងតាមការស្រាវជ្រាវស្តីពីអំពើពុករលួយរបស់ ម.អ.ស ឃើញថា ការប្រើអ្នករត់ការគឺមានភាពញឹកញាប់ ដោយក្នុងនោះសកម្មភាពជាអំណោយមាន ១៧ ភាគរយ និងជាសំណូក ៣៦ ភាគរយ ដែលត្រូវ បានសម្របសម្រួលដោយអ្នករត់ការ ។ ការរកឃើញនេះមិនទាន់បានទទួលការចាប់អារម្មណ៍ខ្លាំងខ្លានោះ ទេ ហើយការអនុវត្តជាក់ស្តែងក៏មិនទាន់យល់ច្បាស់ដែរ។ ទោះយ៉ាងណា តាមការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជនរបស់ វ.ស.ក នៅឆ្នាំ ២០០៦ បានផ្តល់បានបង្ហាញយ៉ាងច្បាស់ថាមានទំនាក់ទំនងដោយផ្ទាល់មួយរវាងបែបបទជាផ្លូវការ និងការប្រើប្រាស់អ្នករត់ការ។ តាមការសិក្សាបង្ហាញថា មានសហគ្រាស ខ្នាតតូចប្រមាណ ៧ ភាគរយ បានប្រើប្រាស់អ្នករត់ការ បើធៀបទៅនឹងសហគ្រាសខាតធំមានដល់ទៅ ៦៤ ភាគរយ។ តាមទិន្នន័យរបស់យើងបង្ហាញថា ការចំណាយក្រៅផ្លូវការនៅសាលាបឋមសិក្សាគឺមិនដែលមាន អ្នករត់ការជួយសម្របសម្រួលនោះទេ។

ក្នុងចំណោមសេវាទាំងបី សេវាមណ្ឌលសុខភាពត្រូវបានកំណត់ជាគោលដៅនៃការសាកល្បងលើប្រព័ន្ធហិរញ្ញវត្ថុ ក្នុងគោលបំណងរួមបញ្ចូលគ្នាលើការកែលំអតរិយាបទអ្នកផ្តល់សេវា លើកកំពស់លទ្ធភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងបង្កើនតម្លាភាព និងគណនេយ្យភាព ដោយរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងក្នុងការលប់បំបាត់ប្រព័ន្ធនៃតម្លៃក្រៅផ្លូវការ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតឱ្យមានមូលនិធិសមភាពសុខភាព និងការសាកល្បងផ្សេងៗទៀត (ឧទាហរណ៍ ការគាំពារសុខភាពតាមសហគមន៍) ជាផ្នែកនៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ ។

# ជំពូកទី ២

# ការយល់ដឹងរបស់ប្រជាជន និងមូលហេតុនៃកម្រៃក្រៅផ្លូវការ

កង្វះខាតនូវព័ត៌មានអំពីតម្លៃផ្លូវការនៃសេវាសាធារណៈ នាំឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំ និងមានភាពស្រពិចស្រពិលអំពីតម្លៃពិតប្រាកដ ហើយឈានទៅរកចំណាយក្រៅផ្លូវការដើម្បីទទួលបានសេវាទាំងនោះ។ ទោះបីយ៉ាងណា របបគំហើញនៃការស្រាវជ្រាវនេះបានបង្ហាញថា ការយល់ដឹងរបស់ប្រជាជន ចំពោះតម្លៃផ្លូវការគឺជាលក្ខខណ្ឌមួយចាំបាច់ ក៏ប៉ុន្តែ មិនគ្រប់គ្រាន់សម្រាប់បញ្ចៀសមិនឱ្យមានការបង់ប្រាក់ក្រៅផ្លូវការបានទាំងស្រុងឡើយ។ ជំពូកនេះនឹងលើកយកមកបង្ហាញនៅមូលហេតុជាក់ស្តែងមួយចំនួនដែលនាំឱ្យមានការបង់ប្រាក់ក្រៅផ្លូវការ ព្រមទាំងធ្វើការវិភាគទៅលើការយល់ដឹងរបស់អ្នកប្រើប្រាស់ទៅលើបញ្ហាទាំងនេះ នៅពេលដែលពួកគាត់បង់ចំណាយសម្រាប់សេវាសាធារណៈថ្នាក់មូលដ្ឋាន។

## ២.១. ការយល់ដឹងរបស់អ្នកប្រើប្រាស់ចំពោះកម្រៃក្រៅផ្លូវការ

វិសាលភាពនៃការផ្តល់ព័ត៌មានរបស់អ្នកផ្តល់សេវាទៅដល់អ្នកប្រើប្រាស់អំពីតម្លៃ ដែលត្រូវបង់សម្រាប់សេវាសាធារណៈខុសៗគ្នា អាចនិយាយបានថា ជាកត្តាចង្អុលបង្ហាញអំពីប្រសិទ្ធភាព និងគុណភាពនៃសេវាទាំងនោះ។

តាមការសង្កេតជាក់ស្តែង សេវាទាំងបីមិនអាចធ្វើការប្រៀបធៀបដោយផ្ទាល់បានទេ ដោយសារតែភាពខុសគ្នាទៅលើវិសាលភាពនៃតម្លៃផ្លូវការរបស់វា។ ក្នុងករណីសាលាបឋមសិក្សា បើទោះបីជារដ្ឋាភិបាលបានកំណត់ជាផ្លូវការមិនឱ្យមានការយកកម្រៃណាមួយពីសិស្សក៏ដោយ ក៏នៅតែមានការបង់ប្រាក់ក្រៅផ្លូវការពីសំណាក់ប្រជាពលរដ្ឋដែរ។ ដូចដែលមានបង្ហាញក្នុងរូបភាព ២.១ ខាងក្រោម ក្នុងចំណោមប្រជាជន ១៩៦ នាក់ ដែលបានចំណាយប្រាក់សម្រាប់ការអប់រំថ្នាក់បឋមសិក្សា (ព័ត៌មានលំអិតនឹងមានបង្ហាញជាបន្តបន្ទាប់) មានតែ ៥៩ ភាគរយប៉ុណ្ណោះ ដែលយល់ច្បាស់ថានោះជាការចំណាយក្រៅផ្លូវការ។ រីឯអ្នកផ្សេងទៀតគិតថា ទាំងនោះជាចំណាយផ្លូវការ ឬអាចមានទាំងផ្លូវការ និងក្រៅផ្លូវការ ឬក៏មិនដឹងតែម្តង។

### រូបភាព ២.១: ការយល់ដឹងអំពីការចំណាយក្រៅផ្លូវការសម្រាប់ការអប់រំថ្នាក់បឋមសិក្សា




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

សម្រាប់សេវាកម្មពីរផ្សេងទៀត មានសេវាមួយចំនួនត្រូវបានកំណត់ជាផ្លូវការឱ្យបង់ប្រាក់ (ចំពោះការិយាល័យឃុំ) ឬត្រូវបានកំណត់ជាផ្លូវការឱ្យបង់គ្រប់សេវាទាំងអស់ (ចំពោះមណ្ឌលសុខភាព)។ ដូច្នេះនៅពេលនេះ ការសិក្សានេះអាចសួរទៅអ្នកប្រើប្រាស់សេវាទាំងអស់ដោយផ្ទាល់ថា តើពួកគាត់បានទទួលព័តិមានជាមុនដែរឬទេ អំពីតម្លៃផ្លូវការដែលត្រូវបង់មុននឹងប្រើប្រាស់សេវាសាធារណៈទាំងអស់នោះ។

### តារាង ២.១: ការយល់ដឹងអំពីតម្លៃផ្លូវការ មុនប្រើប្រាស់សេវា

| | ការិយាល័យឃុំ/សង្កាត់ | មណ្ឌលសុខភាព |
|---|---|---|
| ជានិច្ចកាល ដឹង | ១០% | **៣៤%** |
| ដឹង ម្តងម្កាល | ៣១% | ៣០% |
| មិនដែលដឹងសោះ | **៥៧%** | ៣១% |
| មិនមានចម្លើយ | ២% | ៥% |
| សរុប | ៨៥៩ | ៨៥៩ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

ជាលទ្ធផល អ្នកប្រើប្រាស់សេវាមណ្ឌលសុខភាពដែលមានការកំណត់តម្លៃផ្លូវការគ្រប់សេវាទាំងអស់ បានទទួលព័តិមានអំពីតម្លៃទាំងនេះ បានល្អប្រសើរជាងអ្នកប្រើប្រាស់សេវាឃុំ/សង្កាត់ដែលមានសេវាតែមួយចំនួនតូចប៉ុណ្ណោះមានតម្លៃផ្លូវការ។ ភាពស្រពិចស្រពិលអំពីតម្លៃផ្លូវការនេះហើយ ដែលធ្វើឱ្យអ្នកប្រើប្រាស់សេវាទទួលបានព័តិមានពីតម្លៃទាំងនេះកាន់តែតិចទៅៗ ហើយឈានទៅរកការបង់ប្រាក់ក្រៅផ្លូវការ។ ទន្ទឹមនឹងនេះដែរ អ្នកប្រើប្រាស់ក៏ត្រូវបានចោទសួរដែរថា តើពួកគេបានដឹងថាតម្លៃដែលគេបានបង់នោះ ជាតម្លៃផ្លូវការ ឬក្រៅផ្លូវការ:

**តារាង ២.២: តើអ្នកបានដឹងថាតម្លៃដែលអ្នកបានបង់ជាតម្លៃផ្លូវការ ឬក្រៅផ្លូវការ?**

| | **ការិយាល័យឃុំ/សង្កាត់** | **សាលាបឋមសិក្សា** | **មណ្ឌលសុខភាព** |
|---|---:|---:|---:|
| ផ្លូវការ | ២០% | ១០% | **៤៨%** |
| ក្រៅផ្លូវការ | ១៧% | **៥៥%** | ៦% |
| ទាំងផ្លូវការ និងក្រៅផ្លូវការ | ២០% | ១០% | ១៥% |
| មិនដឹង | **៤១%** | ២០% | ២៦% |
| មិនច្បាស់ណាមួយ | ២% | ៥% | ៥% |
| សរុបអ្នកឆ្លើយតប | ៨៥៥ | ២០៧ | ៨៥៩ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

លទ្ធផលនៃសំណួរនេះបានផ្តល់ការគាំទ្រយ៉ាងសមស្របមួយដល់ការសន្និដ្ឋាន ដែលបានលើកឡើងពីមុនៗថា សាលាបឋមសិក្សាមិនមានការកំណត់ឱ្យយកកម្រៃផ្លូវការ។ ចំណែកឯ មណ្ឌលសុខភាពដែលរាល់សេវាទាំងអស់ត្រូវបានកំណត់ឱ្យបង់នូវតម្លៃផ្លូវការមួយ មានអ្នកឆ្លើយថា "មិនដឹង" តិចជាងសេវារបស់ការិយាល័យឃុំ/សង្កាត់ ដែលមានទ្រង់ទ្រាយនៃតម្លៃលាយបញ្ចូលគ្នា។

ដូច្នេះ កត្តាមួយដែលជំរុញឱ្យមានការបង់ចំណាយក្រៅផ្លូវការ គឺបណ្តាលមកពីភាពកង្វះខាតនូវព័ត៌មានអំពីតម្លៃផ្លូវការ។ មានប្រជាជនមួយចំនួនបានធ្វើការរិះគន់ថា "*តម្លៃគឺស្ថិតនៅលើមាត់របស់ពួកមន្ត្រីទាំងនោះ*"។ ទិន្នន័យខាងលើនេះ គឺសមស្របទៅនឹងចម្លើយរបស់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលទទួលស្គាល់ថា តម្លៃផ្លូវការមិនដែលបានផ្សព្វផ្សាយជាសាធារណៈនោះទេ។ ដោយសារតែមិនបានប្រកាសជាសាធារណៈពីតម្លៃសេវានេះហើយ ទើបប្រជាពលរដ្ឋភាគច្រើនមិនអាចបែងចែកបានរវាងតម្លៃ ផ្លូវការ និងក្រៅផ្លូវការបាន។ ជាទូទៅប្រជាពលរដ្ឋបានយល់ដឹងតិចតួចបំផុតពីតម្លៃផ្លូវការ ដែលជាហេតុបង្កឱ្យមាននូវបរិយាកាសមួយតម្រូវឱ្យមានចំណាយក្រៅផ្លូវការ។

ប៉ុន្តែទោះជាយ៉ាងណា ការផ្សព្វផ្សាយជាសាធារណៈអំពីតម្លៃផ្លូវការ វាគ្រាន់តែជាការចាំបាច់មួយប៉ុណ្ណោះ មិនមែនជាលក្ខខណ្ឌមួយប្រកបដោយប្រសិទ្ធភាពដើម្បីបញ្ជៀសការទាមទារ និងចំណាយក្រៅផ្លូវការបាននោះទេ។ ការសិក្សាដដែលនេះបានបង្ហាញថា ប្រជាពលរដ្ឋនៅតែបង់ចំណាយក្រៅផ្លូវការសម្រាប់ការធ្វើសំបុត្រកំណើត បើទោះជានៅក្នុងកំឡុងពេលធ្វើយុទ្ធនាការណ៍ក៏ដោយ ហើយបើទោះជាមានការបញ្ជាក់យ៉ាងច្បាស់ថា ការផ្តល់សេវានៅក្នុងកំឡុងពេលនោះ គឺមិនយកប្រាក់ទេ ហើយប្រជាពល-រដ្ឋស្ទើរតែទាំងអស់ក៏បានដឹងករណីលើកលែងនេះដែរ។ ដូចគ្នានេះដែរ ចំពោះតម្លៃសេវាមណ្ឌលសុខភាព បើទោះជាបានបិទផ្សាយយ៉ាងច្បាស់ហើយក្តី ក៏គេនៅតែឃើញកើតមានករណីការបង់ចំណាយក្រៅផ្លូវការនេះដដែល។

## ២.២. មូលហេតុនៃការកម្រៃក្រៅផ្លូវការ

មូលហេតុមួយចំនួននៃចំណាយក្រៅផ្លូវការ ត្រូវបានបង្ហាញនៅក្នុងក្រុមពិភាក្សា ជាមួយអ្នកប្រើប្រាស់សេវា។ រីឯនៅក្នុងក្រុមពិភាក្សាជាមួយអ្នកផ្តល់សេវាវិញ សម្រាប់សេចក្តីអះអាងរបស់ពួកគាត់ពីមូលហេតុដែលនាំឱ្យយក ឬតម្រូវឱ្យមានការបង់តម្លៃក្រៅផ្លូវការ ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។ លទ្ធផលនៃការស្រាវជ្រាវនេះ ក៏បានបង្ហាញនូវទិដ្ឋភាពមួយសមស្របជាខ្លាំងទៅនឹងការយល់ឃើញរបស់សាធារណៈជនពាក់ព័ន្ធនឹងមូលហេតុនៃចំណាយក្រៅផ្លូវការសម្រាប់សេវាថ្នាក់ មូលដ្ឋានទាំងបីផងដែរ។

**តារាង ២.៣: តើអ្នកផ្តល់សេវាប្រើប្រាក់ដែលទទួលបានពីការចំណាយក្រៅផ្លូវការក្នុងគោលដៅអ្វីខ្លះ?**

| | ការិយាល័យឃុំ/សង្កាត់ | សាលាបឋមសិក្សា | មណ្ឌលសុខភាព |
|---|---|---|---|
| **ផ្គត់ផ្គង់ជីវភាពគ្រួសារ** | **៥៩%** | **៦៧%** | **៦៦%** |
| បំពេញចិត្តបុគ្គលិកថ្នាក់លើដើម្បីរក្សា ឬតម្លើងតំណែង | ១៤% | ១២% | ១១% |
| សម្រាប់ការកំសាន្ត | ៨% | ៧% | ៦% |
| វិភាគទានដល់គណបក្សនយោបាយ | ៦% | ២% | ៣% |
| ផ្សេងៗ | ១៣% | ១២% | ១៥% |
| ចម្លើយសរុប (*) | ១០០៩ | ៨៥៣ | ៨០១ |

**ចំណាំ:** *(*) ចម្លើយអាចមានលើសពីមួយ*

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

### *២.២.១. សេវាសាលាឃុំ/សង្កាត់*

ឆ្លើយទៅនឹងសំណួរដែលថាមូលហេតុអ្វីបានជាប្រជាពលរដ្ឋត្រូវបង់តម្លៃក្រៅផ្លូវការទៅដល់ការិយាល័យឃុំ/សង្កាត់ ប្រជាពលរដ្ឋដែលបានចូលរួមក្នុងក្រុមពិភាក្សាបានបញ្ជាក់ថា ករណីភាគច្រើន ដែលពួកគាត់យល់ព្រមបង់ប្រាក់បន្ថែមដើម្បីទទួលបានសេវា គឺដើម្បីសម្រេចគោលបំណងមួយចំនួន។ ប៉ុន្តែ មានករណីខ្លះ ពួកគាត់ត្រូវតែបង់តម្លៃក្រៅផ្លូវការ ដោយសារតែមានការទាមទារពីសំណាក់មន្ត្រីឃុំ/សង្កាត់តែម្តង។ ក្រៅពីកត្តាទាំងនេះ នៅមានកាលៈទេសៈផ្សេងៗទៀត ក៏អាចធ្វើឱ្យមានចំណាយក្រៅផ្លូវការនេះផងដែរ។

មូលហេតុសាមញ្ញមួយទៀតដែលប្រជាពលរដ្ឋត្រូវបង់ចំណាយលុយបន្ថែមនោះគឺ ដើម្បីសម្តែងអំណរគុណចំពោះមន្ត្រីឃុំ/សង្កាត់សម្រាប់ការបំពេញការងាររបស់ពួកគាត់ ឬសម្រាប់សេវាបន្ថែមក្រៅម៉ោងធ្វើការ។ ប្រជាពលរដ្ឋម្នាក់បានលើកឡើងថា *"បើយើងមិនឱ្យលុយបន្ថែមទៅពួកគាត់ទេ ក៏ពួកគាត់ធ្វើឱ្យយើងដែរ ដោយមិនបានទាមទារប្រាក់ពីពួកយើងឡើយ ក៏ប៉ុន្តែពួកយើងឱ្យលុយគាត់ ដោយអរគុណដល់*

*ពួកគាត់ បានធ្វើការងារយ៉ាងច្រើនសម្រាប់ពួកយើង ហើយម្យ៉ាងទៀតប្រាក់បៀវត្សរ៍របស់ពួកគាត់ក៏តិចតួច*"។ បន្ថែមលើចំណុចនេះទៀត អ្នកប្រើប្រាស់សេវាមួយចំនួនបានលើកឡើងថា ការឱ្យលុយជាសាគុណនេះក៏ជួយឱ្យមានទំនាក់ទំនងល្អជាមួយមន្ត្រីឃុំ/សង្កាត់សម្រាប់សេវាផ្សេងៗទៀតតទៅថ្ងៃមុខផងដែរ។

មូលហេតុសំខាន់មួយផ្សេងទៀត សម្រាប់ប្រជាពលរដ្ឋក្នុងបង់តម្លៃបន្ថែមនេះ គឺដើម្បីទទួលសេវាដែលគេត្រូវការបានឆាប់រហ័ស។ អ្នកចូលរួមក្រុមពិភាក្សា ម្នាក់នៅខេត្តកំពង់ធំបានរិះគន់ថា "*បើចង់បានលឿន ឱ្យលុយឱ្យច្រើនទៅ*"។ ផ្ទុយទៅវិញ មានប្រជាពលរដ្ឋមួយចំនួនតូចបានឱ្យលុយបន្ថែមទៅអ្នកផ្តល់សេវាសាធារណៈ ដោយមិនមានបំណងពិសេសណាមួយនោះទេ ប៉ុន្តែវាជារឿងធម្មតា ព្រោះចំណាយក្រៅផ្លូវការដើម្បីទទួលបានសេវាបានក្លាយទៅជាទម្លាប់ទៅហើយ។ ប្រជាពលរដ្ឋម្នាក់ដែល ធ្លាប់ប្រើប្រាស់សេវាបានលើកឡើងថា "*ខ្ញុំដូចជាមានអារម្មណ៍អៀនខ្លួនឯងណាស់ ពេលពួកគាត់ផ្តល់សេវាមកឱ្យខ្ញុំ តែខ្ញុំមិនមានផ្តល់អ្វីទៅឱ្យគេវិញសោះនោះ*"។

ទោះយ៉ាងណា ការណ៍ដែលលើកឡើងថា "*ព្រោះមន្ត្រីឃុំ/សង្កាត់តម្រូវឱ្យប្រជាពលរដ្ឋបង់*" នេះពេលខ្លះ គឺជាចម្លើយយ៉ាងខ្លីទៅនឹងសំណួរដែលថា ហេតុអ្វីបានជាប្រជាពលរដ្ឋត្រូវបង់តម្លៃក្រៅផ្លូវការដល់ការិយាល័យឃុំ/សង្កាត់។ អ្នកចូលរួមក្នុងក្រុមពិភាក្សាម្នាក់ បានសម្តែងការគាំទ្រទៅនឹងការលើកឡើងខាងនេះថា "*បើគ្មានការទាមទារឱ្យបង់ទេ ក៏គ្មានសេវាផ្តល់ឱ្យដែរ*"។ ឆ្លើយតបនឹងបញ្ហានេះ ក្រុមអ្នកចុះសម្ភាសន៍របស់ វ.ស.ក. តែងតែសាកសួរទៅអ្នកឆ្លើយតបថា តើពួកគាត់ធ្លាប់បានតវ៉ាដែរទេ ពេលមានការទាមទារបែបនេះ?

ចម្លើយមានលក្ខណៈចំរុះទោះបីជាអ្នកឆ្លើយថា "ទេ" មានចំនួនច្រើនក៏ដោយ (៦៦ ភាគរយ)។ មូលហេតុចំបងដែលគ្មានការតវ៉ាគឺកង្វះតម្លាភាព និងជំនឿទុកចិត្តលើយន្តការនៃការតវ៉ា។ ក្រៅពីការយល់ដឹងតិចតួចអំពីតម្លៃផ្លូវការ អ្នកខ្លះមិនហ៊ានតវ៉ាពីព្រោះពួកគាត់ខ្លាចមន្ត្រីឃុំ/សង្កាត់ ក្នុងនាមជាអាជ្ញាធរគ្រប់គ្រងមូលដ្ឋាន។ មូលហេតុផ្សេងមួយទៀតដែលនាំឱ្យប្រជាជនមិនសូវយកចិត្តទុកដាក់តវ៉ា គឺដោយសារបរិមាណលុយដែលត្រូវបង់នោះតិចតួច។ ក្រៅពីនេះ អ្នកខ្លះបង់លុយដែលខាងមន្ត្រីទាមទារ ដោយសារតែឃើញអ្នកផ្សេងទៀតបង់លុយនេះដែរ។

ប្រជាជនភាគច្រើនជឿថា មន្ត្រីឃុំ/សង្កាត់ប្រើលុយក្រៅផ្លូវការដែលទទួលបានដើម្បីផ្គត់ផ្គង់ការចំណាយក្នុងគ្រួសាររបស់ពួកគេ ដោយសារតែបៀវត្សរ៍ទាប និងកម្រិតតជីវភាពក្រីក្រ។ គ្រូបឋមសិក្សាម្នាក់បានលើកឡើងថា "*បៀវត្សរ៍គ្រូបង្រៀនទាប តែបៀវត្សរ៍មន្ត្រីឃុំទាបជាងនេះទៅទៀត។ ដូចនេះ តើពួកគាត់រស់ដូចម្តេច បើបៀវត្សរ៍ ៨ ម៉ឺនរៀល មិនគ្រប់ទាំងទិញបារីផង*"។

ទស្សនៈនេះគាំទ្រដោយចម្លើយពីសមាជិក/សមាជិកាក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ ដែលទទួលស្គាល់ថាចំណាយក្រៅផ្លូវការដែលពួកគាត់ទទួលបានត្រូវបានប្រើ ដើម្បីប៉ះប៉ូវលើតម្រូវការចាំបាច់នៃជីវភាពប្រចាំថ្ងៃ។ ថែមលើចម្លើយនេះទៀត មន្ត្រីដែលត្រូវបានសម្ភាសបានសួរក្រុមអ្នកស្រាវជ្រាវថា តើមន្ត្រីឃុំ/សង្កាត់រកបានចំណូលប៉ុន្មានក្នុង ១ ខែ។ ទោះបីជាមន្ត្រីឃុំ/សង្កាត់ភាគច្រើនបានទទួលស្គាល់ថាចំណូលដែលពួកគាត់បានទទួលពីអ្នកប្រើប្រាស់ មិនអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់គ្រប់គ្រាន់ទេ គឺគ្រាន់តែអាចប្រើប្រាស់លើចំណាយប្រចាំថ្ងៃ ដូចជាបាយព្រឹក បារី សាំង ។ល។ សមាជិក/សមាជិកាឃុំ/សង្កាត់ខ្លះសារភាពថា ប្រាក់ដែលបានពីចំណាយក្រៅផ្លូវការរបស់ប្រជាជនត្រូវបានចែកទៅឱ្យបុគ្គលិកមួយចំនួនដែលប្រឹងធ្វើការ។

ក្នុងកិច្ចពិភាក្សា អ្នកចូលរួមទាំងអស់ក៏ត្រូវបានសាកសួរថាតើមន្ត្រីឃុំ/សង្កាត់នឹងឈប់ទារកម្រៃក្រៅផ្លូវការទេ បើសិនជារដ្ឋាភិបាលតម្លើងបៀវត្សរ៍ឱ្យពួកគាត់ដល់កំរិតមួយសមរម្យ។ នៅស្ទើតែគ្រប់ក្រុមពិភាក្សា ចម្លើយទៅនឹងសំណួរនេះមានលក្ខណៈចំរុះ ក្នុងចំណោមប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ/សង្កាត់។ អ្នកដែលឆ្លើយថា "នឹងឈប់" ចំពោះសំណួរនេះ ចាត់ទុកការទារលុយក្រៅផ្លូវការជាជំរើសចុងក្រោយ ដោយសារបៀវត្សរ៍ទាបមិនអាចផ្គត់ផ្គង់គ្រួសារបាន។ នៅពេលដែលគេតម្លើងបៀវត្សរ៍ឱ្យគ្រប់គ្រាន់ពួកគាត់ជឿថាមន្ត្រីទាំងនោះ ក្នុងនាមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ នឹងមានការខ្មាស់អៀនក្នុងការបន្តទាមទារកម្រៃក្រៅផ្លូវការ។

ផ្ទុយមកវិញ អ្នកដែលនិយាយថា "មិនអាចឈប់បាន" ការពារចម្លើយរបស់ខ្លួនដោយជឿថា ការយកលុយក្រៅផ្លូវការបានក្លាយជាទម្លាប់របស់មន្ត្រីរដ្ឋាភិបាលទៅហើយ រួមទាំងបុគ្គលិកឃុំ/សង្កាត់ផង។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមម្នាក់បានលើកឡើងថា *"គោព្រៃធំស៊ីស្មៅក្នុងព្រៃធំ ឯគោព្រៃតូចស៊ីស្មៅក្នុងព្រៃតូច "*។

ទោះបីជាមានការខ្វែងយោបល់គ្នាក្តី អ្នកនៅក្នុងក្រុមពិភាក្សាទាំងអស់ជឿថា តម្លើងបៀវត្សរ៍នឹងជួយកាត់បន្ថយការទារកម្រៃក្រៅផ្លូវការ តែតម្រូវអោយមានការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ពីសំណាក់រដ្ឋាភិបាលចំពោះមន្ត្រីណាដែលបន្តធ្វើនេះ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់នៃសេវា។

### ២.២.២. *សេវាសាលាបឋមសិក្សា*

យោងទៅតាមប្រជាពលរដ្ឋ និងគ្រូបង្រៀនមូលហេតុដែលយកប្រាក់ក្រៅផ្លូវការ គឺមកពីបៀវត្សរ៍គ្រូមិនគ្រប់គ្រាន់។ គ្រូភាគច្រើននៅក្នុងកិច្ចពិភាក្សាជាក្រុមបាននិយាយថា *"បៀវត្សរ៍គ្រូទាបណាស់ ហើយជារឿយពួកគេទទួលការរអ៊ូរទាំពីប្រពន្ធ"*។

នៅពេលឆ្លើយទៅនឹងសំណួរថា តើហេតុអ្វីបានជាគ្រូនៅទីប្រជុំជនយកលុយ គ្រូបឋមសិក្សាម្នាក់នៅទីរួមខេត្តកំពង់ធំបាននិយាយថា *"និយាយឱ្យត្រង់ទៅ គ្រូមិនចង់យកលុយពីសិស្សទេ តែភាពក្រីក្រ តម្រូវ ឱ្យយក ...បៀវត្សរ៍មិនឡើងលឿនដូចថ្លៃទំនិញទេ"*។ គ្រូម្នាក់ទៀតនៅទីរួមខេត្តសៀមរាបបានពន្យល់ថា *"ថ្ងៃខ្លះហោប៉ៅគ្រូធូរស្តេត អញ្ចឹងគ្រូរកស៊ីក្នុងថ្នាក់ ដោយសារគ្រូក្រ និងត្រូវការលុយទៅចិញ្ចឹមគ្រួសារ"*។ គ្រូម្នាក់ទៀតបានបន្ថែមថា *"មិនមែនមានន័យថា គ្រូយកលុយពីសិស្សទាំងសប្បាយចិត្តទេ។ ផ្ទុយមកវិញ យើងមានអារម្មណ៍ខ្មាស់អៀន ប៉ុន្តែកូនយើងត្រូវការញ៉ាំបាយ អញ្ចឹងយើងគ្មានជំរើសទេ"*។

គេអាចសន្និដ្ឋានថា មានមូលហេតុពីរចំបងក្នុងការយកលុយក្រៅផ្លូវការគឺៈ ភាពក្រីក្រ និងតម្រូវការក្នុងការចំណាយទៅលើជីវភាពខ្ពស់ ជាពិសេសនៅទីប្រជុំជន។

ក្នុងករណីធ្ងន់ធ្ងរមួយចំនួនកើតមាន ដោយសាមានគ្រូខ្លះបានដាក់ទណ្ឌកម្មសិស្សណាដែលមិនបង់លុយក្រៅផ្លូវការ។ ទណ្ឌកម្មទាំងនោះមានតាំងពីជេរបញ្ចោរ មិនឱ្យសិស្សចូលរៀន ឱ្យពិន្ទុទាប និងមិនឱ្យឡើងថ្នាក់នៅចុងឆ្នាំ។ អ្នកចូលរួមម្នាក់នៅកំពង់ធំនិយាយថា *"គ្មានលុយគ្មានពិន្ទុ គ្មានព្រឹត្តិប័ត្រពិន្ទុល្អ"*។ អ្នកចូល រួមម្នាក់ទៀតនៅកំពង់ចាមបាននិយាយគាំទ្រចំណុចនេះថា *"ទោះបីជាកូនខ្ញុំរៀនបានពិន្ទុល្អ ក៏វាមិនបានលេខល្អដែរ បើសិនវាមិនឱ្យលុយគ្រូវាទេ"*។

### ២.២.៣. សេវាមណ្ឌលសុខភាព

ទោះបីជាចំណាយក្រៅផ្លូវការនៅមណ្ឌលសុខភាពមានទំហំតិចតួច ឬស្ទើតែគ្មានក្តី ក៏យោងតាមកិច្ចពិភាក្សាជាក្រុម ប្រជាជនមួយចំនួនតូចបានសារភាពថា ពេលខ្លះពួកគាត់ឱ្យលុយ "អរគុណ" ទៅបុគ្គលិកមណ្ឌលសុខភាពសម្រាប់សេវារបស់ពួកគាត់ បើទោះបីជាបុគ្គលិកទាំងនោះមិនទារលុយក្តី។ ករណីនេះគាំទ្រដោយអ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមម្នាក់នៅបន្ទាយមានជ័យ ដោយគាត់បាននិយាយថា *"យើងឱ្យលុយគាត់ដោយសារពួកគាត់បានជួយជីវិតពួកយើង"*។ អ្នកចូលរួមកិច្ចពិភាក្សាជាក្រុម នៅព្រៃវែងបានគិតថា វានឹងមានភាពកាន់តែងាយស្រួលក្នុងការទទួលការសង្គ្រោះពីពួកគាត់នៅពេលក្រោយ ប្រសិនបើយើងឱ្យលុយគាត់ខ្លះ។ អ្នកចូលរួមទាំងនោះបាននិយាយទៀតថា *"ពួកគាត់ជួយយើង យើងជួយពួកគាត់វិញ"*។ គាត់បន្តទៀតថា *"ពួកគាត់ឱ្យ (សេវា) យើងឱ្យ (លុយ) ដែរ"*។ ទោះបីយ៉ាងនេះក្តី ជាទូទៅពួកគាត់ឱ្យលុយ "អរគុណ" ទៅបុគ្គលិកមណ្ឌលសុខភាព តែក្នុងករណីធ្ងន់ធ្ងរប៉ុណ្ណោះ ដូចជាពេលសម្រាលកូនដែលត្រូវការឆ្មបក្រៅម៉ោងធ្វើការ។

ជាងនេះទៀត កិច្ចពិភាក្សាជាក្រុមបានបង្ហាញថា ចំណាយក្រៅផ្លូវការទាបបង្កឱ្យមានការផ្តល់សេវាមិនល្អនៅមណ្ឌលសុខភាព។ ដូចគ្នាដែរ នៅទីជនបទខ្លះ អ្នកក្រខ្លាំងមិនអាចទទួលបានសិទ្ធក្នុងការមិនបង់កម្រៃសេវាឡើយ ហើយទីបញ្ចប់ ពួកគាត់ត្រូវតែបង់កម្រៃផ្លូវការ។ បញ្ហានេះកើតឡើងដោយ

សារតែពួកគាត់ត្រូវមានលិខិតបញ្ជាក់ពីឃុំ/សង្កាត់ដែលបញ្ជាក់ថា ពួកគាត់ពិតជាក្រមែន។ ជាធម្មតា នៅពេលដែលពួកគាត់រកសេវាថែទាំសុខភាព ពួកគាត់គ្មានពេលសុំលិខិតនោះទេ ដូចដែលអ្នកចូលរួមម្នាក់នៅសៀមរាបបាននិយាយថា *"ខ្ញុំឮថាសេវា (សុខភាព) មិនយកលុយទេពីអ្នកក្រ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំមិនដែលទទួលបានសេវាដោយមិនគិតថ្លៃនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យខេត្តទេ "*។

**ប្រអប់ ២.១: មណ្ឌលសុខភាពនៅខេត្តកំពង់ធំ**

ខេត្តកំពង់ធំមានមណ្ឌលសុខភាព ៥០ បម្រើប្រជាជន ៨០០ ០០០ នាក់។ ចំនួននេះគ្រប់គ្រាន់ហើយបើគិតពីបរិមាណ ប៉ុន្តែ បើគិតពីទីតាំងភូមិសាស្ត្ររវាងមណ្ឌលសុខភាពនីមួយៗ គេអាចនិយាយបានថា វាមិនគ្រប់គ្រាន់ទេ។ ចម្ងាយរវាងមណ្ឌលសុខភាពមួយទៅមួយទៀតមានលក្ខណៈឆ្ងាយ។ ជាលទ្ធផល អ្នកដែលនៅឆ្ងាយពីមណ្ឌលសុខភាពមានការពិបាកក្នុងការទទួលសេវាណាស់។ ដូចនេះសេវាមណ្ឌលសុខភាពមិនគ្រប់គ្រាន់ទេ សម្រាប់សហគមន៍ ហើយពួកគេត្រូវតែប្រើសេវាឯកជន។ បញ្ហានេះប៉ះពាល់ដល់ចំណូលមណ្ឌលសុខភាពដែរ ដោយសារតែអ្នកជម្ងឺមួយចំនួនមិនប្រើសេវាមណ្ឌលសុខភាព។ ឧទាហរណ៍ មានតែ ១០ ភាគរយ នៃស្ត្រីមានផ្ទៃពោះប៉ុណ្ណោះដែលសម្រាលកូននៅមណ្ឌលសុខភាព ចំណែកឯ ៩០ ភាគរយ ទៀត សម្រាលកូននៅផ្ទះ ដោយប្រើឆ្មបុរាណ ឬបុគ្គលិកមណ្ឌលសុខភាព។

ជាងនេះទៅទៀត សេវានៅមណ្ឌលសុខភាពមានព្រំដែនកំណត់។ សេវាសំខាន់ៗខ្លះ ដូចជាដកធ្មេញមិនទាន់មានទេ។ មណ្ឌលសុខភាពក៏មិនផ្តល់សេវាសម្រាកដែរ ហើយក៏គ្មានឡានពេទ្យសម្រាប់ដឹកអ្នកជម្ងឺធ្ងន់ទៅពេទ្យខេត្តដែរ។ ក្រៅពីបញ្ហាដែលបានលើកឡើងនេះ មណ្ឌលសុខភាពខ្វះថ្នាំ ឧបករណ៍ និងធនធានមនុស្ស។ ដោយសារមូលហេតុនេះ ប្រជាជនជារឿយទៅមន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី ៧ នៅសៀមរាបជំនួសវិញ ទោះជាត្រូវចំណាយសម្រាប់ការធ្វើដំណើរក៏ដោយ តែសេវាមិនគិតលុយឡើយ ហើយមន្ទីរពេទ្យក៏ល្អ។

ក្រៅពីនេះ អ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមភាគច្រើនរអ៊ូរទាំអំពីម៉ោងធ្វើការ និងសីលធម៌របស់បុគ្គលិកមណ្ឌលសុខភាព។ មណ្ឌលសុខភាពភាគច្រើនបើកតែពេលព្រឹកពីម៉ោង ៨ ទៅ ១១ ហើយ គ្មានបុគ្គលិកគ្រប់គ្រាន់ទេ។ លើសពីនេះទៅទៀត មនុស្សជាច្រើនក៏រិះគន់ឥរិយាបថបុគ្គលិកមណ្ឌលសុខភាពផងដែរ។ អ្នកចូលរួមម្នាក់ក្នុងកិច្ចពិភាក្សាជាក្រុមនៅកំពង់ធំនិយាយថា *"សេវាមិនថ្លៃទេចំពោះពួកយើង។ ក្រៅពីថ្នាំ អ្នកជម្ងឺត្រូវការថែទាំ និងលួងលោមពីពួកគាត់។ ផ្ទុយមកវិញ ពួកគាត់និយាយមកយើងដូចយើងមិនមែនមនុស្សអញ្ចឹង ហើយពេលខ្លះគាត់មិនយកភ្នែកមើលយើងផង។ យើងខ្លាចមិនហ៊ានទៅមណ្ឌលសុខភាពទេឥឡូវ"*។

ប្រធានមណ្ឌលសុខភាពម្នាក់បានយល់ស្របថា មណ្ឌលសុខភាពភាគច្រើនបើកតែពេលព្រឹក។ គាត់បាននិយាយថា *"ខ្ញុំទទួលស្គាល់ថា មណ្ឌលសុខភាពរបស់ខ្ញុំ និងមណ្ឌលសុខភាពផ្សេងទៀត បើកតែ*

*ពេលព្រឹក ក៏ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ហើយថែមទាំងមិនអាចដាក់ទណ្ឌកម្មដល់បុគ្គលិកខ្ញុំទៀត ពីព្រោះប្រាក់ខែរបស់ពួកគេមិនគ្រប់គ្រាន់ ដូច្នេះហើយពួកគេត្រូវរកចំណូលផ្សេងទៀត ដោយការយកពេលវេលាធ្វើការទៅព្យាបាលជម្ងឺខាងក្រៅ ឬរកការងារផ្សេងទៀត។ យើងមិនអាចអាស្រ័យតែចំណូលដ៏តិចតួចដែលបានមកពីមណ្ឌលសុខភាពបានទេ ពីព្រោះមនុស្សមកមណ្ឌលសុខភាពតិចណាស់*"។

បញ្ហាទាំងនោះបណ្តាលមកពីចំណូលបុគ្គលិកមណ្ឌលសុខភាពទាប។ យោងតាមបញ្ញត្តិរបស់រដ្ឋាភិបាល បុគ្គលិកមណ្ឌលសុខភាពមានសិទ្ធិទទួលបានដល់ទៅ ៦០ ភាគរយនៃចំណូលផ្លូវការ។ ប៉ុន្តែ ចំនួននេះតិចតួចណាស់ដែលមិនអាចឱ្យពួកគេចិញ្ចឹមជីវិតបាន។ យោងទៅតាមការសម្ភាសជាមួយបុគ្គលិកមណ្ឌលសុខភាពបានបង្ហាញថា បុគ្គលិកម្នាក់ទទួលជាមធ្យមប្រហែលជា ១០ ដុល្លារអាមេរិក ប៉ុណ្ណោះ ពីកម្រៃផ្លូវការក្នុងមួយខែ។ ជាលទ្ធផល ពួកគេត្រូវតែប្រើម៉ោងធ្វើការដើម្បីរកចំណូលថែមទៀត ដែលទង្វើទាំងនេះប៉ះពាល់យ៉ាងខ្លាំងដល់ប្រសិទ្ធភាពនៃសេវាកម្មរបស់មណ្ឌលសុខភាព។

អ្នកចូលរួម និងប្រធានមណ្ឌលសុខភាពក៏លើកឡើងពីបញ្ហាខ្វះថ្នាំ និងឧបករណ៍ប្រើប្រាស់នៅមណ្ឌលសុខភាពដែរ។ អ្នកចូលរួមនៅសៀមរាប កំពង់ធំ បាត់ដំបង ស្វាយរៀង បាននិយាយថា "*បើផ្តាសាយ ឈឺក្បាល វិលមុខ ឬឈឺពោះ មានតែប៉ារ៉ាសេតាម៉ុលទេដែលឱ្យ*"។ ក្រៅពីខ្វះថ្នាំ ថ្នាំដែលប្រើមិនមានស្តង់ដារទេឬហួសកាលបរិច្ឆេទប្រើប្រាស់ ដោយសារមណ្ឌលសុខភាពភាគច្រើនប្រើថ្នាំសល់ពីទសវត្សរ៍ឆ្នាំ ១៩៨០។

# ជំពូកទី ៣

# វិសាលភាពនៃកម្រៃក្រៅផ្លូវការ និងផលប៉ះពាល់

តិច ឬច្រើន កម្រៃក្រៅផ្លូវការកើតមាននៅក្នុងគ្រប់សេវាកម្ម ដែលជាកម្មវត្ថុនៃការសិក្សា។ យ៉ាងណាក្តី វិសាលភាពនៃកម្រៃក្រៅផ្លូវការដែលបង់ចូលទៅក្នុងវិស័យនីមួយៗ មានទំហំខុសប្លែកគ្នាច្រើនពីមួយទៅមួយ និងពីតំបន់មួយទៅតំបន់មួយទៀត។ ក្នុងជំពូកនេះ ភាពខុសប្លែកទាំងនោះនឹងត្រូវបានលើកយកមកសិក្សា ជាមួយគ្នានឹងផលប៉ះពាល់ផ្សេងៗនៃកម្រៃក្រៅផ្លូវការ ទៅលើមន្ត្រីដែលជាអ្នកផ្តល់សេវា ថវិកាឃុំ/សង្កាត់ និងជីវភាពរបស់ប្រជាពលរដ្ឋ។

## ៣.១. វិសាលភាពនៃកម្រៃក្រៅផ្លូវការ

### ៣.១.១. ចំណាយក្រៅផ្លូវនៅសាលាឃុំ/សង្កាត់

បច្ចុប្បន្ននេះ ការចុះបញ្ជីអាត្រានុកូលដ្ឋាន គឺជាសេវាផ្លូវការតែមួយគត់ដែលមានការកំណត់ច្បាស់លាស់ពីតម្លៃផ្លូវការដោយបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។ ជាទូទៅ សេវានេះពាក់ព័ន្ធទៅនឹងការចេញសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណៈភាពដល់ប្រជាពលរដ្ឋសំរាប់ប្រើជាប្រយោជន៍ខាងកំណត់ហេតុរដ្ឋបាលផ្សេងៗ។

ដោយឡែកសេវាមួយចំនួនផ្សេងទៀត ដែលផ្តល់ឱ្យប្រជាពលរដ្ឋដោយការិយាល័យឃុំ/សង្កាត់ដែរនោះមិនមានការកំណត់ទាមទារនូវតម្លៃផ្លូវការណាមួយនោះទេ ដែលការណ៍នេះបណ្តាលមកពីមូលហេតុពីរយ៉ាង។ ម៉្យាងដោយសារមិនទាន់មានច្បាប់ ឬបទប្បញ្ញត្តិណាមួយកំណត់ឱ្យបានច្បាស់ពីតម្លៃផ្លូវការសំរាប់សេវាទាំងនោះនៅឡើយ។ ម៉្យាងទៀត មានសេវាមួយចំនួនត្រូវបានផ្តល់ដោយការិយាល័យឃុំ/សង្កាត់ ទៅតាមទំលាប់ដែលធ្លាប់មានពីមុនមកនៅក្នុងសហគមន៍ ដែលតាមពិតសេវាមួយចំនួននោះស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរថ្នាក់លើ និងមិនមែនជាតួនាទីផ្លូវការរបស់ឃុំទេ។

លទ្ធផលនៃការស្រាវជ្រាវបង្ហាញឱ្យឃើញថា ចំណាយជាក់ស្តែងដែលប្រជាពលរដ្ឋបង់ដើម្បីទទួលបានសេវានីមួយៗនៅឃុំ/សង្កាត់ជាទូទៅមានភាគរយខ្ពស់ជាងខ្លាំងបើធៀបទៅនឹងតម្លៃផ្លូវការរបស់សេវាទាំងនោះដែលជាទូទៅទាបខ្លាំង និងក្នុងលក្ខខណ្ឌដែលសេវាក្រៅផ្លូវការដទៃទៀតត្រូវបានសន្មតថាផ្តល់ដោយមិនយកថ្លៃ។

ផ្អែកតាមទិន្នន័យដែលបានរកឃើញ កម្រៃក្រៅផ្លូវការប្រចាំឆ្នាំដែលបង់ចូលទៅក្នុងរដ្ឋបាលឃុំ-សង្កាត់ នៅទូទាំងប្រទេសកម្ពុជា មានប្រមាណ ៥ ទៅ ៦ លានដុល្លារអាមេរិក[១៧] បន្ថែមទៅលើថវិកាឃុំ/សង្កាត់នាពេលបច្ចុប្បន្ន ។ ធាតុចូលជាក់លាក់ និងរបៀបគណនាចំនួននេះ នឹងមានបកស្រាយលំអិតក្នុងឧបសម្ព័ន្ធ ២ ។ បើធៀបទៅនឹងទិន្នន័យស្រាវជ្រាវស្តីពីអំពើពុករលួយរបស់ ម.អ.ស បរិមាណនេះមានទំហំមិនដល់ ១០ភាគរយផងនៃកម្រៃក្រៅផ្លូវការដែលបង់ដោយប្រជាពលរដ្ឋលើសេវាសាធារណៈទាំងអស់នៅគ្រប់កំរិត ដែលមានរហូតដល់ប្រមាណ ៦៦ លានដុល្លារអាមេរិកនៅឆ្នាំ ២០០៥ [១៨] ។

## តារាង ៣.១: តម្លៃផ្លូវការ និង ការចំណាយជាក់ស្តែងលើសេវាទីមួយៗរបស់ឃុំ

**(គិតជារៀល)**

| សេវា | តម្លៃផ្លូវការ | ចំណាយជាក់ស្តែង | |
|---|---|---|---|
| | | ទីប្រជុំជន (១) | ជនបទ |
| សំបុត្រកំណើត | ៤០០ | ៥ ០០០ | ៥ ០០០ |
| សំបុត្រអាពាហ៍ពិពាហ៍ | ៤០០ | ២០ ០០០ | ២០ ០០០ |
| សំបុត្រមរណៈភាព | ៤០០ | ៧ ៥០០ | ៥ ០០០ |
| ចំលងសំបុត្រកំណើត | ២ ១០០ | ៥ ០០០ | ៥ ០០០ |
| ចំលងសំបុត្រអាពាហ៍ពិពាហ៍ | ៥ ៧០០ | ១៦ ០០០ | ១៦ ០០០ |
| ចំលងសំបុត្រមរណៈភាព | ២ ៤០០ | ២ ០០០ | ២ ០០០ |
| លិខិតប្រកាសអាពាហ៍ពិពាហ៍ | ២ ២០០ | ២០ ០០០ | ២០ ០០០ |
| លិខិតស្នាក់នៅ | - | ១០ ០០០ | ៧ ០០០ |
| លិខិតបញ្ជាក់កិរិយាមាយាទ | - | ៥ ០០០ | ៥ ០០០ |
| លិខិតអនុញ្ញាតអោយសាងសង់ | - | ៨៥ ០០០ | ២០ ០០០ |
| ប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី | - | ៥០ ០០០ | ២៨ ០០០ |
| សម្របសម្រួលជម្លោះ | - | ១៨ ០០០ | ១៥ ០០០ |
| ទទួលស្គាល់កុងត្រា | - | ១០ ០០០ | ៥ ០០០ |

**កំណត់សម្គាល់:** *(១) រួមបញ្ចូលទាំងឃុំក្នុងរាជធានីភ្នំពេញ និង នៅតាមទីរួមខេត្តដទៃទៀត*

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

---

[១៧] តម្លៃក្រៅផ្លូវការនេះ បូកបញ្ចូលទាំងសេវាផ្លូវការ និងក្រៅផ្លូវការដែលផ្តល់ដោយមន្ត្រីឃុំ/សង្កាត់ដល់ប្រជាជនក្នុងមូលដ្ឋាន លើកលែងតែសេវាផ្ទេរកម្មសិទ្ធដីធ្លី ដែលបរិមាណចំណាយមានគំលាតខុសគ្នាខ្លាំងពីឃុំមួយទៅឃុំមួយទៀត ។

[១៨] ម.អ.ស ឆាំ ២០០៥

បើគិតក្នុងកំរិតម៉ាក្រូ បរិមាណនៃកម្រៃក្រៅផ្លូវការដែលបានបង់ទៅការិយាល័យ ឃុំ/សង្កាត់ ទូទាំងប្រទេសមានតិចតួចបំផុត ប្រមាណជា ១ភាគរយនៃថវិកាជាតិសរុប ឬត្រឹមតែ ០,១ ភាគរយនៃ (ផ.ស.ស) របស់ប្រទេសប៉ុណ្ណោះ[១៩] ។ ទោះយ៉ាងណាក៏ដោយ ចំណាយក្រៅផ្លូវការទាំងនេះ ផ្តល់ផលប៉ះពាល់ច្រើន លើប្រជាពលរដ្ឋទីទាល់ក្រ និងបង្កើតបានជាបន្ទុកដ៏អវិជ្ជមានមួយចំពោះប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃដំណើរការផ្តល់សេវាថ្នាក់មូលដ្ឋាន។

បើគិតតាមតំបន់ ជាទូទៅកម្រៃក្រៅផ្លូវការ មានកំរិតខ្ពស់នៅតាមសង្កាត់ក្នុងរាជធានីភ្នំពេញ ហើយថយចុះតាមលំដាប់នៅឃុំតាមទីរួមខេត្ត ទីរួមស្រុក និងតំបន់ជនបទ ។ ជាមធ្យម កម្រៃក្រៅផ្លូវការប្រចាំឆ្នាំ ដែលបង់ចូលក្នុងឃុំ/សង្កាត់នីមួយៗមានចំនួនពី ៨ ០០០ ដុល្លារនៅរាជធានីភ្នំពេញ ៥ ៥០០ ដុល្លារនៅទីរួមខេត្ត ៣ ១០០ ដុល្លារនៅទីរួមស្រុក និងធ្លាក់ដល់ប្រមាណ ១ ៧០០ ដុល្លារនៅតំបន់ជនបទ ។ ដោយឡែក បរិមាណនៃការកម្រៃក្រៅផ្លូវការទាំងនេះ មិនបានរាប់បញ្ចូលនូវការបង់កម្រៃក្រៅផ្លូវការលើសេវាផ្ទេរកម្មសិទ្ធិដីធ្លីនោះទេ ដោយហេតុថាចំនួនករណីតាមឃុំនីមួយៗ និងបរិមាណចំណាយក្នុងមួយករណីៗពុំអាចផ្តល់ឱ្យមានសិក្សាជាក់លាក់បាន។

**រូបភាព ៣.១: ការចំណាយក្រៅផ្លូវការប្រចាំឆ្នាំ ក្នុងមួយឃុំ (គិតជាដុល្លារ)**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

[១៩] នៅឆ្នាំ ២០០៥ ចំណូលក្នុងសរុបរបស់រដ្ឋាភិបាលកម្ពុជាមាន ៦៤០លានដុល្លារ (មិនបូកបញ្ចូលជំនួយបរទេស មានប្រមាណ ៦០០ លានដុល្លារអាមេរិកទៀត) និង ម.អ.ស មាន ៦,២ ពាន់លានដុល្លារអាមេរិក

ជាទូទៅ កម្រៃក្រៅផ្លូវការមិនបានបង្កឱ្យមានការបាត់បង់ថវិកាឃុំ/សង្កាត់ទេ ប៉ុន្តែវាជាប្រភពថវិកាបន្ថែមមួយសំរាប់ការិយាល័យឃុំ/សង្កាត់។ យ៉ាងណាក្តី ទំលាប់នៃការបង់កម្រៃក្រៅផ្លូវការបង្កើតជារូបភាពដ៏អវិជ្ជមា នប៉ះពាល់ដល់ភាពស្មោះត្រង់របស់ប្រជាពលរដ្ឋ និងនាំទៅរកកង្វះទំនុកចិត្តទៅលើប្រព័ន្ធគ្រប់គ្រងរបស់អជ្ញាធរមូលដ្ឋាន។

## *៣.១.២. កម្រៃក្រៅផ្លូវការនៅសាលាបឋមសិក្សា*[២០]

យោងតាមបទបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល ការអប់រំនៅថ្នាក់បឋមសិក្សាពុំតម្រូវឱ្យមានការបង់ថ្លៃអ្វីទាំងអស់។ ទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវបង្ហាញឱ្យឃើញថា ចំណាយក្រៅផ្លូវការនៅតែកើតមាននៅក្នុងវិស័យអប់រំថ្នាក់បឋមសិក្សា ដោយភាគច្រើនប្រមូលផ្តុំនៅក្នុងរាជធានីភ្នំពេញ និងទីរួមខេត្ត-ក្រុងនានា ។ ការណ៍ដែលចំណាយក្រៅផ្លូវការនៅតាមតំបន់ជនបទពុំត្រូវបានមើលឃើញអាចបណ្តាលមកពីមូលហេតុ៣យ៉ាង ។ មូលហេតុទី ១ គឺគ្រួសារតាមតំបន់ជនបទជាទូទៅមានជីវភាពក្រី្រ គ្មានលទ្ធភាពអាចបង់ចំណាយនេះបាន។ មូលហេតុទី ២ គឺគ្រូបង្រៀននៅជនបទភាគច្រើនក៏ជាកសិករ ដូចនេះ ពួកគេអាចរកបានប្រភពចំណូល និងអាហារបន្ថែមខ្លះទៀត ដើម្បីបង្គ្រប់ជីវភាពពួកគាត់។ មូលហេតុទី ៣ គឺថាទំនាក់ទំនងរវាងគ្រូបង្រៀន និងប្រជាពលរដ្ឋនៅតាមជនបទមានភាពជិតស្និទ្ធខ្លាំងជាងតាមតំបន់ទីប្រជុំជនដោយសារចំនួនប្រជាជនមានបរិមាណតិច។ មូលហេតុទាំងនេះ ត្រូវបានគូសបញ្ជាក់ដោយក្រុមពិភាក្សាមួយចំនួនធំ ដែលក្នុងនោះគ្រូបឋមសិក្សាបានលើកឡើងថា " *កូនសិស្សនៅទីនេះ ភាគច្រើនមានជីវភាពក្រីក្រ ហើយមិនសូវចង់មករៀនទេ បើយើងហ៊ានតែទារលុយពីពួកគេនៅថ្ងៃនេះ ថ្ងៃស្អែកប្រាកដជាមិនឃើញពួកគេមករៀនឡើយ* " ។

---

[២០] លទ្ធផលសម្រាប់សាលាបឋមសិក្សានេះ មិនបានប្រៀបធៀបដោយផ្ទាល់ទៅនឹងការលទ្ធផលរបស់ ម.អ.ស នៅឆ្នាំ ២០០៥ អំពីការ អប់រំសាធារណៈដែលបានរាប់បញ្ចូលតាំងពីថ្នាក់បឋម ដល់មធ្យមសិក្សានោះទេ

## រូបភាព ៣.២៖តើអ្នកត្រូវចំណាយថ្លៃសាលាសំរាប់ការសិក្សា របស់កូនអ្នកនៅថ្នាក់បឋមសិក្សាដែរឬទេ?




**ប្រភព៖** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

យោងតាមលទ្ធផលទិន្នន័យនៃការសិក្សាប្រជាជនប្រមាណ ៨៧ ភាគរយ ដែលរស់នៅតាមជនបទ បានអះអាងថា ពួកគាត់មិនបានបង់ចំណាយក្រៅផ្លូវការ សំរាប់ការសិក្សារបស់កូនពួកគាត់នៅថ្នាក់បឋមសិក្សាឡើយ ខណៈពេលដែលប្រជាជនត្រឹមតែ ១៣ភាគរយប៉ុណ្ណោះឆ្លើយថាធ្លាប់បានបង់។ ដោយឡែកប្រជាជនប្រមាណជិត ៥០ភាគរយ នៅតំបន់ទីប្រជុំជនបានឱ្យដឹងថាពួកគាត់បានបង់ចំណាយ ក្រៅផ្លូវការសម្រាប់ឱ្យកូនរបស់ពួកគាត់បានរៀននៅថ្នាក់បឋមសិក្សា។លទ្ធផលទាំងនេះបង្ហាញឱ្យឃើញថា កម្រៃក្រៅផ្លូវការក្នុងសេវាអប់រំថ្នាក់បឋមសិក្សាភាគច្រើនកើតមាននៅតំបន់ទីប្រជុំជនដែលនៅទីនោះជីវភាពរស់នៅ និងលទ្ធភាពក្នុងការចាយវាយរបស់ប្រជាជនជាទូទៅមានកំរិតខ្ពស់ជាងតាមជនបទ។

សរុបមក កម្រៃក្រៅផ្លូវការនៅតំបន់ជនបទ មានកំរិតទាបជាងនៅទីប្រជុំជន ប៉ុន្តែបើយោងតាមការពិភាក្សាជាក្រុមឃើញថា គុណភាពសេវាអប់រំថ្នាក់បឋមសិក្សានៅតំបន់ទាំងពីរមានភាពខុសគ្នាស្រឡះ។ គ្រូបង្រៀននៅតំបន់ជនបទ មិនអាចផ្តល់សេវាអប់រំដល់សិស្សានុសិស្សឱ្យបានគ្រប់គ្រាន់នោះទេ ដោយហេតុថាពួកគាត់ ត្រូវចំណាយស្ទើរតែពាក់កណ្តាលនៃពេលវេលារបស់ដែលមានលើការងារកសិកម្ម។ ដូច្នេះឃើញថា ការណ៍ដែលគ្រូបង្រៀនពុំអាចលះបង់ពេលវេលាសំរាប់ផ្តោតតែទៅលើកាងារអប់រំតែមួយមុខ

នោះ គឺដោយសារកត្តាជីវភាពក្រីក្រ។ ផ្ទុយទៅវិញ គ្រូបង្រៀននៅតំបន់ទីប្រជុំជនមានលទ្ធភាពផ្តល់សេវាបានល្អប្រសើរជាងគ្រូតាមជនបទ ពីព្រោះពួកគាត់អាចរកប្រភពចំណូលបន្ថែមដែលបានមកពីការបង់កម្រៃក្រៅផ្លូវការ និងការបង្រៀនគួក្រៅម៉ោងផ្សេងៗ។

ការបង់កម្រៃក្រៅផ្លូវការនៅតំបន់ទីប្រជុំជន បង្កើតបានជាបន្ទុកមួយសំរាប់គ្រួសារនៅតំបន់នោះ បើទោះជាកម្រៃដែលត្រូវបង់មានបរិមាណតិចតួចក្តី។ ជាទូទៅ ប្រភេទកម្រៃក្រៅផ្លូវការដែលត្រូវបង់ញឹកញាប់ជាងគេរួមមានៈ

**តារាង ៣.២ៈ កម្រៃក្រៅផ្លូវការប្រចាំឆ្នាំនៅរាជធានីភ្នំពេញ (គិតជារៀល)**

| | |
|---|---|
| ថ្លៃចុះឈ្មោះចូលរៀន | ១ ២០០ |
| ថ្លៃទឹក និងភ្លើង | ២ ០០០ |
| ថ្លៃគ្រូទារប្រចាំថ្ងៃ | ៥០ ៨០០ |
| **សរុប** | **៥៤ ០០០** |

**ប្រភពៈ** *កិច្ចពិភាក្សាជាមួយគ្រូបង្រៀនថ្នាក់បឋមសិក្សា*

យោងតាមការសិក្សារបស់ធនាគារពិភពលោក[២១] ចំនួនប៉ាន់ស្មានសរុបប្រចាំឆ្នាំនៃកម្រៃក្រៅផ្លូវការនៅភ្នំពេញ (ដូចមានបង្ហាញក្នុងតារាង ៣.២) មានប្រមាណ ៤៣ ភាគរយនៃចំណាយមធ្យមសរុបរបស់គ្រួសារទៅលើការអប់រំថ្នាក់បឋមសិក្សា[២២] នៅតាមតំបន់ទីប្រជុំជនទាំងមូល។ ម្យ៉ាងទៀត ការរកឃើញដដែលនេះក៏បានបង្ហាញដែរថា បរិមាណចំណាយជាមធ្យមរបស់គ្រួសារទៅលើការអប់រំថ្នាក់បឋមសិក្សានៅតាមតំបន់ជនបទ មានទំហំតិចតួច (ប្រមាណ ៣៥ ០០០ រៀល)។ និយាយម្យ៉ាងទៀត កម្រៃក្រៅផ្លូវការសំរាប់ការអប់រំថ្នាក់បឋមសិក្សានៅតំបន់ជនបទមានកំរិតទាប[២៣]។

នៅទីប្រជុំជន កម្រៃក្រៅផ្លូវការក្នុងបរិមាណតិចតួចទាំងនោះ គឺជាឧបសគ្គយ៉ាងធំសម្រាប់កុមារដែលមកពីគ្រួសាទាល់ក្រ។ ក្រៅពីចំណាយទៅលើឯកសណ្ឋានសាលា និងសម្ភារៈសិក្សា គ្រួសាររបស់ពួកគេ

---

[២១] CSES ឆ្នាំ ២០០៤

[២២] ត្រូវបានគណនាដោយផ្អែកលើ ការចំណាយជាមធ្យមរបស់គ្រួសារ សម្រាប់ថ្នាក់ទី ១ និង ទី ៦

[២៣] បើទោះជាចំនួននេះមិនបានប្រៀបធៀបដោយផ្ទាល់ក្តី តាមលទ្ធផលស្រាវជ្រាវរបស់ ម.អ.ស ឆ្នាំ ២០០៥ បានបញ្ជាក់ថា : តម្លៃក្រៅផ្លូវការនៅតំបន់ជនបទ សំរាប់រាល់ការអប់រំសាធារណៈ មានប្រមាណតែ ១៥ ភាគរយនៃតំបន់ទីប្រជុំជន ។

មិនមានលទ្ធភាពចំណាយលើកម្រៃក្រៅផ្លូវការខាងលើនេះទេ។ ជាលទ្ធផល កុមារទាំងនោះមិនបានចូលរៀន បើទោះជាតាមផ្លូវច្បាប់ ពួកគេមានសិទ្ធចូលរៀនដោយឥតបង់ថ្លៃដ៏ដោយ ។ ទាក់ទងនឹងបញ្ហានេះ អ្នកចូលរួមក្រុមពិភាក្សានៅភ្នំពេញម្នាក់បានលើកឡើងថា *"ហេតុអ្វីបានជាពួកគេ(គ្រូបង្រៀន) នៅតែទារលុយពីសិស្ស បើការអប់រំនៅថ្នាក់បឋមសិក្សាមិនតម្រូវឱ្យបង់ថ្លៃអ្វីផងនោះ? ក្មេងមួយចំនួននៅភូមិខ្ញុំមិនបានចូលរៀនទេ ព្រោះថាគ្រួសាររបស់ពួកគេមានជីវភាពក្រីក្រ"* ។ គាត់បន្ថែមទៀតថា *" ខ្ញុំទទួលស្គាល់ថាប្រាក់ខែពួកគាត់ទាប ប៉ុន្តែខ្ញុំពិតជាធុញទ្រាន់នឹងគ្រូទាំងនោះណាស់។ មែនទែនទៅ ខ្ញុំមិនដឹងថាត្រូវបង់ប៉ុន្មាន ទេ ដើម្បីឱ្យកូនខ្ញុំបានរៀនស្រួលនោះ? "* ។

សរុបមក ឃើញថាកម្រៃក្រៅផ្លូវការនៅថ្នាក់បឋមសិក្សា ប្រមូលផ្តុំនៅតំបន់ទីប្រជុំជន ដែលនៅទីនោះជីវភាពរស់នៅ និងលទ្ធភាពក្នុងការចាយវាយរបស់ប្រជាជនមានកំរិតខ្ពស់ ។ផ្ទុយទៅវិញ ទន្ទឹមគ្នានឹងការណ៍ដែលកម្រៃក្រៅផ្លូវការនៅតាមតំបន់ជនបទមានចំនួនតិចតួច គុណភាពសេវានៅទីនោះ ក៏មានកំរិតទាបដែរ ដោយសារគ្រូបឋមសិក្សានៅជនបទអាចរកចំណូលបានតិត។ កង្វះប្រសិទ្ធភាពអប់រំនៅតាមជនបទផ្តល់ផលប៉ះពាល់អវិជ្ជមានច្រើនដល់កុមារនៅទីនោះ ដោយពួកគេមិនបានទទួលនូវការបង្រៀនដិតដល់ និងគ្រប់គ្រាន់ពីគ្រូ។ ការណ៍នេះ ជម្រុញឱ្យមានគំលាតកាន់តែធំលើការយល់ដឹងរបស់កុមាររវាងទីប្រជុំជន និងជនបទ។

### ៣.១.៣. *កម្រៃក្រៅផ្លូវការលើសេវាមណ្ឌលសុខភាព*

យោងតាមប្រកាសអន្តរក្រសួងមួយរបស់រាជរដ្ឋាភិបាល ៦០ ភាគរយ នៃថ្លៃសេវាសរុបដែលបង់ចូលមណ្ឌលសុខភាព ត្រូវផ្តល់ទៅឱ្យបុគ្គលិកដែលបំរើការនៅទីនោះ ៣៩ ភាគរយ ប្រើសំរាប់ការចំណាយផ្សេងៗ របស់មណ្ឌលសុខភាព និង ១ ភាគរយ ទៀត ត្រូវបង់ចូលថវិការដ្ឋ[២៤] ។ ដូចនេះ បើកាលណាមានប្រជាជនចូលទៅប្រើសេវាសុខភាពនៅទីនោះកាន់តែច្រើន នោះមណ្ឌលសុខភាពក៏អាចរកចំណូលបានកាន់តែច្រើន សំរាប់បែងចែកដល់បុគ្គលិកពេទ្យផងដែរ។ លើសពីនេះ បុគ្គលិកមណ្ឌលសុខភាពអាចរកចំណូលក្រៅបន្ថែម តាមរយៈការផ្តល់សេវាតាមផ្ទះ ដូចជាការបង្កើតកូន ចាក់ថ្នាំ និងរុំរបួសផ្សេងៗ។

[២៤] សេចក្តីប្រកាសអន្តរក្រសួង ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៥

**តារាង ៣.៣: តម្លៃផ្លូវការរបស់សេវាមណ្ឌលសុខភាព (គិតតាមចំនួនភាគច្រើន ជារៀល)**

| សេវា | ទីប្រជុំជន(១) | ជនបទ |
|---|---|---|
| **ការពិគ្រោះជម្ងឺទូទៅ** | | |
| កូនក្មេង | ១ 000 | ៥00 |
| មនុស្សពេញវ័យ | ១ 000 | ៥00 |
| ពិនិត្យកាមរោគ | ៣ 000 | ១ 000 |
| ពិនិត្យផ្ទៃពោះ | ១ 000 | ១ 000 |
| **ការពន្យារកំណើត** | | |
| ស្រោមអនាម័យ | ១ 000 | ១ 000 |
| ថ្នាំគ្រាប់ | ១ 000 | ១ 000 |
| ថ្នាំចាក់ | ១ 000 | ១ 000 |
| ការដាក់កង | ១0 000 | ៥ 000 |
| **ការព្យាបាលរបួស** | | |
| របួសតូច | ៣ 000 | ២ 000 |
| របួសធំ | ៥ 000 | ៥ 000 |
| **ការសម្រាលកូន** | | |
| ការសម្រាលកូនតាមធម្មតា | ៥0 000 | ១៥ 000 |

**កំណត់សម្គាល់:** *(១) រួមបញ្ចូលសង្កាត់ក្នុងរាជធានីភ្នំពេញ និង ឃុំតាមទីរួមខេត្តដទៃទៀត*

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

នៅតាមមណ្ឌលសុខភាព ពុំមានសញ្ញាញជាក់លាក់ណាមួយកំណត់ពីកម្រៃក្រៅផ្លូវការនោះទេ។ មូលហេតុគឺដោយសារទំហំសេវាកម្មនៅទីនោះមានកំរិតតូច ហើយតម្លៃដែលជាទូទៅទាបត្រូវបានគេបិទ-ផ្សាយជាសាធារណៈនៅតាមមណ្ឌលសុខភាពស្ទើរតែទាំងអស់។ លើសពីនេះទៀត ប្រជាជនប្រើប្រាស់សេវាមណ្ឌលសុខភាព ក៏ដោយសារតែពួកគាត់មិនមានលទ្ធភាពទៅកាន់មន្ទីរពេទ្យបង្អែក ឬគ្លីនិកឯកជន។ ដូចដែលអង្គការក្រៅរដ្ឋាភិបាលមួយនៅខេត្តកំពតបានលើកឡើង ឃើញថា *"(តម្លៃក្រៅផ្លូវការ) កម្រកើតមានណាស់ ព្រោះថាមណ្ឌលសុខភាពយកថ្លៃសេវាតែបន្តិចបន្តួចប៉ុណ្ណោះ ហើយសេវាទាំងនោះ ទៀតសោតក៏ស្ថិតក្នុងមួយតូចតាចដែរ...ចំពោះចំនួនលុយបន្តិចបន្តួច ដែលអ្នកជម្ងឺផ្តល់ឱ្យជាសារគុណនោះ យើងពិបាកនឹង ថាជា តម្លៃក្រៅផ្លូវការណាស់ ព្រោះពួកគាត់ពេញចិត្តនឹងផ្តល់ឱ្យដោយស្ម័គ្រចិត្ត* ។

ការចៀសវាងមិនប្រើប្រាស់សេវាសុខភាពសារធារណៈ និងកំរិតតូចតាចនៃកម្រៃក្រៅផ្លូវការនៅក្នុងសេវានេះ គឺដូចគ្នាទៅនឹងការរកឃើញរបស់ ម.អ.ស ក្នុងការស្រាវជ្រាវពីអំពើពុករលួយនៅឆ្នាំ ២០០៥។ ការស្រាវជ្រាវនៅឆ្នាំ២០០៥នេះបង្ហាញថា ត្រឹមតែ ៣១ ភាគរយ នៃអ្នកចូលរួមផ្តល់ចម្លើយប៉ុណ្ណោះ ដែលឆ្លើយថាធ្លាប់បានប្រើប្រាស់សេវាសុខភាពសាធារណៈ (នេះបើប្រៀបទៅនឹងការប្រើប្រាស់សេវាសុខភាព

ដែលផ្តល់ដោយឯកជនដែលមានដល់ទៅ ៩២ ភាគរយ) ហើយករណីដែលទំនងជាមានការបង់ប្រាក់សំណូក នោះមានត្រឹម ១៣ ភាគរយ ប៉ុណ្ណោះ។

## ៣.២. កម្រៃក្រៅផ្លូវការជាចំណូលបន្ថែមលើប្រាក់បៀវត្សរ៍

ដូចដែលបានលើកឡើងដោយអ្នកផ្តល់បទសសម្ភាសភាគច្រើនមូលហេតុចំបង ដែលនាំឱ្យមានកម្រៃក្រៅផ្លូវការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងតំរូវការខាងជីវភាពប្រចាំថ្ងៃរបស់មន្ត្រីឃុំ/សង្កាត់។ ក្នុងន័យនេះ ការបង់កម្រៃក្រៅផ្លូវការផ្តល់បានជាចំណូលបន្ថែមសំខាន់មួយទៅលើបៀវត្សន៍បច្ចុប្បន្នរបស់មន្ត្រី ជាពិសេស មន្ត្រីឃុំ/សង្កាត់ និងគ្រូបឋមសិក្សាតាមទីប្រជុំជន។

### *៣.២.១. មន្ត្រីឃុំ/សង្កាត់*

ផ្អែកលើទំហំនៃកម្រៃក្រៅផ្លូវការដែលប៉ាន់ស្មាននៅទូទាំងប្រទេស ទឹកប្រាក់ប្រមាណជា ៣៦ ដុល្លារក្នុងមួយខែ អាចជាចំណូលបន្ថែមលើបៀវត្សរ៍របស់មន្ត្រីឃុំ/សង្កាត់ ដែលបច្ចុប្បន្នមានចំនួនប្រហែល ១៨ ដុល្លារ[២៥]។ ប៉ុន្តែ បើផ្អែកលើចំនួនកម្រៃក្រៅផ្លូវការជាក់ស្តែងដែលឃុំ/សង្កាត់នីមួយៗទទួលបានចំនួនបន្ថែមនេះខុសគ្នាយ៉ាងខ្លាំងពីតំបន់ជនបទនិងទីប្រជុំជន។

ដោយឡែក នៅក្នុងការអនុវត្តជាក់ស្តែង ការបែងចែកប្រាក់ ក្រៅផ្លូវការទាំងនោះពុំបានធ្វើឡើងដោយស្មើភាពគ្នាដល់មន្ត្រីឃុំ/សង្កាត់ទាំងអស់នោះទេ ភាគច្រើនត្រូវចែកទៅឱ្យស្មៀននិងមេឃុំដែលជាអ្នកមានអំណាចរដ្ឋបាលច្រើនជាងគេ[២៦]។ ក្នុងចំនោមមន្ត្រីដែលទទួលកម្រៃក្រៅផ្លូវការដោយផ្ទាល់ ៣៦ ភាគរយ គឺសំដៅទៅលើស្មៀនឃុំ និង ២៩ ភាគរយ ទៀតទៅលើមេឃុំឬជំទប់ឃុំ។

ដូចនេះ បើគិតពីបៀវត្សរ៍បច្ចុប្បន្ន ឃើញថាកម្រៃក្រៅផ្លូវការជាទំហំបន្ថែមួយគួរឱ្យកត់សម្គាល់។ ដោយឡែក ក៏នឹងមានមធ្យោបាយផ្សេងទៀត ដែលអាចយកមកប្រើសំរាប់វាយតំលៃលើទឹកប្រាក់ដែលពាក់ព័ន្ធ។ ទាក់ទិននឹងកម្រៃក្រៅផ្លូវការក្នុងសេវាឃុំ/សង្កាត់ ទិដ្ឋភាពពីរបន្ថែមទៀតនឹងត្រូវធ្វើការសិក្សាក្នុងជំពូកបន្ទាប់។

---

[២៥] នេះបង្ហាញពីកំរិតបៀវត្សរ៍សមាជិកក្រុមប្រឹក្សាឃុំ និងស្មៀន

[២៦] យោងតាមសម្ភាសជាមួយអ្នកយល់ដឹងមួយចំនួន

**រូបភាព ៣.៣៖ ចំណូលប៉ាន់ស្មានប្រចាំខែរបស់មន្ត្រីឃុំ/សង្កាត់ (មធ្យម គិតជាដុល្លារ)**




ប្រភព៖ *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦ និង កម្មវិធីសីលា*

### ៣.២.២. គ្រូបង្រៀនបឋមសិក្សា

ដោយសារកម្រៃក្រៅផ្លូវការក្នុងវិស័យអប់រំថ្នាក់បឋមសិក្សាជាទូទៅកើតឡើងនៅទីប្រជុំជន ដូចជា នៅភ្នំពេញ និងទីរួមខេត្ត ករណីនៅរាជធានីភ្នំពេញត្រូវបានលើកយកមកសិក្សា ដើម្បីធ្វើការវិភាគ ស្ថានភាពរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជននិងរកមូលហេតុដែលនាំឱ្យមានកម្រៃក្រៅផ្លូវការ។ លើសពីនេះ ករណីសិក្សានេះ ក៏នឹងបង្ហាញឱ្យឃើញផងដែរពីរស្ថានភាពផ្សេងៗគ្នារវាងគ្រូតាមទីជនបទ និងទីប្រជុំជន។

បរិមាណសំរុបនៃកម្រៃក្រៅផ្លូវការក្នុងសេវាបឋមសិក្សានៅភ្នំពេញ មានប្រមាណ ២លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំ (សូមមើលឯកសារភ្ជាប់ទី ២ ពីវិធីគណនា)។ និយាយម្យ៉ាងទៀត គ្រូបឋមសិក្សាម្នាក់នៅភ្នំពេញអាចរកបានប្រហែលជា ៤៦ ដុល្លារក្នុង ១ខែ ពីចំណូលក្រៅផ្លូវការ។ ក្រៅពីនេះ គ្រូបឋមសិក្សាម្នាក់ ជាទូទៅអាចរកបានប្រហែលជា ៧៥ ដុល្លារក្នុង១ខែ ពីការបង្រៀនគួរបន្ថែម។ សរុបមក គ្រូបឋមសិក្សានៅភ្នំពេញអាចមានប្រភពចំនូលបីសំខាន់ ៖ បៀវត្សរ៍ផ្លូវការ កំរៃក្រៅផ្លូវការ និងការបង្រៀន គួរបន្ថែម។

តាមរយៈរូបភាព ៣.៤ ចំណូលសរុបរបស់គ្រូបឋមសិក្សាដែលបានមកពីប្រភពចំបងទាំង៣នេះ មានប្រហែល ១៥០ ដុល្លារក្នុង ១ខែ។ ក្រៅពីប្រភពទាំងនេះ គ្រូមួយចំនួនអាចរកប្រាក់បន្ថែមពីប្រភពផ្សេងខ្លះទៀត ដូចជារត់ម៉ូតូឌុប លក់ដូរនំចំណីតាមសាលាជាដើម។ បន្ថែមលើនេះ គួរកត់សំគាល់ផងដែរ

ថា ចំណូលពីការបង្រៀនគួរបន្ថែមមានប្រហែល ៥០ ភាគរយ នៃចំណូលសរុប ហើយប្រៀវត្សរ៍ផ្លូវការមានតែ ២០ ភាគរយប៉ុណ្ណោះ។

**រូបភាព ៣.៤: ប្រភពចំបងៗនៃចំណូលរបស់គ្រូបឋមសិក្សានៅភ្នំពេញ**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ឆ្នាំ ២០០៦*

ដោយឡែក ការស្រាវជ្រាវបង្ហាញឱ្យឃើញថា គ្រូនៅទីប្រជុំជនក្នុងចំនួនត្រឹមតែ ៣៣ភាគរយ និងគ្រូតាមជនបទត្រឹមតែ ៩ភាគរយប៉ុណ្ណោះដែលអាចបង្រៀនគួរបន្ថែមដើម្បីរកកម្រៃបង្គ្រប់លើប្រៀវត្សរ៍របស់ពួកគាត់។ ទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីតួនាទីចំបង នៃកម្រៃក្រៅផ្លូវការ និងមធ្យោបាយទាប់បន្សំដទៃទៀត នៅក្នុងការស្វែងរកប្រាក់ចំណូលរបស់គ្រូបង្រៀន។

**រូបភាព ៣.៥: ភាគរយនៃគ្រូបឋមសិក្សាដែលបង្រៀនគួរបន្ថែមដើម្បីបង្គ្រប់ប្រៀវត្សរ៍របស់ខ្លួន**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

## ៣.៣. តម្លៃក្រៅផ្លូវការ និងថវិការឃុំ/សង្កាត់

ក្នុងនាទីជារដ្ឋបាលវិមជ្ឈការ ឃុំ/សង្កាត់ទទួលបានប្រភពចំណូលផ្លូវការបីសំខាន់ៈ ប្រាក់វិភាជផ្ទេរពីរដ្ឋាភិបាលកណ្តាល ចំណូលផ្ទាល់ខ្លួន និងប្រាក់បដិភាគចូលរួមចំណែកពីប្រជាពលរដ្ឋតាមមូលដ្ឋាន។ យ៉ាងណាក្តី ប្រព័ន្ធហិរញ្ញវត្ថុឃុំ/សង្កាត់នាពេលបច្ចុប្បន្នពឹងផ្អែកយ៉ាងខ្លាំងទៅលើថវិកាដែលផ្ទេរមកពីរដ្ឋបាលកណ្តាល ខណៈពេលដែលប្រភពពីរទៀតនៅទន់ខ្សោយនៅឡើយដោយសារតែមូលហេតុផ្លូវច្បាប់ និងការអនុវត្តមួយចំនួន។

ក្នុងឆ្នាំ២០០៦ ថវិកាដែលផ្ទេរពីរដ្ឋាភិបាលកណ្តាលទៅឱ្យឃុំ/សង្កាត់ទាំង ១៦២១ មានប្រមាណ ១៩ លានដុល្លារ ។ ១ ភាគ ៣នៃថវិកានេះប្រើសំរាប់ចំណាយរដ្ឋបាល ហើយចំណែកដែលនៅសល់សំរាប់ការងារ អភិវឌ្ឍមូលដ្ឋាន។ ចំនួនថវិកាជា មធ្យមដែលផ្ទេរទៅឱ្យឃុំនីមួយៗមានប្រហែល ១១ ៧០០ ដុល្លារ ដែលក្នុងនោះ ៨១០០ដុល្លា ប្រើសំរាប់ការអភិវឌ្ឍមូលដ្ឋាន និង ៣៦០០ ដុល្លារទៀតសំរាប់ចំណាយរដ្ឋបាល ដែលរួមទាំងបៀវត្សរ៍មន្ត្រីផងដែរ។

**ថវិកាឃុំ/សង្កាត់នីមួយៗក្នុងឆ្នាំ ២០០៦ គិតជាមធ្យម (ដុល្លារអាមេរិក)**

| | សង្កាត់ នៅភ្នំពេញ | ឃុំ ទីរួមខេត្ត | ឃុំ ទីរួមស្រុក | ឃុំ ដាច់ស្រយ៉ាល |
|---|---|---|---|---|
| **ប្រាក់វិភាជផ្ទេរពីថវិកាជាតិ** | **១១ ៧០០** | **១១ ៧០០** | **១១ ៧០០** | **១១ ៧០០** |
| *បៀវត្សរ៍បុគ្គលិកឃុំ* | *១ ៧៨០* | *១ ៧៨០* | *១ ៧៨០* | *១ ៧៨០* |
| *ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗ* | *១ ៨២០* | *១ ៨២០* | *១ ៨២០* | *១ ៨២០* |
| *អភិវឌ្ឍន៍មូលដ្ឋាន* | *៨ ១០០* | *៨ ១០០* | *៨ ១០០* | *៨ ១០០* |
| **ចូលរួមដោយប្រជាជនមូលដ្ឋាន** | **៩ ១០០** | **៦ ២១០** | **៣ ៥២០** | **២ ០៥០** |
| *ប្រាក់បដិភាគ* | *៦៦០* | *៤១០* | *២៥០* | *២៥០* |
| *តម្លៃផ្លូវការ* | *៤៤០* | *៣០០* | *១៧០* | *១០០* |
| *តម្លៃក្រៅផ្លូវការ (*)* | *៨ ០០០* | *៥ ៥០០* | *៣ ១០០* | *១ ៧០០* |
| **សរុប** | **២០ ៨០០** | **១៧ ៩១០** | **១៥ ២២០** | **១៣ ៧៥០** |
| **%នៃតម្លៃក្រៅផ្លូវការលើថវិកាសរុប** | ៣៨% | ៣១% | ២០% | ១២% |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦ និង កម្មវិធីសីលា*

*(*) មិនបញ្ចូលកំរៃពីតម្លៃលើការផ្ទេរកម្មសិទ្ធិដីធ្លី*

បច្ចុប្បន្ន កំរៃដែលប្រមូលបានពីសេវាចុះបញ្ជីអាត្រានុកូលដ្ឋានបង្កើតបានជាប្រភពចំណូលផ្ទាល់ចំបងមួយរបស់ឃុំ/សង្កាត់ ខណៈពេលដែលក្របខណ្ឌច្បាប់មិនទាន់បានកំណត់ឱ្យបានច្បាស់ថាតើថ្លៃសេវាមូលដ្ឋានណាទៀតអាចប្រមូលបានដោយការិយាល័យឃុំ/សង្កាត់[២៧] ។ កំរៃផ្លូវការទាំងនេះជាទូទៅត្រូវបានប្រើឧបត្ថម្ភបន្ថែមលើចំណាយរដ្ឋបាលរបស់ឃុំ/សង្កាត់។ ជាមធ្យម កម្រៃផ្លូវការប្រចាំឆ្នាំ ដែលប្រមូលដោយឃុំនីមួយៗ មានចំនួនប្រហែល ៤៤០ ដុល្លារ នៅរាជធានីភ្នំពេញ ៣០០ ដុល្លារ នៅទីរួមខេត្ត ១៧០ ដុល្លារ នៅទី រួមស្រុក និង ១០០ ដុល្លារ នៅតំបន់ជនបទ។

ប្រភពចំណូលមួយទៀតដែលបានពីការចូលរួមបដិភាគដោយប្រជាជននោះ ជាទូទៅត្រូវបានប្រើជាមូលនិធិបន្ថែមសំរាប់គម្រោងអភិវឌ្ឍមូលដ្ឋាន ។ ចំណែកនៃប្រាក់បដិភាគ ដែលបង់ចូលក្នុងគម្រោងអភិវឌ្ឍនីមួយៗ ជាមធ្យមមានប្រមាណ ៨ ភាគរយ នៅតាមសង្កាត់ក្នុងរាជធានីភ្នំពេញ ៥ ភាគរយ នៅតាមឃុំក្នុងទីរួមខេត្ត និង ៣ ភាគរយ នៅតាមទីរួមស្រុក និងតំបន់ជនបទ ។

ក្រៅពីចំណូឡផ្លូវការទាំងនេះកម្រៃក្រៅផ្លូវការផ្តល់បានជាចំនែកយ៉ាងសំខាន់មួយ បើរាប់បញ្ចូលទៅក្នុងថវិកាឃុំ/សង្កាត់ទាំងមូល។ ជាទូទៅ ចំណែកនៃកម្រៃក្រៅផ្លូវការមានកំរិតខ្ពស់តាមសង្កាត់ក្នុងរាជធានីភ្នំពេញ (៣៨ ភាគរយ) ហើយថយចុះនៅតាមទីរួមខេត្ត (៣១ ភាគរយ) ទីរួមស្រុក (២០ ភាគរយ) និងតំបន់ជនបទ (១២ ភាគរយ)។

## ៣.៤. កម្រៃក្រៅផ្លូវការ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន

ថ្វីត្បិតតែកម្រៃក្រៅផ្លូវការត្រូវបានគេមើលឃើញនៅគ្រប់ទីកន្លែងក្នុងសេវាឃុំ/សង្កាត់ ជាទូទៅលទ្ធផលនៃការស្រាវជ្រាវមិនបានរកឃើញថា កម្រៃក្រៅផ្លូវការទាំងនេះមានផលប៉ះពាល់ខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននោះទេ។ ជាមធ្យមក្នុងមួយឆ្នាំប្រជាជនម្នាក់បង់ប្រហែលជា ៩ ០០០ រៀល (២,២៥ ដុល្លារ) ទៅឱ្យការិយាល័យឃុំ/សង្កាត់ជាកម្រៃក្រៅផ្លូវការ។ បើធៀបនឹងចំណាយប្រចាំឆ្នាំរបស់ពួកគេ ចំណែកជាមធ្យមនៃកម្រៃក្រៅផ្លូវការដែលបង់ដោយប្រជាជន ម្នាក់ៗមានទំហំខុសគ្នារវាងតំបន់ជនបទ និងទីប្រជុំជន ពោលគឺ ០,២ភាគរយ នៅជនបទ និង ០,៥ភាគរយ នៅទីរួមខេត្ត/ក្រុង។

---

[២៧] យោងតាមក្រសួងមហាផ្ទៃ ប្រភេទសេវា និងតម្លៃផ្លូវការដទៃទៀតកំពុងត្រូវបានរៀបរៀងឡើង នៅក្នុងដំណើរការនៃការតាក់តែងច្បាប់ស្តីពីវិមជ្ឈការនិងវិសហមជ្ឈការសំរាប់រដ្ឋបាលក្រោមថ្នាក់ជាតិ

**រូបភាព ៣.៦: ភាគរយនៃកម្រៃក្រៅផ្លូវការធៀបនឹងចំណាយរបស់ប្រជាជន**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា សីហា ២00៦*

រូបភាពខាងលើ បង្ហាញពីការប្រៀបធៀបរវាងចំណាយក្រៅផ្លូវការដោយប្រជាជនទៅឱ្យរដ្ឋបាលថ្នាក់ឃុំ/សង្កាត់ (ផ្អែកលើលទ្ធផលនៃការសិក្សានេះ) និងចំណាយក្រៅផ្លូវការលើសេវាសាធារណៈដទៃទៀត (ផ្អែកលើរបកគំហើញក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលអភិវឌ្ឍសង្គម ឆ្នាំ ២00៥) ដោយធៀបទៅនឹងចំណាយសរុបប្រចាំឆ្នាំរបស់ប្រជាជន ។

គួរកត់សំគាល់ដែរថា ការស្ទង់មតិនេះ បានប្រព្រឹត្តទៅនៅក្នុងកំឡុងពេលយុទ្ធនាការចុះបញ្ជីអាត្រានុកូលដ្ឋានដែលតម្រូវឱ្យប្រជាជនគ្រប់រូបទៅចុះបញ្ជីនៅការិយាល័យឃុំ/សង្កាត់ ។ ដូចនេះ ឃើញថាតួលេខខាងលើ អាចនឹងថយចុះនៅក្នុងកំឡុងពេលធម្មតា ដោយសារចំនួននៃការចូលទៅប្រើសេវាដោយប្រជាជនចុះទាប[២៨] ។

បើទោះជាកម្រៃក្រៅផ្លូវការមានភាគរយទាបក្នុងការចំណាយរបស់ប្រជាជនក្តី ក៏ពុំមែនមានន័យថា ប្រជាជនមើលរំលងពិទំហំទឹកប្រាក់ទាំងនោះឡើយ ។ ឆ្លើយតបទៅនឹងសំណួរថាតើពួកគាត់ចាត់ទុកការចំណាយលើសេវាទាំងបីដែលជាកម្មវត្ថុនៃការសិក្សានេះធ្ងន់ធ្ងរប៉ុណ្ណាដែរនោះ ជាង ៤0 ភាគរយនៃអ្នកផ្តល់ចម្លើយយល់ឃើញថាជាបន្ទុកធ្ងន់ធ្ងរសំរាប់ពួកគាត់ ។ ដោយពិតទៅសំណួរនេះរួមបញ្ចូលទាំងការចំណាយ

---

[២៨] សេវាដែលជាកម្មវត្ថុនៃការសិក្សាមិនក៏រិតយកត្រឹមតែសេវាចុះបញ្ជីអាត្រានុកូលដ្ឋានប៉ុណ្ណោះទេ ពោលគឺរួបបញ្ចូលទាំសេវាផ្លូវការនិងក្រៅផ្លូវការដទៃទៀតដែលផ្តល់ដោយការិយាល័យឃុំ/សង្កាត់ទៅឱ្យប្រជាជន ។

លើសេវាមណ្ឌលសុខភាពដែលភាគច្រើនជាការចំណាយផ្លូវការ ប៉ុន្តែក៏រួមមានការចំណាយលើការអប់រំថ្នាក់បឋមសិក្សា និងសេវាឃុំ/សង្កាត់ ដែលនៅទីនោះការចំណាយរបស់ពួកគាត់ច្រើនជាចំណាយក្រៅផ្លូវការ ។ ដោយឡែក បើមើលពីជ្រុងម្ខាងទៀតនៃចម្លើយដែលទទួលបាន ឃើញថាតួលេខដ៏គួរឱ្យចាប់អារម្មណ៍មួយបង្ហាញឱ្យឃើញថា ជិត៦០ភាគរយនៃអ្នកផ្តល់ចម្លើយគេចាត់ទុកការចំណាយទាំងនេះល្មមនឹងទទួលយកបាន ឬក៏ថាមិនធ្ងន់ធ្ងរទេ។ ផលប៉ះពាល់ដែលកើតចេញពីការយល់ឃើញទាំងនេះនឹងមានបកស្រាយបន្ថែមក្នុងផ្នែកបន្ទាប់ ។

**រូបភាព ៣.៧: តើការចំណាយលើសេវាទាំងបី មានភាពធ្ងន់ធ្ងរប៉ុណ្ណាធៀបនឹងចំណូលរបស់ប្រជាពលរដ្ឋ?**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

# ជំពូកទី ៤

# ជំហានបន្ទាប់ឆ្ពោះទៅសេវាសាធារណៈថ្នាក់មូលដ្ឋាន ប្រកបដោយប្រសិទ្ធភាពៈ ទស្សនៈរបស់អ្នកដែលពាក់ព័ន្ធ

ដើម្បីធានាថាសេវាសាធារណៈថ្នាក់មូលដ្ឋាន នឹងត្រូវបានផ្តល់ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងដោយគ្មានចំណាយក្រៅផ្លូវការ ការតម្លើងប្រាក់បៀវត្សរ៍មន្ត្រីមូលដ្ឋានជាលក្ខខណ្ឌ ចាំបាច់មិនអាចខ្វះបាន។ នៅពេលដែលមានបៀវត្សរ៍គ្រប់គ្រាន់ហើយ ការកសាងសមត្ថភាពរបស់ពួកគាត់ និងការកសាងហេដ្ឋា រចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន គឺត្រូវបានគេចាត់ទុកថាជាជំហ៊ានបន្ទាប់ដែលត្រូវធ្វើ។ ជាចុងក្រោយ វិធានការច្បាប់ និងរដ្ឋបាល ដូចជាផែនការលើកទឹកចិត្ត ការផ្លាស់ប្តូរមន្ត្រីរាជការពីកន្លែងមួយទៅកន្លែងមួយទៀត និង គោលនយោបាយរក្សាមន្ត្រីដែលមានសមត្ថភាព គួរតែបង្កើតឡើង និងអនុវត្តឱ្យមានប្រសិទ្ធភាព ដើម្បីធានា ឱ្យបាននូវក្រមសីលធម៌ការងារមួយដ៏ល្អ។

## ៤.១. សេវាឃុំ/សង្កាត់

### *៤.១.១. ការកំណត់តម្លៃផ្លូវការសំរាប់សេវាកម្ម និងបង្កើនប្រាក់ខែបុគ្គលិក*

ដោយឆ្លើយនឹងសំណួរដែលថា តើបៀវត្សរ៍ប៉ុន្មានគ្រប់គ្រាន់សម្រាប់ការរស់នៅដ៏សមរម្យមួយ មន្ត្រី ឃុំ/សង្កាត់ភាគច្រើនបានឆ្លើយថា យ៉ាងតិចបំផុត ១០០ ដុល្លារអាមេរិក ក្នុង ១ ខែ ទើបពួកគាត់អាចធានា បាននូវកម្រិតជីវភាពស្តង់ដារថ្នាក់មូលដ្ឋានមួយ។ ចំណែកឯតួលេខនៃកម្រិតប្រាក់ខែស្នើឡើង មានចាប់ ពី ៥០ ដុល្លារ ដល់ ២៥០ ដុល្លារអាមេរិក។ ជាទូទៅ ប្រាក់ខែដែលបានស្នើឡើងនេះ មានកំរិតខ្ពស់ នៅទីប្រជុំជនជាង នៅទីជនបទ។

អនុសាសន៍ជាច្រើនស្តីអំពីការរិះរកមធ្យោបាយដើម្បីបង្កើនបៀវត្សរ៍មន្ត្រីឃុំ/សង្កាត់ ត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធមួយចំនួន។ បន្ថែមលើសពីនេះទៀត ការព្រួយបារម្ភអំពីរយុទ្ធសាស្ត្រដើម្បីពង្រឹងប្រព័ន្ធហិរញ្ញវត្ថុដ៏ទន់ខ្សោយរបស់អាជ្ញាធរមូលដ្ឋានក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។ ជាទូទៅ អនុសាសន៍ទាំងនោះបានបាញ់ឆ្ពោះទៅរកជំរើស ៣ គឺ ៖ ធ្វើឱ្យចំណាយក្រៅផ្លូវការទៅជាផ្លូវការពង្រីកមូលនិធិគាំទ្រពីថវិការជាតិ និងពង្រឹងប្រភពចំណូលផ្ទាល់ខ្លួនរបស់ឃុំ/សង្កាត់តាមរយៈការពង្រីកសកម្មភាពសេវាកម្មនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការធ្វើឱ្យចំណាយក្រៅផ្លូវការទៅជាផ្លូវការត្រូវបានចាត់ទុកថាគឺជាជំរើសដ៏ល្អមួយ ព្រោះមិនគ្រាន់តែដើម្បីផ្តល់ការរួមចំណែកបន្ថែមដល់ថវិកាឃុំ/សង្កាត់ប៉ុណ្ណោះទេ គឺថែមទាំងធ្វើឱ្យដំណើរការទូទាត់

និងបែបបទនៃការគ្រប់គ្រងកាន់តែមានតម្លាភាពថែមទៀត។ អង្គការក្រៅរដ្ឋាភិបាលមួយនៅខេត្តបាត់ដំបង បានលើកឡើងមកថា *"ការធ្វើឱ្យទៅជាផ្លូវការនូវចំណាយក្រៅផ្លូវការនឹងធ្វើឱ្យមានភាពយុត្តិធម៌ក្នុងការបែងចែកចំណូលទៅឱ្យបុគ្គលិកឃុំ/សង្កាត់ទាំងអស់ និងអាចជៀសផុតបញ្ហាដែលកើតមានដូចសព្វថ្ងៃ ដែលមានតែអ្នកមានអំណាចនៅក្នុងឃុំ/សង្កាត់ប៉ុណ្ណោះដែលទទួលបានកម្រៃក្រៅផ្លូវការ"*។

មន្ត្រីឃុំ/សង្កាត់ភាគច្រើនយល់ស្របចំពោះការធ្វើឱ្យទៅជាផ្លូវការនូវចំណាយក្រៅផ្លូវការនេះដែរ តែពួកគាត់បានសំដែងការបារម្ភថា តើរដ្ឋាភិបាលនឹងអនុញ្ញាតឱ្យប្រើប្រាស់លុយទាំងនោះក្នុងគោលបំណងតម្លើងប្រាក់បៀវត្សរ៍ដែរឬទេ។ មន្ត្រីឃុំ/សង្កាត់ម្នាក់នៅពោធិសាត់បានលើកឡើងថា *"បើយើងឱ្យប្រជាជនបង់លុយបន្ថែមយើងច្បាស់ថាកម្រៃទាំងនោះនឹងអាចឱ្យយើងទិញបារី ឬរបស់របរផ្សេងទៀតបាន។ ប៉ុន្តែបើកម្រៃទាំងនោះត្រូវបានដាក់ឱ្យក្លាយជាផ្លូវការ ខ្ញុំមិនច្បាស់ថាតើរដ្ឋាភិបាលនឹងប្រើប្រាស់កម្រៃទាំងនោះសម្រាប់តម្លើងបៀវត្សរ៍ពួកយើងនោះទេ"*។

ប្រជាជនភាគច្រើនយល់ព្រមបង់ប្រសិនបើគេដាក់ចំណាយក្រៅផ្លូវការឱ្យទៅជាផ្លូវការ ដោយពួកគេមិនចាំបាច់បង់អ្វីក្រៅពីនេះទៀតឡើយ។ ចំពោះការយល់ព្រមនេះ អ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុមម្នាក់និយាយថា *"អស្ចារ្យ វាយុត្តិធម៌ដែលអ្នករាល់គ្នាបង់លុយដូចគ្នា និងវាងាយស្រួលដល់យើងត្រៀម ទុកជាមុននូវទឹកប្រាក់ដែលត្រូវបង់សម្រាប់សេវាដែលយើងត្រូវការ"*។

**រូបភាព ៤.១: ភាគរយប្រជាពលរដ្ឋដែលយល់ព្រមបង់ចំណាយក្រៅផ្លូវការដែលដាក់ឱ្យទៅជាផ្លូវការ**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

ប៉ុន្តែ ប្រជាជនមានការប្រុងប្រយ័ត្នយ៉ាងខ្លាំងចំពោះចំនួនទឹកប្រាក់ដែលត្រូវបង់ ដោយបានស្នើថា កម្រៃដែលនឹងក្លាយជាផ្លូវការនោះ គួរត្រូវកំណត់នៅចំនួនមួយដែលប្រជាជនគ្រប់រូបអាចមានលទ្ធភាពបង់

បានគ្រប់ៗគ្នា ។ ផ្នែកកម្រិតតម្លៃផ្លូវការស្នើឡើងដោយអ្នកប្រើប្រាស់សេវាដែលបានចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម ជាមធ្យម គឺស្មើនឹង ៥០ ភាគរយ នៃចំនួនទឹកប្រាក់ដែលពួកគាត់បានបង់នាពេលបច្ចុប្បន្ន ។ តម្លៃនេះ គឺអាចទទួលយកបានសម្រាប់ដំណើរការដាក់តម្លៃក្រៅផ្លូវការឱ្យទៅជាផ្លូវការ ។

**តារាង ៤.១: កម្រៃផ្លូវការ និងតម្លៃស្នើឡើងសំរាប់សេវាតាមឃុំនីមួយៗ (រៀល)**

| សេវា | តម្លៃផ្លូវការ | ទីប្រជុំជន | | ជនបទ | |
|---|---|---|---|---|---|
| | | តម្លៃបង់ពិតប្រាកដ | តម្លៃស្នើឡើង | តម្លៃបង់ពិតប្រាកដ | តម្លៃស្នើឡើង |
| **សំបុត្រកំណើត** | ៤០០ | ៥ ០០០ | ២ ២០០ | ៥ ០០០ | ១ ០០០ |
| **លិខិតអាពាហ៍ពិពាហ៍** | ៤០០ | ២០ ០០០ | ៨ ៥០០ | ២០ ០០០ | ៨ ០០០ |
| **សំបុត្រមរណះភាព** | ៤០០ | ៧ ៥០០ | ៤ ០០០ | ៥ ០០០ | ២ ៦០០ |
| **ចម្លងសំបុត្រកំណើត** | ២១០០ | ៥ ០០០ | ២ ៣០០ | ៥ ០០០ | ២ ០០០ |
| **ចម្លងលិខិតអាពាហ៍ពិពាហ៍** | ៥៧០០ | ១៦ ០០០ | ៥ ៥០០ | ១៦ ០០០ | ៤ ១០០ |
| **ចម្លងលិខិតមរណភាព** | ២៤០០ | ២០០០ | ២ ០០០ | ២ ០០០ | ១ ៧០០ |
| **លិខិតប្រកាសអាពាហ៍ពិពាហ៍** | ២២០០ | ២០ ០០០ | ១០ ០០០ | ២០ ០០០ | ១១ ៧០០ |
| **លិខិតបញ្ជាក់ទីលំនៅ** | - | ១០ ០០០ | ៤ ៥០០ | ៧ ០០០ | ៣ ០០០ |
| **លិខិតបញ្ជាក់កិរិយាមាយាទ** | - | ៥ ០០០ | ៥ ០០០ | ៥ ០០០ | ៥ ០០០ |
| **លិខិតអនុញ្ញាតឱ្យសាងសង់** | - | ៨៥ ០០០ | ៣២ ០០០ | ២០ ០០០ | ៥ ០០០ |
| **លិខិតកាន់កាប់ដីធ្លី** | - | ៥០ ០០០ | ១៥ ០០០ | ២៨ ០០០ | ១០ ០០០ |
| **ការផ្សះផ្សាជំលោះ** | - | ១៨ ០០០ | ១០ ០០០ | ១៥ ០០០ | ៥ ០០០ |
| **ការដឹងឮកិច្ចសន្យា** | - | ១០ ០០០ | ១០ ០០០ | ៥ ០០០ | ៥ ០០០ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

តម្លៃដែលនឹងដាក់ឱ្យទៅជាផ្លូវការនឹងមិនគ្រប់គ្រាន់ សម្រាប់ការផ្គត់ផ្គង់តម្រូវការមូលដ្ឋានរបស់បុគ្គលិកគ្រប់គ្នានៅឡើយទេ ជាពិសេសឃុំ/សង្កាត់ជាច្រើននៅតាមទីជនបទដែលការផ្តល់សេវាមានកម្រិតតិចតួច។ ទន្ទឹមនឹងនេះដែរ ឃុំ/សង្កាត់ខ្លះនៅទីរួមខេត្ត និងភ្នំពេញ បានទទួលស្គាល់ថាបុគ្គលិករបស់ខ្លួននិងរស់នៅក្នុងកម្រិតជីវភាពមួយអប្បបរមា បើសិនជាកម្រៃទាំងនោះត្រូវបានដាក់ឱ្យទៅជាផ្លូវការ។

ឆន្ទៈរបស់ប្រជាជនក្នុងការកែលំអរគុណភាពនៃការផ្តល់សេវាកម្មនៅថ្នាក់មូលដ្ឋាន មិនមានត្រឹមតែកម្រិតសម្រាប់ចំណាយដែលដាក់ឱ្យទៅជាផ្លូវការនោះទេ គឺថែមទាំងមានសន្ទុះខ្លាំងឈានទៅរកការចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋានទៀតផង។ ស្ទើតែ ៩០ ភាគរយនៃអ្នកចូលរួម បានយល់ព្រមបង់វិភាគទានដល់មូលនិធិអភិវឌ្ឍន៍ឃុំ/សង្កាត់។ របបគំហើញនេះ បានរំលឹកឡើងវិញពីលទ្ធផលនៃការអង្កេតឆ្នាំ ២០០៤ របស់អង្គការមូលនិធិអាស៊ី និងមជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ អំពីប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។

**រូបភាព ៤.២: ភាគរយនៃចំនួនគ្រួសារដែលយល់ព្រមចូលរួម**
**បង់ប្រាក់បដិភាគដើម្បីអភិវឌ្ឍន៍មូលដ្ឋាន**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

លើសពីនេះទៀត ការសិក្សានេះបានបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់ប្រហែលជាងពាក់កណ្តាលយល់ព្រមបង់ប្រាក់ប្រមាណជាតិចជាង ១០ ភាគរយនៃថ្លៃរបស់គម្រោងអភិវឌ្ឍន៍នីមួយៗនៅមូលដ្ឋាន និងប្រហែលជា ១ ភាគ ៣ ផ្សេងទៀត យល់ព្រមចូលរួមបង់បដិភាគរហូតដល់ ២០ ភាគរយ។

ចំនួនភាគរយនេះខ្ពស់ជាងកម្រិតបដិភាគជាក់ស្តែង ដែលបានបង់សម្រាប់ការអភិវឌ្ឍ សហគមន៍បច្ចុប្បន្ន ដែលមានពី ៣ ទៅ ៨ ភាគរយ នៃថ្លៃគម្រោង។

**រូបភាព ៤.៣ៈ លទ្ធភាពក្នុងចូលរួមជាប្រាក់បដិភាគរបស់ប្រជាជនដើម្បីអភិវឌ្ឍន៍មូលដ្ឋាន**




**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា- សីហា ២០០៦*

គ្រប់សូចនាករទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ដោយបានបង្ហាញពីការយល់ស្របដល់ការសន្មត់មុនៗដែលថា ប្រជាពលរដ្ឋកម្ពុជាមានជំនឿទុកចិត្តគ្រប់គ្រាន់លើរដ្ឋបាលគ្រប់គ្រងថ្នាក់មូលដ្ឋាននេះ ដើម្បីជាការពិសោធន៍លើគោលនយោបាយក្នុងការលុបបំបាត់កម្រៃក្រៅផ្លូវការ ។ ការវាយតម្លៃលើភាពសុច្ចរិតនៃអ្នកបម្រើសេវាសាធារណៈទាំងបី ដែលបានបង្ហាញភាពអវិជ្ជមាន ចំពោះភាពស្មោះត្រង់របស់អជ្ញាធរឃុំ/សង្កាត់ បើធៀបទៅនឹងមន្ត្រីបម្រើសេវាពីរផ្សេងទៀត (សូមមើលតារាង ១.៣) គឺហាក់ដូចជាមិនបានបង្ហាញពីការមិនទុកចិត្តដែលរារាំងដល់ការអនុវត្តក្រមសាធារណៈ ដើម្បីបង្កើនប្រាក់ចំណូលផ្លូវការសម្រាប់ឃុំ/សង្កាត់នោះឡើយ។

ទោះបីជាយ៉ាងណា អជ្ញាធរឃុំនៅតាមជនបទភាគច្រើនមិនមានទំនុកចិត្តគ្រប់គ្រាន់ថា ខ្លួនអាចបន្តរស់នៅបានដោយគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលកណ្តាលឡើយ បើទោះជាប្រភពចំណូលផ្សេងៗទៀត ត្រូវបានផ្តល់ឱ្យដោយច្បាប់នៅក្នុងបរិបទនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏ដោយ។ នេះគឺ បណ្តាលមកពីសកម្មភាពសេដ្ឋកិច្ច នៅតាមមូលដ្ឋានរបស់ឃុំទាំងនោះនៅមានភាពទន់ខ្សោយ ហើយសមត្ថភាពរបស់បុគ្គលិកឃុំក៏នៅទន់ខ្សោយនៅឡើយ។ ផ្ទុយទៅវិញ បុគ្គលិកឃុំ/សង្កាត់នៅតាមទីក្រុង និងទីរួមខេត្តនានាមួយចំនួនមានជំនឿថា ឃុំ/សង្កាត់របស់ខ្លួនអាចឈរបានដោយខ្លួនឯង បើទោះជាគ្មានការផ្ទេរមូលនិធិពីរដ្ឋាភិបាលកណ្តាលក្តី ប្រសិនបើពួកគាត់ត្រូវបានផ្តល់អំណាចឱ្យប្រមូលថ្លៃឈ្នួលពីអ្នកប្រើ

ប្រាស់សេវាផ្សេងៗ និងពន្ធនៅតាមមូលដ្ឋាន ដែលកំណត់ដោយច្បាប់អង្គការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលនឹងមកដល់នាពេលឆាប់ៗនេះ។

ទោះបីជាយ៉ាងណា ឃុំ/សង្កាត់ទាំងអស់ជឿជាក់ថា ការពង្រីកសេវាកម្មឱ្យកាន់តែច្រើននឹងផ្តល់លទ្ធភាពចូលរួមវិភាគទានដ៏ច្រើនលើសលុបថែមទៀតដល់ថវិកានៅតាមមូលដ្ឋានរបស់ខ្លួន។ ខណៈដែលឃុំ/សង្កាត់នៅតាមទីប្រជុំជនជឿថា ពួកគាត់អាចរ៉ាប់រងធ្វើបានដោយស្វ័យភាពនូវរាល់សេវាកម្មតាមមូលដ្ឋានទាំងអស់ប្រសិនបើច្បាប់អនុញ្ញាតិនោះ ឃុំនៅតាមជនបទភាគច្រើនស្នើឱ្យមានជំនួយលើផ្នែកបច្ចេកទេសពីនាយកដ្ឋានពាក់ព័ន្ធ ព្រមជាមួយនឹងការផ្តល់នូវសេវាកម្មបន្ថែមទៀត។

សេវាកម្មដែលគួរពង្រីកសម្រាប់ការផ្តល់ សេវាកម្មបន្ថែមថ្នាក់មូលដ្ឋាននោះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងសកម្មភាពសេដ្ឋកិច្ចនៅតាមមូលដ្ឋានរបស់ឃុំ/សង្កាត់នីមួយៗ។ សកម្មភាពទាំងនោះ រួមមានការយកពន្ធផ្លូវលើទោចក្រយានយន្ត ពន្ធលើដីដែលមិនប្រើប្រាស់ និងពន្ធផ្សេងៗទៀតលើអាជីវកម្មធុនតូច។ ម្យ៉ាងទៀត សកម្មភាពទាំងនេះត្រូវបានក្រុមប្រឹក្សាឃុំ/សង្កាត់ជឿជាក់ថាពួកគាត់មានសមត្ថភាពអាចប្រមូលពន្ធតាមមូលដ្ឋានទាំងនោះ ប្រកបប្រសិទ្ធភាពជាងអាជ្ញាធរថ្នាក់លើ ដែលធ្លាប់បានប្រមូលពីមុនៗមក។

## ៤.១.២. បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ និងពង្រឹងក្រមសីលធម៌

នៅពេលដែលថវិកាឃុំ/សង្កាត់គ្រប់គ្រាន់ និងអាចបង្កើនប្រាក់បៀវត្សរ៍ឱ្យបុគ្គលិកឃុំ/សង្កាត់បាន ហើយការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋពីថ្លៃសេវាផ្លូវការ និងការពង្រឹងក្រមសីលធម៌របស់មន្ត្រីឃុំ/សង្កាត់នឹងត្រូវតែអនុវត្តន៍ជាចាំបាច់។

ការផ្សព្វផ្សាយជាសាធារណៈអំពីតម្លៃសេវាផ្លូវការ ដើម្បីឱ្យអ្នកប្រើប្រាស់សេវាកម្មបានដឹង នោះត្រូវបានគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋនៅក្នុងកិច្ចពិភាក្សាជាក្រុម និងក្នុងកិច្ចសម្ភាសន៍ជាមួយមន្ត្រីសំខាន់ៗនៅតាមមូលដ្ឋាន។ មេឃុំ/ចៅសង្កាត់មួយចំនួន ដែលសាលាឃុំ/សង្កាត់របស់គាត់បានបិទផ្សាយនូវថ្លៃសេវាកម្មរួចហើយនោះ បានទទួលស្គាល់ពីសារៈសំខាន់នៃការផ្តល់ព័ត៌មានពីថ្លៃសេវាកម្មដោយលើកយកហេតុផលពីរយ៉ាងមកបង្ហាញ។ ហេតុផលទី១ វាជួយធ្វើឱ្យដំណើរការការងារប្រព្រឹត្តិទៅដោយរលូន និងទាន់ពេលវេលា។ ហេតុផលទី ២ វាជួយកាត់បន្ថយការចំណាយក្រៅផ្លូវការ ដែលទាមទារដោយបុគ្គលិកឃុំ/សង្កាត់ បើទោះជាមន្ត្រីដែលត្រូវបានសម្ភាសន៍ទាំងអស់ទទួលស្គាល់ថា បុគ្គលិករបស់ខ្លួនបានទទួលប្រាក់បន្ថែមពីប្រជាពលរដ្ឋក្នុងលក្ខណៈជាការអាណិតអាសូរក្តី។

ដើម្បីលុបបំបាត់ ឬកាត់បន្ថយឱ្យបានជាដរាបនូវការបង់ប្រាក់ក្រៅផ្លូវការនេះ ក្រុមសីលធម៌ និងបទបញ្ញាត្តិរដ្ឋបាល ត្រូវបានស្នើឱ្យបង្កើតឡើងឱ្យបានគ្រប់គ្រាន់ និងដាក់ឱ្យអនុវត្តន៍ឱ្យបានតឹងរឹងបំផុត។

ដោយយោងតាមអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនៅតាមមូលដ្ឋានបានឱ្យដឹងថា ការបង្កើតអោយមានក្រមសីលធម៌វិជ្ជាជីវៈនេះឡើង គួរតែផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាថា តើត្រូវផ្លាស់ប្តូរទម្លាប់ និងផ្នត់គំនិតរបស់មន្ត្រីរាជការពីអាកប្បកិរិយាជាអាជ្ញាធរគ្រប់គ្រងឱ្យក្លាយទៅជាអ្នកផ្តល់នូវសេវាសាធារណៈ ដែលបំរើដល់ប្រយោជន៍របស់ប្រជាពលរដ្ឋនោះដោយរបៀបណា?

## ៤.២. សេវាកម្មសាលាបឋមសិក្សា

### *៤.២.១. ការតម្លើងប្រាក់ខែ និងការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ*

ការតម្លើងប្រាក់ខែ និងការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ គឺជាសំណើរមួយដ៏សំខាន់ពីក្រុមគ្រួសារ និងក្រុមគ្រូបង្រៀន ដែលបានចូលរួមក្នុងកិច្ចពិភាក្សា។ ក្តីព្រួយបារម្ភពីជីវភាពប្រចាំថ្ងៃ ដោយសារតែប្រាក់ខែមិនគ្រប់គ្រាន់ ជំរុញឱ្យគ្រូបង្រៀននៅតាមសាលាបឋមសិក្សាបង្ខំចិត្តយកប្រាក់ក្រៅផ្លូវ-ការ និង/ឬបង្ខំចិត្តស្វែងរកប្រភពចំណូលផ្សេងៗបន្ថែមទៀត។ ជាលទ្ធផល ពួកគាត់មិនសូវយកចិត្តទុកដាក់លើការងារបង្រៀន និងពង្រឹងគុណភាពសេវាអប់រំរបស់ខ្លួនឡើយ។ ការបង្កើនប្រាក់ខែឱ្យបានគ្រប់គ្រាន់ នឹងប្រហែលជាធ្វើអោយពួកគាត់មានភាពខ្មាស់អៀនក្នុងការទារប្រាក់ពីកូនសិស្សរបស់ខ្លួន ឬយ៉ាងហោចណាស់ក៏អាចកាត់បន្ថយបានច្រើននូវចំណាយក្រៅផ្លូវការនោះដែរ។ ការតម្លើងប្រាក់ខែនេះក៏អាចជាកត្តាជំរុញ និងលើកទឹកចិត្តមួយដល់គ្រូបង្រៀន ក្នុងការផ្តល់នូវសេវាអប់រំ ដល់សិស្សឱ្យបានកាន់តែប្រសើរជាងមុននៅក្នុងសហគមន៍ផងដែរ។

ទោះជាយ៉ាងណា ការតម្លើងប្រាក់ខែ និង ការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីសាធារណៈ គឺជាឆន្ទះដ៏ខ្លាំងក្លារបស់រាជរដ្ឋាភិបាល និងទទួលបានការគាំទ្រពីម្ចាស់ជំនួយជាច្រើន។ បច្ចុប្បន្នរដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយម្ចាស់ជំនួយបានខិតខំប្រឹងប្រែងរួមគ្នាដើម្បីបង្កើនប្រាក់ខែរបស់មន្ត្រីសាធារណៈ និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈតាមរយៈកំណែទម្រង់រដ្ឋបាល។ ជាលទ្ធផល គម្រោងលើកទឹកចិត្តត្រូវបានអនុវត្តន៍នៅក្នុងក្រសួងមួយចំនួនដូចជា ក្រុមគណកម្មការអាទិភាព (PMG) និងគំនិតផ្តួចផ្តើមនៃការផ្តល់ប្រាក់កម្រៃតាមគុណបំណាច់ (MBPI)។ ទោះយ៉ាងណា កម្មវិធីទាំងនេះ មិនទាន់បានអនុវត្តន៍សម្រាប់មន្ត្រីរាជការនៅតាមមូលដ្ឋាននៅឡើយទេ។

បើទោះជាប្រាក់ខែរបស់មន្ត្រីរាជការត្រូវបានបង្កើនក្តី ក៏មន្ត្រីនៅតែជួបប្រទះនឹងការលំបាកក្នុងការរ៉ាប់រងនូវរាល់ចំណាយសម្រាប់ជីវភាពរបស់ពួកគាត់ដែរ ដោយសារតែតម្លៃទំនិញកើនឡើងខ្លាំង។ម្យ៉ាងទៀត ប្រាក់ខែរបស់មន្ត្រីសាធារណៈបានកើនឡើងមែន ក៏ប៉ុន្តែអំណាចទិញរបស់ពួកគេនោះធ្លាក់ចុះទៅវិញទេ ដោយសារតែអត្រាអតិផរណាខ្ពស់របស់ប្រទេស។

ដូច្នេះ ដើម្បីលុបបំបាត់ការបង់ចំណាយក្រៅផ្លូវការចំពោះសេវាសាលាបឋមសិក្សារដ្ឋាភិបាលត្រូវតែបង្កើនប្រាក់ខែឱ្យបានសមរម្យដល់គ្រូបង្រៀន។

នាយកសាលាមួយរូបបាននិយាយថា *"ប្រសិនបើយើងចង់កាត់បន្ថយការយកប្រាក់ក្រៅផ្លូវការនៅសាលាបឋមសិក្សា ជាដំបូងយើងគួរតែបង្កើនកម្រិតជីវភាពរបស់គ្រូបង្រៀនជាមុនសិន។ នេះមានន័យថា យើងគួរតែបង្កើនប្រាក់ខែឱ្យដល់គ្រូបង្រៀន"*។ ដូចគ្នាដែរ ក្នុងកិច្ចពិភាក្សាជាក្រុមប្រជាពលរដ្ឋនៅក្នុងខេត្ត កំពង់ធំមានជំនឿថា *"គ្រូនឹងឈប់ទារប្រាក់ក្រៅផ្លូវការពីសិស្ស ១០០% ប្រសិនបើប្រាក់ខែរបស់គាត់គ្រប់គ្រាន់ ព្រោះថាពួកគាត់គ្មានអំណាចទេ ប៉ុន្តែគាត់មានក្រមសីលធម៌វិជ្ជាជីវៈក្នុងខ្លួនគ្រប់ៗគ្នា"*។ *"ពួកគាត់នឹងយកចិត្តទុកដាក់កាន់តែខ្លាំងឡើងក្នុងការបង្រៀនកូនសិស្ស ហើយកូនសិស្សនឹងគោរពគ្រូរបស់ខ្លួនវិញដែរ"*។

**ប្រអប់ ៤.១: តើប្រាក់ខែប៉ុន្មានគ្រប់គ្រាន់សម្រាប់គ្រូបង្រៀនបឋមសិក្សា?**

បច្ចុប្បន្ន ប្រាក់ខែរបស់គ្រូមានចំនួនពី ២៥ដុល្លារ ទៅ ៤០ដុល្លារ ក្នុងមួយខែ ដែលចំនួននេះមិនគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃដែលកាន់តែថ្លៃទៅៗនោះឡើយ។ កម្រៃក្រៅផ្លូវការដែលគ្រូទទួលបាន គឺសម្រាប់តែទ្រទ្រង់ការចំណាយប្រចាំថ្ងៃក្នុងគ្រួសាររបស់ពួកគាត់តែប៉ណ្ណោះ។ ទាំងនេះ ជាការយល់ឃើញរបស់ប្រជាពលរដ្ឋ និងត្រូវបានបញ្ជាក់បន្ថែមដោយគ្រូបង្រៀន នាយកសាលា ប្រធានមណ្ឌលសុខភាព និងមន្ត្រីអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។

ការបង្កើនប្រាក់ខែគ្រូបង្រៀន ត្រឹម ១៥ភាគរយ ក្នុងមួយឆ្នាំ នឹងមិនទាន់គ្រប់គ្រាន់សម្រាប់ឱ្យពួកគាត់អាចផ្គត់ផ្គង់ជីវភាពបាន ជាមួយនឹងអត្រាអតិផរណាខាងសេដ្ឋកិច្ចដ៏ខ្ពស់នោះឡើយ ហើយវានឹងត្រូវចំណាយពេលយូរពេកទម្រាំអាចឈានដល់កម្រិតសមរម្យមួយ។ ជាមួយនឹង សំនួរថាតើប្រាក់ខែប៉ុន្មាននឹងគ្រប់គ្រាន់សម្រាប់ឱ្យគ្រូបង្រៀនអាចទ្រទ្រង់ជីវភាពប្រចាំថ្ងៃបាននោះ ចម្លើយដែលទទួលបានគឺប្រហាក់ប្រហែលគ្នាពីតំបន់មួយទៅតំបន់មួយ។ ប្រាក់ខែដែលស្នើសុំដោយគ្រូបឋមសិក្សាភាគច្រើនមានចំនួនប្រមាណ ១០០ដុល្លារ ទាំងនៅតំបន់ជនបទ និងទីប្រជុំជន។ ជាមួយនឹងកំរិតប្រាក់បៀវត្សដែលស្នើរឡើងនេះ មន្ត្រីតាមមូលដ្ឋានយល់ឃើញថាពួកគាត់អាចបំពេញចំណាយចាំបាច់មួយចំនួនដូចជា ថ្លៃអង្ករ ម្ហូបអាហារ សំលៀកបំពាក់ ប្រេងសាំង ជាដើម

យ៉ាងណាក្តី បើទោះជាការតម្លើងប្រាក់បៀវត្សន៍គឺជាលក្ខខណ្ឌដ៏ចាំបាច់បំផុតនោះក៏ដោយ វិធានការនេះតែមួយមុខនឹងមិនគ្រប់គ្រាន់ សម្រាប់លុបបំបាត់ចោលនូវកម្រៃក្រៅផ្លូវការបានទាំងស្រុង បានទេ។ ការបង្កើនប្រាក់ខែនឹងជួយកាត់បន្ថយការយកកម្រៃក្រៅផ្លូវការ ប៉ុន្តែដើម្បីអាចលុបបំបាត់បានទាំងស្រុង ចាំបាច់ត្រូវដាក់ចេញ និងអនុវត្តឱ្យបានតឹងរ៉ឹងនូវ ក្រមសីលធម៌វិជ្ជាជីវៈ វិធានការវិន័យផ្សេងទៀត។ មន្ត្រី

សាធារណៈដែលបានប្រព្រឹត្តិខុស ត្រូវតែទទួលរងនូវការដាក់ពិន័យ ហើយមន្ត្រីដែលមានស្នាដៃការងារល្អ ត្រូវទទួលបាននូវការលើកទឹកចិត្តដោយគ្មានការលើកលែង។ ដើម្បីសម្រេចបាននូវគោលដៅនេះ គឺទាមទារឱ្យមាននូវក្របខណ្ឌច្បាប់មួយច្បាស់លាស់។ រហូតមកដល់ពេលនេះ ច្បាប់ប្រឆាំងអំពើពុករលួយនៅមិនទាន់បានអនុម័តនៅឡើយ ដែលការណ៍នេះអាចនាំឱ្យមានការលំបាកក្នុងការលុបបំបាត់ការបង់កម្រៃក្រៅផ្លូវការផងដែរ។ ក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលគប្បីបង្កើនការខិតខំបន្ថែមទៀត ដើម្បីអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបានឆាប់រហ័ស ព្រោះវត្តមាននៃច្បាប់នេះ ជាតម្រូវការចាំបាច់បំផុតនាពេលបច្ចុប្បន្ន សំរាប់ធានាឱ្យការងារការអភិបាលកិច្ច តម្លាភាព និង គណនេយ្យភាពកាន់តែប្រសើរឡើង។ ជាសត្យានុម័ត ប្រាក់ខែអាចនឹងត្រូវតម្លើងបាន នៅពេលដែល កម្រៃក្រៅផ្លូវការត្រូវបានលុបបំបាត់ ហើយថវិកាជាតិមានការកើនឡើង។

## ៤.២.២. ទំនាក់ទំនងរវាងទស្សនៈវិស័យខាងគុណភាព និងបរិមាណក្នុងវិស័យអប់រំមូលដ្ឋាន

ដើម្បីពង្រឹងគុណភាពការអប់រំ ទាំងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ និងប្រជាពលរដ្ឋបានផ្តល់សារៈសំខាន់ទៅលើតួនាទីរបស់គ្រូបង្រៀន។ ពួកគាត់ជឿជាក់ថា គ្រូគឺជាអ្នកដែលស្ថិតនៅជិតជាងគេ ដែលស្គាល់បានច្បាស់ និងអាចធ្វើការវិនិច្ឆ័យដោយផ្ទាល់ទៅលើលក្ខណៈសម្បត្តិរបស់សិស្ស។ ដូច្នេះ គ្រូគួរតែមានក្រមសីលធម៌វិជ្ជាជីវៈផ្ទាល់ខ្លួន ហើយមិនគួរចេះតែអនុញ្ញាតិឱ្យសិស្សដែលគ្មានសមត្ថភាពបានឡើងថ្នាក់នោះឡើយ។ គ្រូគប្បីយល់ឱ្យបានច្បាស់ពីបញ្ហាអវិជ្ជមានផ្សេងៗដែលសង្គម ទាំងមូលត្រូវជួបប្រទះតាមរយៈការតំឡើងថ្នាក់ដល់របស់សិស្សដោយខ្វះគុណភាពបែបនេះ។ ដូចដែលបានលើក ឡើងដោយប្រជាពលរដ្ឋម្នាក់ ស្ថានភាពនឹងអាចកាន់តែធ្ងន់ធ្ងរទៅទៀតដោយហេតុថា *"ប្រសិនបើគ្រូនៅតែយកប្រាក់ ហើយចេះតែអនុញ្ញាតិឱ្យសិស្សឡើងថ្នាក់ គំរូនេះជៀសមិនផុតនឹងជម្រុញឱ្យសិស្សទាំងនោះក្លាយទៅជាជនអ្នកពុករលួយមិនខាននៅថ្ងៃខាងមុខ"*។

ទន្ទឹមនឹងនេះ តាមរយៈកិច្ចពិភាក្សាជាក្រុមជាមួយប្រជាពលរដ្ឋ និងគ្រូបង្រៀនឃើញថា សម្ភារៈសិក្សាកំពុងជួបការខ្វះខាតនៅឡើយ។ គ្រូមួយចំនួនត្រូវស្វែងរកសម្ភារៈបង្រៀនដោយខ្លួនឯង ហើយជួនកាលពួកគាត់បង្រៀនសិស្សដោយពុំមានទាំងសម្ភារៈសម្រាប់ឱ្យសិស្សមើលទៀតផង។ ជាការពិត ភាពខ្វះខាតទាំងនេះផ្តល់ផលប៉ះពាល់ខ្លាំងទៅលើកម្រិតយល់ដឹងរបស់សិស្ស និងគុណភាពនៃការបង្រៀន។ ក្នុងស្ថានភាពនេះរាជរដ្ឋាភិបាល ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា គួរចាត់ វិធានការដើម្បីធានាឱ្យមានយន្តការផ្គត់ផ្គង់សម្ភារៈសិក្សាមួយដែលគ្រប់គ្រាន់ ។ បន្ថែមលើនេះ ចំនួននៃអគារសិក្សាក៏កំពុងជាតម្រូវការមួយដែលទាមទារឱ្យមានការពង្រីកបន្ថែមផងដែរ។

## ៤.៣. សេវាមណ្ឌលសុខភាព

### *៤.៣.១ ការតម្លើងប្រាក់បៀវត្សរ៍ និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ*

បើទោះជារាជរដ្ឋាភិបាលអនុញ្ញាតិឱ្យមណ្ឌលសុខភាពរកចំណូលបន្ថែមដោយខ្លួនឯងក្តី ក៏ថ្លៃសេវាដែលអាចរកបានជាផ្លូវការទាំងនោះ នៅតែមានចំនួនតិចតួច និងមិនអាចផ្គត់ផ្គង់តម្រូវការចាំបាច់របស់បុគ្គលិកឱ្យបានគ្រប់គ្រាន់នៅឡើយ។ តាមការប៉ាន់ស្មានឃើញថា បុគ្គលិកមណ្ឌលសុខភាពម្នាក់ៗទទួលបានត្រឹមប្រមាណ ១០ដុល្លារ ប៉ុណ្ណោះក្នុងមួយខែ ពីចំណូលផ្លូវការទាំងនោះ។

ក្នុងស្ថានភាពនេះ ទាំងអ្នកប្រើប្រាស់ អ្នកផ្តល់សេវា ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធសុទ្ធតែយល់ឃើញថាការតម្លើងប្រាក់បៀវត្សរ៍ រួមផ្សំជាមួយនឹងការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ គឺជាមធ្យោបាយអាទិភាពមួយ សំរាប់បង្កើននូវប្រសិទ្ធភាពសេវាសុខភាពមូលដ្ឋានឱ្យប្រសើរឡើង។ ប្រធានមណ្ឌលសុខភាពមួយរូបបានលើកឡើងថា "*ប្រសិនបើប្រាក់ខែគ្រប់គ្រាន់ ហើយច្បាប់ត្រូវបានអនុវត្តន៍ នោះមណ្ឌលសុខភាពនឹងឈប់រកកម្រៃក្រៅផ្លូវការ ឬក៏គេចវេះពីការបំពេញភារកិច្ចរបស់ខ្លួន ព្រោះពួកគាត់ខ្លាចបាត់បង់ការងារ*"។ មន្ត្រីអង្គការ UNICEF ម្នាក់បាននិយាយថា "*ការផ្តន្ទាទោសចំពោះមន្ត្រី ដែលពុករលួយគួររាប់ចាប់ពីការដកតំណែងដែលមានស្រាប់រហូតដល់បណ្តេញចេញពីតំណែងជាមន្ត្រីរាជការសាធារណៈ*"។

### *៤.៣.២ ការពង្រីងបរិក្ខាពេទ្យ និងកសាងសមត្ថភាព*

សម្ភារៈបរិក្ខាដើរតួនាទីយ៉ាងសំខាន់នៅក្នុងគ្រប់មណ្ឌលសុខភាពថ្នាក់មូលដ្ឋាន ជាពិសេសនៅតាមតំបន់ជនបទ។ ការបង្កើនសម្ភារៈចាំបាច់ដល់មណ្ឌលសុខភាព នឹងធានាបាននូវគុណភាពនៃសេវាកម្ម នៅទីនោះ។ រដ្ឋាភិបាល និងភាគីពាក់ព័ន្ធ គប្បីបន្តបង្កើនឡើងនូវការផ្គត់ផ្គង់ឧបករណ៍ទាំងនោះឱ្យបានគ្រប់គ្រាន់។

ឧបករណ៍ចាស់ៗគួរតែផ្លាស់ប្តូរចេញ ដោយជំនួសមកវិញនូវឧបករណ៍ទំនើប ហើយចាំបាច់ត្រូវមានថ្នាំពេទ្យគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងប្រភេទជម្ងឺផ្សេងៗ។ អាគារសម្រាកព្យាបាលគប្បីត្រូវសង់បន្ថែមទៀត ដើម្បីអាចទទួលអ្នកជម្ងឺដែលមិនមានលទ្ធភាពទៅព្យាបាលនៅមន្ទីរពេទ្យស្រុក ឬពេទ្យខេត្ត។ ជាមួយគ្នានឹងការកែលំអនេះ សេវាកម្មចាំបាច់បន្ថែមទៀតគួរតែបង្កើតឱ្យមាននៅតាមមណ្ឌលសុខភាព។ ប្រជាពលរដ្ឋតាមមូលដ្ឋានបានឱ្យដឹងថា ពួកគាត់ត្រូវការជាចាំបាច់នូវសេវាកម្មមួយចំនួនផ្សេងទៀតដូចជាការព្យាបាលធ្មេញ ការសម្រាកព្យាបាល ការព្យាបាលរោគភ្នែក និងការបង្កើតកូនដោយវះកាត់ ដោយស្នើសុំឱ្យសេវាទាំងនេះមានផ្តល់ឱ្យនៅតាមមណ្ឌលសុខភាពផ្ទាល់ ជាមួយនឹងតម្លៃដែលសមរម្យ។

បន្ថែមពីលើនេះ ការកសាងសមត្ថភាពបុគ្គលិកពេទ្យក៏ត្រូវបានមើលឃើញថាជាកត្តាចាំបាច់ផងដែរ។ បុគ្គលិកមណ្ឌលសុខភាពគួរត្រូវបានបណ្តុះបណ្តាលខាងវិជ្ជាជីវៈឱ្យបានពេញលេញ និងជាប្រចាំដើម្បី

ទទួលបាននូវចំណេះដឹង  និងជំនាញសមស្របទៅនឹងតម្រូវការថ្មីៗរបស់សហគមន៍ដែលចេះតែកើនឡើងជាលំដាប់ ។ ដំណើរការនៃការបណ្តុះបណ្តាលគួរផ្តោតជាសំខាន់ទៅលើតំបន់ជនបទ ដែលនៅទីនោះការទទួលបាននូវព័ត៌មានក៏ដូចជាបច្ចេកវិជ្ជាថ្មីៗនៅមានកម្រិតទាបនៅឡើយ ។

# អនុសាសន៍គោលនយោបាយ និងសេចក្តីសន្និដ្ឋាន

សេវាសាធារណៈមូលដ្ឋានទាំងបីដែលជាកម្មវត្ថុនៃការសិក្សាប្រឈមមុខធ្ងន់ធ្ងរទៅនឹងបញ្ហាប្រាក់បៀវត្សរ៍ដែលបង្ខំឱ្យមន្ត្រីដែលបំរើការនៅទីនោះ ត្រូវស្វែងរកប្រភពចំណូលបន្ថែមតាមរយៈការយកកម្រៃក្រៅផ្លូវការ និង.ឬឆ្លៀតពេលធ្វើការក្រៅនៅក្នុងម៉ោងបំពេញការងារ។ ផលប៉ះពាល់អវិជ្ជមាននៃស្ថានការនេះ ជះឥទ្ធិពលអាក្រក់ទៅលើគុណភាពនៃការផ្តល់សេវា ទៅលើការទទួលបាន សេវាដោយប្រជាជនក្រីក្រ និងទៅលើកិច្ចសន្យាសង្គមរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ។

ការបង្កើនដែនអន្តរាគមន៍ និងតួនាទីរបស់ឃុំ/សង្កាត់ទៅក្នុងសេវាថ្នាក់មូលដ្ឋានទាំងបីនឹងអាចជួយបង្កើនគុណភាពនៃសេវាទាំងនោះឱ្យកាន់តែប្រសើឡើង។ នៅក្នុងប្រទេសអភិវឌ្ឍន៍ ដែលមានប្រព័ន្ធអប់រំរឹងមាំ ការអប់រំថ្នាក់បឋមសិក្សាច្រើនជាបន្ទុកផ្ទាល់របស់រដ្ឋបាលថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងណាវិស័យអប់រំថ្នាក់បឋមសិក្សា និងសុខភាពថ្នាក់មូលដ្ឋានទាមទារឱ្យមានជំនាញបច្ចេកទេសច្បាស់លាស់ដែលសព្វថ្ងៃមិនទាន់មាននៅឡើយតាមឃុំ/សង្កាត់។ យ៉ាងណាក្តី ចំនុចនេះ មិនមែនរនាំងចំពោះអាជ្ញាធរឃុំ-សង្កាត់ក្នុងការអនុវត្តតួនាទីពាក់ពន្ធ័ដទៃទៀត ដូចជាតួនាទី ក្នុងការលើកកម្ពស់ការយល់ដឹង ការប្រមូលផ្តុំប្រជាជន ការត្រួតពិនិត្យនិងតាមដានដែលមិនទាក់ទិននឹង កាងារបច្ចេកទេស និងការវាយតម្លៃតាមរយៈ (ការចូលរួមក្នុង) គណៈកម្មការគ្រប់គ្រងនោះឡើយ។ ដោយឡែក ក្នុងករណីដែលតួនាទីបែបវិមជ្ឈការទាំងនេះកំពុងត្រូវបានសាកល្បង ឬក៏រកឃើញតាមវិធីផ្សេងណាមួយនោះការងារទាំងនេះជាធម្មតាទាមទារឱ្យធ្វើឡើងដោយមានការសម្របសម្រួល ពីសំណាក់អង្គភាពជំនាញថ្នាក់ស្រុក និងថ្នាក់ខេត្តដទៃទៀត និងជាញឹកញាប់ក្រោមកិច្ចសហប្រតិបត្តការជាមួយនឹងអ្នកពាក់ព័ន្ធក្រៅរដ្ឋាភិបាលផ្សេងទៀត ដូចជា មូលនិធិសមធមិរបស់អង្គការក្រៅរដ្ឋាភិបាលសំរាប់វិស័យសុខភាព និងអង្គការអន្តរជាតិក្នុងវិស័យអប់រំជាដើម។

ដូចនេះឃើញថា ក្នុងចំណោមសេវាកម្មថ្នាក់មូលដ្ឋានទាំងបី សេវារដ្ឋបាលឃុំ/សង្កាត់ ផ្តល់នូវគុណសម្បត្តិច្រើនជាងគេ សំរាប់ឱ្យមានការដាក់ចេញនូវការពិសោធន៍គោលនយោបាយទាក់ទិនទៅនឹងការដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាតម្លៃផ្លូវការនៅថ្នាក់មូលដ្ឋាន។ សេវាទាំងនេះជាប្រភេទសេវា ដែលក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវមានការទទួលខុសត្រូវផ្ទាល់ច្រើន។

តាមរយៈលទ្ធផលនៃការសិក្សា ការបង្កើនប្រសិទ្ធភាពសេវាសាធារណៈថ្នាក់មូលដ្ឋាន ដោយគ្មានការបង់កម្រៃក្រៅផ្លូវការគឺជារឿងដែលអាចធ្វើទៅបាន ប្រសិនបើឃុំ/សង្កាត់ទាំងអស់មានថវិកាគ្រប់គ្រាន់ផ្គត់ផ្គង់លជីវភាពប្រចាំថ្ងៃរបស់មន្ត្រី និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ នៅក្នុងក៏រិតម៉ាក្រូ ការបង់កម្រៃក្រៅផ្លូវការមានទំហំតិចតួចណាស់ ពោលគឺមិនដល់ ១ ភាគរយ នៃថវិកាជាតិ ប៉ុន្តែផ្តល់ផលប៉ះពាល់គួរឱ្យកត់សំគាល់ទៅលើប្រជាជនក្រីក្រទាក់ទិនទៅនឹងប្រសិទ្ធភាពនៃសេវាកម្ម។ បន្ថែមពីលើនេះ ប្រជាពលរដ្ឋ

ភាគច្រើនមានឆន្ទះក្នុងការចូលរួមវិភាគទាន ក្នុងការអភិវឌ្ឍមូលដ្ឋាន និងយល់ព្រមបង់ថ្លៃសេវាផ្សេងៗ ដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន។

យ៉ាងណាក្តី ការដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាផ្លូវការក៏នៅមិនទាន់អាចឱ្យឃុំ/សង្កាត់ រកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីធានាបាននូវកំរិតបៀវត្សន៍សមរម្យ ដែលជាលក្ខខណ្ឌចាំបាច់ចំពោះប្រសិទ្ធភាពនៃការផ្តល់សេវានៅឡើយទេ ជាពិសេសករណីឃុំនៅតាមជនបទ។ ការពង្រឹងស្វ័យតភាព ផ្នែកហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ/សង្កាត់ តាមរយៈការពង្រីកអំណាច និងសមត្ថភាពរបស់អាជ្ញាធរនេះ ក្នុងការប្រមូលពន្ធមូលដ្ឋានគឺជាការចាំបាច់។ ច្បាប់រៀបចំអង្គការទាក់ទងទៅនឹងការរៀបចំរដ្ឋបាលដែនដី គប្បីផ្ទេរភារកិច្ចក្នុងការប្រមូលចំណូលពន្ធ និងចំណូលមិនមែនពន្ធទៅឱ្យថ្នាក់ឃុំ/សង្កាត់ ហើយបង្កើតឡើងនូវយន្តការចែករំលែក ថវិកាមួយ ដែលនឹងជម្រុញឱ្យស្វ័យតភាពហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ/សង្កាត់បានប្រសើរឡើង។ តួនាទីដែលត្រូវផ្ទេរទាំងនេះអាចរាប់បញ្ចូលនូវការផ្តល់អាជ្ញាប័ណ្ណលើអាជីវកម្ម ខ្នាតតូចការប្រមូលពន្ធលើមធ្យោបាយធ្វើដំណើរ និងលើដីដែលមិនប្រើប្រាស់ និងប្រតិបត្តិការទាក់ទិននឹងកម្មសិទ្ធដទៃទៀត[២៩]។ ជាការពិត ការផ្ទេរអំណាចទាំងនេះអាចធ្វើទៅបាន លុះណាតែកំណែទម្រង់រដ្ឋបាលទូទៅ និងកំណែទម្រង់រដ្ឋបាល ដែនដីមានភាពស៊ីសង្វាក់គ្នា។

ក្នុងខណៈដែលអាជ្ញាធរឃុំ/សង្កាត់បច្ចុប្បន្ននៅមានភាពទន់ខ្សោយខាងផ្នែកថវិកា និងធនធានមនុស្សនៅឡើយ ការផ្ទេរអំណាចគប្បីធ្វើឡើងដោយសន្សឹមៗនិងតាមដំណាក់កាលជាក់លាក់។ លទ្ធផលនៃការសិក្សាបានលើកឡើងនូវអំណះអំណាងដែលបញ្ជាក់ឱ្យឃើញថា ការដាក់កម្រៃក្រៅផ្លូវការឱ្យទៅជាផ្លូវការបូករួមនឹងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដទៃទៀត ជាគោលការណ៍បង្កើតបាននូវស្វ័យតភាពហិរញ្ញថ្នាក់មូលដ្ឋានក្នុងកំរិតមួយដែលអាចនាំទៅដល់បៀវត្សន៍សមរម្យរបស់មន្ត្រី និងសេវាកម្មមួយប្រកបដោយគុណភាព។ លទ្ធភាពនេះអាចនឹងពិបាកទៅរួចបន្តិចចំពោះឃុំក្រីក្រតាមជនបទ ប៉ុន្តែពិតជា អាចទៅរួចសម្រាប់ឃុំតាមទីប្រជុំជន។

គោលនយោបាយដែលកើតចេញពីការគិតគូរដ៏ល្អិតល្អន់មួយ គួរត្រូវបានដាក់ចេញដើម្បីធ្វើការសាកល្បងដាក់សេវារដ្ឋបាលទាំងឡាយឱ្យទៅជាផ្លូវការ និងផ្ទេរភារកិច្ចប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួនទៅឱ្យថ្នាក់ឃុំ/សង្កាត់។ មកទល់បច្ចុប្បន្ន ឃើញថាកំណែទម្រង់ខាងផ្នែកវិមជ្ឈការគឺជាឧទាហរណ៍ដ៏លេចធ្លោមួយនៅកម្ពុជា ដែលបានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃកម្មវិធីសាកល្បងៈជោគជ័យគួរឱ្យកត់សំគាល់នេះ កើតចេញពីការរៀបចំមួយដែលបានផ្អែកទៅលើបទពិសោធន៍ជាក់ស្តែងនៃកម្មវិធីគម្រោងសាកល្បងរបស់ CARERE/SEILA។ គម្រោងសាកល្បងដ៏ល្អិតល្អន់មួយគួបផ្សំជាមួយនឹង

---

[២៩] ចំណូលពីសេវាកម្មទាំងនេះអាចប្រមូលដោយឃុំ/សង្កាត់ប្រកបដោយប្រសិទ្ធភាពខ្ពស់ជាង ដោយហេតុថាឃុំ/សង្កាត់អាចក្តាប់ពីស្ថានការណ៍ក្នុងសហគមរបស់ពួកគេបានជិតដល់ជាងអាជ្ញធរថ្នាក់លើ។

ការត្រួតពិនិត្យដ៏ហ្មត់ចត់[៣០] បង្កើតបានជាមូលដ្ឋានយោងចាំបាច់មួយ សម្រាប់ជាជំនួយដល់ការដាក់ចេញនូវគោលនយោបាយដទៃទៀតប្រកបដោយប្រសិទ្ធភាព។

ទោះជាយ៉ាងណា ត្រូវមានការសិក្សាឱ្យបានទូលំទូលាយបន្ថែមទៀតទៅលើការអនុវត្តនូវគម្រោងសាកល្បងដែលនឹងអាចផ្តល់នូវចំណេះដឹងជាក់ស្តែងសម្រាប់ឱ្យមានការពង្រីកដែនអនុវត្តន៍ទៅដល់ឃុំ/សង្កាត់ដទៃទៀតជាបន្តបន្ទាប់។ ដើម្បីឱ្យគម្រោងសាកល្បងមួយនេះអាចរៀបចំបានល្អចាំបាច់ទាមទារឱ្យមានការផ្តល់នូវចំណេះដឹងគ្រប់គ្រាន់មួយអំពីទំហំ និងលក្ខខណ្ឌនៃការងារដែលត្រូវអនុវត្តសម្រាប់ជាគន្លឹះដល់អ្នកចេញគោលនយោបាយក្នុងការចាត់វិធានការជាក់ស្តែងបន្ត។ ដូចនេះ គោលដៅនៃការសិក្សា តាមដានមួយគប្បីផ្តោតទៅលើការគិតគូររៀបចំនូវគម្រោងសាកល្បងមួយដោយធ្វើការកំណត់ឱ្យបានច្បាស់លាស់ពីចំនួនគោលនយោបាយថ្មីៗដែលចាំបាច់សម្រាប់ធ្វើការសាកល្បង។ ការស្វែងយល់ពីចំណុចរួម និងចំណុចដោយឡែកដែលកើតមាននៅក្នុងប្រពន្ធ័រដ្ឋបាលដែនដី តាមរយៈការសិក្សាទៅលើលក្ខខណ្ឌដោយឡែកៗនៃបណ្តាឃុំ/សង្កាត់ដែលស្ថិតក្នុងស្ថានភាពផ្សេងគ្នា នឹងនាំទៅរកការកំណត់បានពីលទ្ធភាព សំណូមពរលក្ខខណ្ឌចាំបាច់ផ្សេងៗ និងការរៀបចំឡើងនូវគំរូស្ថាប័នជាក់លាក់មួយ សម្រាប់ដាក់ឱ្យគម្រោងសាកល្បងអាចដំណើរការទៅបាន ស្របទៅនឹងស្ថានភាពជាក់ស្តែងរបស់ឃុំ/សង្កាត់នីមួយ។

[៣០] *"ការត្រួតពិនិត្យពីដំណើរការជាប្រចាំ នឹងជួយជម្រុញដល់ដំណើរការអនុវត្តគម្រោង តាមរយៈការបំភ្លឺ និងផ្តល់អនុសាសន៍ ដល់ភ្នាក់ងារអនុវត្តអំពីការផ្លាស់ប្តូរដែលចាំបាច់ត្រូវធ្វើការកែប្រែ សំដៅសម្រេចបាននូវគោលដៅរបស់"ការពិសោធន៍គោលនយោបាយ"ទាំងនេះ* Rusten C។ (២០០៥) ទំព័រ ២៤។

# ឯកសារយោង

**Biddulph, R (2003).** *PAT Empowerment Study – Final Report.* Phnom Penh: Permanent Advisory Team on the Seila Program, Partnership for Local Governance, 2003.

http://www.seila.gov.kh

**CSD (2005A).** *Corruption and Cambodian Households. Household Survey on Perceptions, Attitudes, and Impact of Everyday Forms of Corrupt Practices in Cambodia.* http://www.csdcambodia.org/

**CSD (2005).** *Public Attitude towards Corruption* http://www.csdcambodia.org/

**CSD (2005).** *Living under the Rule of Corruption* http://www.csdcambodia.org/

**EIC (2006).** Assessment *of Corruption in Cambodia's Private Sector.* http://www.eicambodia.org/downloads/index.php?pageid=3

**Fjeldstad, O. (2003).** Decentralisation and Corruption. A review of the literature. U4 reports

**Hean, S, & Henke, R (2004).** *The state of democracy in Cambodia, the added value of opinion polls***.** Paper presented at Asiabarometer conference on the state of democracy in Asia, King Prajadhipok's Institute, Bangkok.

**Horng, V., & Ann, S. (2005).** *Local service Delivery and Commune Councils.* CDR 9 (3),

p.1-4, http://www.cdri.org.kh/

**Lambsdorff, J. (2001).** *How Corruption in Government Affects Public Welfare – A Review of Theories.* Discussion Paper 9. Goettingen:CeGE

**Ninh, K. & Henke, R. (2005).** *Commune councils in Cambodia:A national survey on their functions and Performance, with a Special Focus on Conflict Resolution.* Phnom Penh: TAF/CAS, http://www.asiafoundation.org/Locations/cambodia_publications.html

**Royal Government of Cambodia/World Bank (2003).** *Cambodia Public Expenditure Review Report: Decentralization and Deconcentration*

**Rusten, C, Kim S, Eng N. & Pak K (2004).** *The Challenges of the Decentralisation Design in Cambodia.* Phnom Penh: CDRI Monograph 1, http://www.cdri.org.kh/

**World Bank (2005).** *Public Expenditure Tracking Survey on Primary Education*

**World Bank (2005).** *Cambodia – Quality Basic Education For All*

**World Bank (2000).** *Cambodia Governance and Corruption Diagnostic. Evidence from Citizen, Enterprise and Public Official Surveys,* www.worldbank.org/wbi/governance

**World Bank (2005).** East Asia Decentralizes. Making local government work. Washinton DC.

**World Bank & ADB (2003).** Cambodia – Enhancing service delivery through improved resource allocation and institutional reform

**Ruste, C. (2005).** Institutional and Administrative arrangements for the Social Land Concessions. MLMUPC/GTZ/WB: LASED

***Websites:***

**Council for Administrative Reform:**

http://www.car.gov.kh/document/report

**Transparency International:**

http://www.transparency.org/cpi

**Council of Jurists**

http://www.bigpond.com.kh/Council_of_Jurists/somg.htm

***Other Sources:***

Government Rectangular Strategy

Strategic framework for decentralization and De-concentration reforms 2005

Codification of legal texts on Commune/Sangkat Administration, Official Gazette Department

Commune/sangkat fund project implementation manual, 2005

Education for All National Programme 2003-2015

Education Strategic Plan 2006-2010

Health Sector Strategic Plan 2003-2007

National Account of Cambodia 1993-2005

Cambodia Socio-Economic Survey 2004

# សេចក្តីបន្ថែម ១

# វិធីសាស្ត្រស្រាវជ្រាវ

# វិធីសាស្ត្រស្រាវជ្រាវ

## ១.១. ការសិក្សាអត្ថបទ

អត្ថបទ និងឯកសារស្រាវជ្រាវ ព្រមទាំងបទបញ្ញត្តិផ្សេងៗពាក់ព័ន្ធទៅនឹងប្រធានបទនេះត្រូវបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ដើម្បីផ្តល់ជាគំនិត ទស្សនៈ និងទិដ្ឋភាពទូទៅជុំវិញបញ្ហាដែលទាក់ទងទៅនឹងតម្លៃផ្លូវការ និងក្រៅផ្លូវការនៃសេវាសាធារណៈថ្នាក់មូលដ្ឋាន។ ឯកសារសំខាន់ៗដែលបានសិក្សាស្រាវជ្រាវរួមមានៈ ការវាយតម្លៃទៅលើអំពើពុករលួយដោយអង្គភាពជាច្រើន ដូចជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងធនាគារពិភពលោក ព្រមទាំងការសិក្សាទាក់ទងទៅនឹងប្រព័ន្ធវិមជ្ឈការដែលធ្វើឡើងដោយ អង្គការមូលនិធិអាស៊ី មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវជាន់ខ្ពស់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី។ល។ មេរៀនទទួលបានពីការស្រាវជ្រាវមុនៗបានជួយសម្រួលដល់ការតាក់តែងវិធីសាស្ត្រនៃការសិក្សានេះឱ្យមានលក្ខណៈវិទ្យាសាស្ត្រ និងស៊ីជម្រៅក្នុងការវាយតម្លៃទិន្នន័យ ចាំបាច់ទាក់ទងនឹងចំណាយក្រៅផ្លូវការលើសេវាសាធារណៈនៅថ្នាក់ឃុំ/សង្កាត់។

## ១.២. ការតាក់តែងប៉ាន់គំរូ

ខេត្ត/ក្រុងចំនួន ១២ ត្រូវបានជ្រើសរើសសម្រាប់ការចុះស្ទង់មតិនេះ។ ខេត្ត/ក្រុងដែលបានជ្រើសរើសតំណាងឱ្យប្រហែល ៨០ ភាគរយ នៃប្រជាជន និងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា។ ក្នុងការសិក្សានេះ ឃុំ/សង្កាត់ត្រូវបានបែងចែកជា ៣ ប្រភេទខុសៗពីគ្នាៈ ឃុំដែលមានទីតាំងក្នុងទីរួមខេត្ត ឃុំដែលមានទីតាំងក្នុងទីរួមស្រុក និងឃុំដែលនៅដាច់ស្រយាល។ លើសពីនេះទៅទៀត ដោយសារតែពេលវេលា និងថវិកាមានកំណត់ ព្រមទាំងដើម្បីភាពងាយស្រួល ចំនួនឃុំ/សង្កាត់ ដែលជាប៉ាន់គំរូត្រូវបានជ្រើសរើសចេញពីស្រុកតែពីរប៉ុណ្ណោះ ក្នុងខេត្តមួយ។ នៅក្នុងខេត្តនីមួយៗ ឃុំដែលមានទីតាំងនៅទីរួមខេត្តត្រូវបានរើសចេញពីស្រុកនៅទីរួមខេត្ត ហើយឃុំ ៣ ផ្សេងទៀតដែលរួមទាំងឃុំនៅទីរួមស្រុក និងឃុំនៅដាច់ស្រយាល ២ ផ្សេងទៀតត្រូវបានរើសពីស្រុកមួយផ្សេងទៀត។ មូលហេតុនៃការជ្រើសរើសវិធីសាស្ត្រនេះ គឺដោយសារតែប្រជាជនកម្ពុជាប្រហែល ៨០ ភាគរយ រស់នៅទីជនបទ។ ដូចនេះ ដើម្បីធ្វើឱ្យការបែងចែកប៉ាន់គំរូឱ្យមានតុល្យភាព ៤៤ ភាគរយ នៃប៉ាន់គំរូទាំងអស់ត្រូវផ្តល់ឱ្យឃុំនៅតាមជនបទ។

## រូបភាព ១.១: វិធីសាស្ត្រជ្រើសរើសឃុំ




ជាទូទៅ ឃុំ ៤ ត្រូវបានជ្រើសរើសចេញពីខេត្ត ១។ ក្នុងករណីពិសេស ឃុំមួយថែមទៀតក្នុងស្រុកនៃខេត្តសៀមរាប និងបាត់ដំបងត្រូវបានប្រើជាករណីសិក្សា ដោយសារតែគម្រោងសាកល្បងមួយដែលតម្រង់គោលដៅលើការលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវាសាធារណៈ ដែលកំពុងអនុវត្តដោយរដ្ឋាភិបាល និងដោយមានការគាំទ្រពី Konrad Adenaur Stiftung ។ ជាក់ស្តែង របាយការណ៍នេះ ពុំបានបង្ហាញភាពខុសគ្នារវាងឃុំដែលកំពុងអភិវឌ្ឍគម្រោងសាកល្បង និងឃុំដទៃទៀតឡើយ។ សរុបមកមាន ៥០ ឃុំ/សង្កាត់ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។

នៅក្នុងឃុំ/សង្កាត់នីមួយៗ មនុស្សពីរប្រភេទត្រូវបានជ្រើសរើសជាអ្នកចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម (FGDs) រួមមាន: អ្នកឆ្លើយទៅនឹងកម្រងសំណួរ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនតាមរយៈការសម្ភាស ឬក៏យើងអាចនិយាយម្យ៉ាងទៀតថា អ្នកប្រើប្រាស់សេវា និងអ្នកផ្តល់សេវា។

## តារាង ១.១: ចំនួនគំរូតាមប្រភេទឃុំ

| ប្រភេទឃុំ/សង្កាត់ | ចំនួនគំរូ | ភាគរយ |
|---|---|---|
| ឃុំដែលមានទីតាំងនៅទីប្រជុំជនខេត្ត | ១៧ | ៣៤% |
| ឃុំដែលមានទីតាំងនៅទីប្រជុំជនស្រុក | ១១ | ២២% |
| ឃុំដាច់ស្រយាល | ២២ | ៤៤% |
| **សរុប** | ៥០ | ១០០% |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ២០០៦*

ក្នុងករណីនេះ អ្នកផ្តល់សេវាសាធារណៈ គឺក្រុមប្រឹក្សាឃុំ/សង្កាត់ បុគ្គលិកមណ្ឌលសុខភាព និងគ្រូបង្រៀនសាលាបឋមសិក្សា។ ចំណែកឯ អ្នកប្រើប្រាស់វិញ គឺប្រជាជនធម្មតា។ អ្នកប្រើប្រាស់សេវាសាធារណៈ និងគ្រូបង្រៀនបានតម្រូវឱ្យចូលរួមក្នុងក្រុមពិភាក្សា និងបំពេញនូវកម្រងសំណួរ នៅពេលដែលក្រុមប្រឹក្សាឃុំ/សង្កាត់បានតម្រូវឱ្យត្រឹមតែចូលរួមក្នុងកិច្ចពិភាក្សាប៉ុណ្ណោះ ដោយមិនចាំបាច់បំពេញនូវកម្រងសំណួរឡើយ។ រីឯបុគ្គលិកមណ្ឌលសុខភាពវិញត្រូវបានសម្ភាសដាច់ដោយឡែកពីគ្នា។ បន្ថែមពីលើអ្នកផ្តល់សេវាទាំងពីក្រុមអ្នកផ្តល់ព័ត៌មានផ្សេងៗទៀតក៏ត្រូវបានធ្វើការសម្ភាសផងដែរ ដូចជា អភិបាលស្រុក នាយក/នាយិការសាលាបឋមសិក្សា និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត។

### ១.២.១ អ្នកប្រើប្រាស់សេវាៈ ការពិភាក្សាជាក្រុម និងកម្រងសំណួរ

មុនពេលចុះសម្ភាសន៍ ក្រុមចុះទៅរៀបចំទុកជាមុនរបស់ វ.ស.ក. បានដើរតួយ៉ាងសំខាន់ក្នុងការស្វែងរកអ្នកស្រុកដែលរស់នៅក្នុងឃុំ/សង្កាត់ដែលជាគោលដៅក្នុងការចុះទៅ ក្នុងគោលបំណងឱ្យពួកគាត់ជ្រើសរើសអ្នកចូលរួមសម្រាប់កិច្ចពិភាក្សាជាក្រុម ក្រោមលក្ខណៈវិនិច្ឆ័យយ៉ាងហ្មត់ចត់ដែលកំណត់ដោយក្រុមអ្នកស្រាវជ្រាវរបស់ វ.ស.ក.។ ប្រជាជនម្នាក់ៗត្រូវបានជ្រើសរើសពីភូមិផ្សេងៗគ្នា មានឋានៈសង្គម-សេដ្ឋកិច្ចខុសៗគ្នា ហើយតុល្យភាពរវាងបុរស និងស្ត្រី ក៏ជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់សមាសភាពកិច្ចពិភាក្សាជាក្រុមដែរ។ម្យ៉ាងទៀត អ្នកចូលរួមទាំងអស់ត្រូវបានគេរំពឹងថា មានការយល់ដឹង និងបទពិសោធន៍ផ្សេងៗពីគ្នា ចំពោះសេវាសាធារណៈដែលជាគោលដៅនៃការសិក្សាទាំង ៣។ លើសពីនេះទៅទៀត អ្នកចូលរួមទាំងអស់ក៏ត្រូវបានរំពឹងថា មានអាយុលើសពី ២៥ ឆ្នាំផងដែរ។

**តារាង ១.២: ចំនួនគំរូតាមប្រភេទឃុំ**

| ភេទ | អ្នកប្រើប្រាស់សេវា | ភាគរយ | គ្រូបង្រៀន | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|
| បុរស | ៣៨៣ | ៤៥% | ១៥៨ | ៤៧% | ៥៤១ | ៤៥% |
| ស្ត្រី | ៤៧៦ | ៥៥% | ១៧៩ | ៥៣% | ៦៥៥ | ៥៥% |
| សរុប | ៨៥៩ | ១០០% | ៣៣៧ | ១០០% | ១១៩៦ | ១០០% |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ២០០៦*

### ១.២.២. គ្រូបង្រៀនបឋមសិក្សាៈ ការពិភាក្សាជាក្រុម និងកម្រងសំណួរ

ការជ្រើសរើសគ្រូបង្រៀនបឋមសិក្សា បុគ្គលិកមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវបានកំណត់តាមពេលវេលាទំនេររបស់ពួកគាត់។ ដើម្បីជៀសវាងស្ថានភាពខ្លាចមិនហ៊ានបញ្ចេញយោបល់ពីសំណាក់លោកគ្រូ

អ្នកគ្រូ នាយក/នាយិកា និងនាយករង/នាយិការងនៃបឋមសិក្សាមិនត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចពិភាក្សាឡើយ។ តារាង ១.២ និង ១.៣ បានបង្ហាញពីការផ្សំផ្គុំឡើងនៅប៉ាន់គំរូទាំងអស់នៃការសិក្សានេះ ដែលមានជាកិច្ចពិភាក្សា និងការបំពេញកម្រងសំណួរ។

## តារាង ១.៣.: ប៉ាន់គំរូតាមប្រភេទឃុំ/សង្កាត់

| ប្រភេទឃុំ/សង្កាត់ | ប្រជាជន | | គ្រូបឋមសិក្សា | |
|---|---|---|---|---|
| | ប៉ាន់គំរូ | ភាគរយ | ប៉ាន់គំរូ | ភាគរយ |
| ឃុំដែលមានទីតាំងនៅទីប្រជុំជនខេត្ត | ២៧០ | ៣.១៤% | ១១៦ | ៣៤.៤% |
| ឃុំដែលមានទីតាំងនៅទីប្រជុំជនស្រុក | ១៩០ | ២២.១% | ៨២ | ២៤.៣% |
| ឃុំដាច់ស្រយាល | ៣៩៩ | ៤៦.១% | ១៣៩ | ៤១.៣% |
| **សរុប** | ៨៥៩ | ១០០% | ៣៣៧ | ១០០ |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ២០០៦*

នៅក្នុងតារាង ១.៣ យើងឃើញថា ប៉ាន់គំរូសម្រាប់ឃុំនៅទីរួមខេត្តមានចំនួនច្រើនជាងប៉ាន់គំរូសម្រាប់ឃុំនៅតាមទីរួមស្រុក។ ចំពោះចំណុចនេះ គឺបណ្តាលមកពីការសម្រេចចាត់ទុកឃុំ ៤ នៅទីក្រុងភ្នំពេញចូលទៅក្នុងឃុំនៅទីរួមខេត្តដោយសារតែកម្រិតជីវភាពរបស់ប្រជាជនមានលក្ខណៈប្រហាក់ប្រហែលគ្នា និងដោយសារតែឃុំចំនួន ២ ទៀតដែលកំពុងធ្វើការសាកល្បង "ច្រកចេញចូលតែមួយ" ត្រូវបានជ្រើសរើសធ្វើការសិក្សាផងដែរ។

### ១.២.៣. ក្រុមប្រឹក្សាឃុំ

ជាទូទៅ ក្រុមប្រឹក្សាឃុំនីមួយៗ មានសមាជិក/សមាជិកាពី ៥ ឬ ៧ ឬ ៩ ឬក៏ ១១ នាក់ អាស្រ័យទៅលើចំនួនប្រជាជន។ ក្នុងការសិក្សានេះ យ៉ាងតិចបំផុតក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ៥ ត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចពិភាក្សាជាក្រុមក្នុងគោលបំណងដើម្បីទទួលបាននូវមតិ ការបារម្ភ និងបញ្ហានានាពីថ្នាក់ដឹកនាំឃុំ/សង្កាត់។ ជាសរុបមកសមាជិក/សមាជិកាក្រុមប្រឹក្សាឃុំ/សង្កាត់ប្រមាណ ៣០០ នាក់ បានចូលរួមក្នុងកិច្ចពិភាក្សាជាក្រុម។

### ១.២.៤. អ្នកផ្តល់ព័ត៌មានផ្សេងៗទៀត: ការសម្ភាសដោយផ្ទាល់

ក្នុងខេត្តនីមួយៗ អ្នកដឹងឮសំខាន់ៗប្រហែល ២០ នាក់ ត្រូវបានសម្ភាសបែបគុណវិស័យ រួមមាន: ថ្នាក់ដឹកនាំសាលាបឋម ៨ នាក់ (នាយកសាលា/នាយិកា ៤ នាក់ និងនាយករង/នាយិការង ៤ នាក់) បុគ្គលិកមណ្ឌលសុខភាព ៨ នាក់ និងមន្ត្រីការិយាល័យស្រុក ៤ នាក់ (អភិបាលស្រុក ២ នាក់ និងអភិបាលរងស្រុក ២ នាក់)។ សរុបមក អ្នកដឹងឮប្រហែល ២៤០ នាក់ ត្រូវបានជ្រើសរើសសម្រាប់កិច្ចសម្ភាសន៍បែបគុណវិស័យក្នុងការសិក្សានេះ។

## ១.៣ វិធីសាស្ត្រក្នុងការសិក្សា

បើពិចារណាពីលក្ខណៈផ្សេងៗគ្នានៃសេវាទាំង ៣ ដែលបានជ្រើសរើសយកមកសិក្សា កិច្ចពិភាក្សាជាក្រុម ត្រូវបានប្រើជាវិធីសាស្ត្រមួយក្នុងការស្ទាបស្ទង់មតិសម្រាប់កិច្ចសម្ភាសន៍ដោយសារមូលហេតុ ២។ មូលហេតុទី ១ គឺ សមាសភាពផ្សេងៗគ្នានៃកិច្ចពិភាក្សាជាក្រុម អាចជៀសវាងលទ្ធភាពដែលថាអ្នកត្រូវបានសម្ភាសខ្លះមានកង្វះខាត ការយល់ដឹងអំពីសេវាទាំង ៣ នេះ។ ម្យ៉ាងទៀត វិធីសាស្ត្រស្រាវជ្រាវនេះ បានជួយពង្រឹងចម្លើយនានាដែល បានពីកម្រងសំណួរនៃការស្ទង់មតិ ហើយព្រមទាំងធ្វើឱ្យចម្លើយមានលក្ខណៈទូទៅសម្រាប់ទាំងអស់គ្នា។ ក្នុងន័យនេះ កិច្ចពិភាក្សា ៤ ក្រុម ត្រូវបានធ្វើឡើងក្នុងឃុំ/សង្កាត់នីមួយៗ: ២ ក្រុមជាមួយប្រជាជន ហើយ ១ ក្រុមជាមួយ អាជ្ញាធរមូលដ្ឋាន និង ១ ក្រុមទៀតជាមួយគ្រូបឋមសិក្សា។

កិច្ចពិភាក្សានីមួយៗជាមួយអ្នកប្រើប្រាស់សេវា ជាទូទៅ មានប្រជាជនប្រមាណពី ៨ ទៅ ៩ នាក់ ចូលរួម។ ចំណែកឯកិច្ចពិភាក្សាជាមួយគ្រូបឋមសិក្សាវិញ មានចំនួនអ្នកចូលរួមប្រមាណ ៦ ទៅ ៧ នាក់។ បន្ទាប់ពីកិច្ចពិភាក្សារួច អ្នកចូលរួមទាំងអស់បានតម្រូវឱ្យបំពេញនូវកម្រងសំណួរដែលរៀបចំដោយក្រុមអ្នកសម្ភាសន៍ របស់ វ.ស.ក.។ កម្រងសំណួរទាំងនោះ ត្រូវបានផ្តល់ទៅឱ្យអ្នកចូលរួមក្នុងគោលបំណងផ្តល់ជាឱកាសមួយដើម្បីឱ្យ ពួកគាត់បញ្ចេញនូវគំនិតយោបល់មួយចំនួន ដែលពួកគាត់មិនហ៊ានបញ្ចេញជាសាធារណៈ។ អ្នកចូលរួមទាំងអស់ តម្រូវឱ្យបំពេញកម្រងសំណួររៀងៗខ្លួន បើសិនជាគាត់អាចបំពេញបាន។ ក្រុមអ្នកស្រាវជ្រាវរបស់ វ.ស.ក. នឹងជួយ សម្រួល បើគាត់មិនអាចបំពេញបាន។

ការសម្ភាសម្នាក់ៗជាមួយអ្នកផ្តល់ព័ត៌មានផ្សេងៗទៀត ក៏ត្រូវបានចាត់ទុកថាមានសារៈសំខាន់ណាស់ដែរ ពីព្រោះយើងសង្ឃឹមថា គាត់នឹងអាចផ្តល់នូវអនុសាសន៍ និងសំណើរដ៏មានតម្លៃមួយចំនួនក្នុងការកែលំអរគុណភាព របស់សេវាសាធារណៈទាំងបីនោះ។

## ១.៤. កម្រងសំណួរ

កម្រងសំណួរនៃកិច្ចពិភាក្សាជាក្រុម ត្រូវបានតាក់តែងឡើងសម្រាប់ក្រុមអ្នកចូលរួមទាំងបីខាងលើ។ កម្រងសំណួរសម្រាប់កិច្ចពិភាក្សាមានបីផ្នែកសំខាន់ៗគឺ: សេវាឃុំ/សង្កាត់ សេវាសាលាបឋមសិក្សា និងសេវា មណ្ឌលសុខភាព។ កិច្ចពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់បានសង្កត់ធ្ងន់ទៅលើសេវាឃុំ/សង្កាត់ ដោយរួម បញ្ចូលកម្រៃក្រៅផ្លូវការ និងភាពញឹកញាប់នៃការប្រើប្រាស់សេវា ក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន បន្ទាប់ពីមានការ បោះឆ្នោតឃុំ/សង្កាត់ក្នុងឆ្នាំ ២០០២ មក។ កម្រងសំណួរសម្រាប់ធ្វើការអង្កេតចំពោះអ្នកប្រើប្រាស់ និងគ្រូសាលា បឋមសិក្សា ក៏ដូចជាចំពោះអ្នកផ្តល់ព័ត៌មានផ្សេងៗទៀត និងបង្ហាញនៅក្នុងសេចក្តីបន្ថែម ៣។

## ១.៥. ការគ្រប់គ្រងគុណភាព

### ១.៥.១. ការបណ្ដុះបណ្ដាលពីកម្រងសំណួរ

មុននឹងធ្វើការសិក្សាសាកល្បងការចុះស្ទង់មតិ ការបណ្ដុះបណ្ដាលមួយមានរយៈពេល ១ សប្ដាហ៍ ត្រូវបានរៀបចំឡើងសម្រាប់ក្រុមអ្នកចុះសាកសួរ។ គោលបំណងនៃការបណ្ដុះបណ្ដាលនេះ ដំបូងគឺដើម្បីផ្ដល់នូវការយល់ដឹងឱ្យមានលក្ខណៈស៊ីជម្រៅពីទម្រង់ និងអត្ថន័យនៃកម្រងសំណួរ ព្រមទាំងជួយសម្រួលដល់ក្រុមអ្នកស្រាវជ្រាវរបស់ វ.ស.ក.។ គោលដៅទី ២ នៃការបណ្ដុះបណ្ដាលនេះ គឺបង្កើននូវជំនាញទំនាក់ទំនងរបស់សមាជិក/សមាជិកាក្រុមស្រាវជ្រាវនីមួយៗ ជាពិសេសក្រុមចុះទៅរៀបចំទុកជាមុន ក្នុងគោលបំណងបង្កើតនូវទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធនានា និងសម្របសម្រួលដំណើរការប្រមូលទិន្នន័យ។ គោលដៅចុងក្រោយ គឺធានាឱ្យបានគុណភាពនៃទិន្នន័យដែលប្រមូលបាន ដោយផ្ដល់បច្ចេកទេសមួយចំនួនដល់ក្រុមអ្នកធ្វើសម្ភាសន៍របស់ វ.ស.ក. សម្រាប់ដោះស្រាយជាមួយអ្នកចូលរួមដែលមានការលំបាកក្នុងការបញ្ចេញយោបល់។

### ១.៥.២. ការសិក្សាសាកល្បង

ឃុំ/សង្កាត់ ៤ នៅភ្នំពេញ និងខេត្តកណ្ដាលត្រូវបានជ្រើសរើសដើម្បីធ្វើការសិក្សាសាកល្បង។ គោលបំណងនៃការសិក្សាសាកល្បងនេះគឺ:

- ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃកម្រងសំណួរសម្រាប់ការស្ទង់មតិ។
- ពិនិត្យមើលការយល់ដឹងរបស់អ្នកចូលរួមទៅលើសំណួរនីមួយៗ និងទៅលើការណែនាំរបស់អ្នកធ្វើកិច្ចសម្ភាសន៍។
- សាកល្បងប្រសិទ្ធភាពនៃបច្ចេកទេសសម្រាប់ដោះស្រាយជាមួយអ្នកចូលរួមដែលមានការលំបាកក្នុងការបញ្ចេញយោបល់ចំពោះនឹងសំណួរសំខាន់ៗមួយចំនួន។
- កំណត់រយៈពេលចាំបាច់សម្រាប់កិច្ចសម្ភាសន៍ និងការលំបាករបស់អ្នកសម្ភាសន៍ ក៏ដូចជាអ្នកឆ្លើយតប។

បន្ទាប់ពីការសិក្សាសាកល្បងរួចមក កិច្ចប្រជុំផ្ទៃក្នុងមួយត្រូវបានរៀបចំឡើងដើម្បីពិភាក្សាពីលទ្ធផលនៃការសិក្សាសាកល្បងនេះ និងរៀបចំកែប្រែរចនាសម្ព័ន្ធនៃកម្រងសំណួរស្ទង់មតិផ្អែកលើមេរៀនដែលបានពីការសិក្សាសាកល្បងនេះ។

### ១.៥.៣. កម្រងសំណួរសម្រាប់ជ្រើសរើសអ្នកចូលរួម

កម្រងសំណួរសម្រាប់ជ្រើសរើសអ្នកចូលរួម ត្រូវបានប្រើសម្រាប់ក្រុមអ្នកឆ្លើយតប ២ ក្រុមគឺ: ប្រជាជន និងគ្រូបឋមសិក្សា។ គោលដៅនៃកម្រងសំណួរនេះ គឺដើម្បីកាត់បន្ថយចំនួនអ្នកឆ្លើយតបដែលមានការលំបាក

ជាពិសេសអ្នកដែលគ្មានការយល់ដឹងអំពីសេវាកម្មទាំង ៣ ដោយជ្រើសរើសអ្នកឆ្លើយតបនីមួយៗតាមរយៈលក្ខណៈវិនិច្ឆ័យកំណត់ដោយក្រុមអ្នកស្រាវជ្រាវរបស់ វ.ស.ក.។ វិធីសាស្ត្រនៃការជ្រើសរើសនេះ ត្រូវបានប្រើ ២ ដំណាក់កាលៈ

ដំណាក់កាលទី ១ ក្រុមអ្នកចុះទៅរៀបចំទុកជាមុនបានជ្រើសរើសអ្នកស្រុកមួយចំនួនសម្រាប់ជ្រើសរើសអ្នកចូលរួម និងពន្យល់ពួកគាត់ពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកចូលរួម។ អ្នកចូលរួមដែលត្រូវបានជ្រើសរើសត្រូវបំពេញកម្រងសំណួរនៃការជ្រើសរើសជាកំហិត។ ដំណាក់កាលទី ២ កម្រងសំណួរនេះ ត្រូវប្រមូលដោយក្រុមអ្នកចុះទៅរៀបចំទុកជាមុន និងអ្នកចូលរួមត្រូវឆ្លងកាត់ការជ្រើសរើសម្តងទៀតដោយក្រុមអ្នកសម្ភាសន៍។

## ១.៥. ការបញ្ចូលទិន្នន័យ និងការសម្រិតសម្រាំង

គំរូសម្រាប់បញ្ចូលទិន្នន័យត្រូវបានរៀបចំដោយ ក្រុមស្រាវជ្រាវរបស់ វ.ស.ក.(អ្នកស្រាវជ្រាវ និង ជំនួយការអ្នកស្រាជ្រាវ) សម្រាប់អ្នកឯកទេសបញ្ចូលទិន្នន័យសំខាន់ៗ។ ការសម្រិតសម្រាំងទិន្នន័យមាន ៤ ដំណាក់កាល។ ទី ១ នៅកំឡុងពេលចុះធ្វើអង្កេត ប្រធានក្រុម និងអ្នកគ្រប់គ្រងត្រួតពិនិត្យបានផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងភាពខ្ជាប់ខ្ជួននៃកម្រងសំណួរ។ ពេលដែលកម្រងសំណួរមិនបានបំពេញចប់ ឬមិនខ្ជាប់ខ្ជួន ក្រុមអ្នកស្រាវជ្រាវ វ.ស.ក. បានពន្យល់សំណួរ និងស្នើសុំឱ្យអ្នកចូលរួមបំពេញម្តងទៀត។

ទី ២ កំឡុងពេលបញ្ចូលទិន្នន័យ ជំនួយការស្រាវជ្រាវពិនិត្យមើលម្តងទៀតលើភាពត្រឹមត្រូវ និងភាពខ្ជាប់ខ្ជួនរបស់សំណួរនីមួយៗ។ ទី ៣ អ្នកស្រាវជ្រាវធ្វើការសម្រិតសម្រាំងទិន្នន័យ ហើយទិន្នន័យណាដែលមានលក្ខណៈមិនសមស្របត្រូវបានលុបចោល តាមរយៈវិធីសាស្ត្រដែលមានលក្ខណៈវិទ្យាសាស្ត្រ។ ទី ៤ ជំនួយការអ្នកស្រាវជ្រាវចុះសិក្សាម្តងទៀតដើម្បីផ្ទៀងផ្ទាត់ពីទិន្នន័យ ដែលមិនខ្ជាប់ខ្ជួន ពាក់ព័ន្ធនឹងចំនួនដងនៃភាពញឹកញាប់របស់សេវាដែលផ្តល់ដោយមន្ត្រីឃុំ/សង្កាត់ និងបុគ្គលិកមណ្ឌលសុខភាព។

# សេចក្តីបន្ថែម ២

# ការប៉ាន់ស្មានបរិមាណសរុប ប្រចាំឆ្នាំនៃកម្រៃក្រៅផ្លូវការ

# ការប៉ាន់ស្មានបរិមាណសរុបប្រចាំឆ្នាំនៃកម្រៃក្រៅផ្លូវការ

## ២.១. កម្រៃក្រៅផ្លូវការសម្រាប់សេវាសាធារណៈ

ការប៉ាន់ស្មានចំណាយក្រៅផ្លូវការសម្រាប់សេវាសាធារណៈនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវបានគណនាដោយផ្អែកតាមរូបមន្តដូចខាងក្រោម។ ក្នុងករណីនេះ រង្វាន់ ឬក៏អំណោយ ដែលត្រូវបានផ្តល់ទៅឱ្យអ្នកផ្តល់សេវា ដើម្បីទទួលបាននូវសេវាសាធារណៈ ក៏ត្រូវបានចាត់ទុកថាជាចំណាយក្រៅផ្លូវការដែរ។

$$TUF = \alpha * \beta$$

- $TUF$ = ចំណាយក្រៅផ្លូវការសរុប
- $\alpha$ = ចំណាយក្រៅផ្លូវការជាមធ្យមប្រចាំឆ្នាំដែលត្រូវបានបង់ទៅលើសេវាឃុំ/សង្កាត់ដោយគ្រួសារនីមួយៗ
  (**ប្រភព:** *វិទ្យាស្ថានអភិវឌ្ឍន៍សង្គម - ការរស់នៅក្រោមច្បាប់នៃអំពើពុករលួយ ២០០៥*)
- $\beta$ = ចំនួនគ្រួសារសរុប (**ប្រភព:** *វិទ្យាស្ថានជាតិស្ថិតិ*)

**តារាងទី ២.១: ចំណាយផ្លូវការ និងក្រៅផ្លូវការដែលបង់ជាប្រចាំឆ្នាំដោយអ្នកប្រើប្រាស់សេវា**

| សេវាសាធារណៈ | ចំណាយផ្លូវការ (ដុល្លារ) | ចំណាយក្រៅផ្លូវការ (ដុល្លារ) | រង្វាន់ (ដុល្លារ) | ចំណាយក្រៅផ្លូវការសរុប (លាន ដុល្លារ) | ភាគរយសរុប |
|---|---|---|---|---|---|
| វិស័យអប់រំសាធារណៈ | ៧៣,៥ | ១៣ | ១ | ៣៦,៨ | ៥៦,០% |
| តុលាការ | ៣,៥ | ៣,៥ | - | ៩,២ | ១៤,០% |
| ប៉ូលីសចរាចរ | ០,៥ | ២,៥ | - | ៦,៦ | ១០,០% |
| ប៉ូលីស(លើកលែងប៉ូលីសចរាចរ) | ០,៥ | ២,៥ | - | ៦,៦ | ១០,០% |
| គយ | ០,៥ | ១,០ | - | ២,៦ | ៤,០% |
| សេវាសុខភាពសាធារណៈ | ៨,០ | ០,៥ | - | ១,៣ | ២,០% |
| ការចុះបញ្ជីអត្រានុកូលដ្ឋាន | ២,០ | ០,៥ | - | ១,៣ | ២,០% |
| ភូមិបាល | ១,០ | ០,៥ | - | ១,៣ | ២,០% |
| ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម | ១,០ | - | - | - | - |
| លិខិតអនុញ្ញាតសាងសង់ | ០,៥ | - | - | - | - |
| សេវាអគ្គិសនីសាធារណៈ | ២៥,០ | - | - | - | - |
| ទឹក | ១៤,៥ | - | - | - | - |
| **សរុប** | ១៣០,៥ | ២៤ | ១ | ៦៥,៦ | ១០០,០% |

**ប្រភព:** *វិទ្យាស្ថានអភិវឌ្ឍន៍សង្គម និង វិទ្យាស្ថានជាតិស្ថិតិ*

## ២.២ តម្លៃក្រៅផ្លូវការសម្រាប់សេវាឃុំ/សង្កាត់

### ២.២.១ តម្លៃក្រៅផ្លូវការតាមប្រភេទនីមួយៗនៃឃុំ/សង្កាត់

ក្នុងការសិក្សានេះ ចំណាយក្រៅផ្លូវការជាមធ្យមដែលត្រូវបានបង់ដោយគ្រួសារនៅក្នុងប្រភេទឃុំ/សង្កាត់ នីមួយៗ គឺត្រូវបានគណនាដោយបែងចែកដាច់ពីគ្នា សម្រាប់ទីក្រុងភ្នំពេញ ខេត្ត ស្រុក និងជនបទ។ ចំពោះប្រភេទនីមួយៗនៃឃុំ/សង្កាត់ តម្លៃផ្លូវការសម្រាប់សេវាមួយចំនួន និងភាពញឹកញាប់នៃកាប្រើប្រាស់ប្រចាំឆ្នាំនៃសេវាដែលផ្ដល់ទាំងអស់ត្រូវបានរកឃើញតាមរយៈការពិភាក្សាជាក្រុមជាមួយនឹងក្រុមប្រឹក្សាឃុំ/សង្កាត់។ រីឯ ចំណាយជាក់ស្តែងជាមធ្យមសម្រាប់សេវាទាំងអស់ត្រូវបានកំណត់នៅក្នុងការពិភាក្សាជាក្រុមជាមួយអ្នកប្រើប្រាស់សេវា។ ហើយចំពោះសេវាដែលមានតម្លៃផ្លូវការ ថ្លៃផ្លូវការនោះត្រូវបានដកចេញពីចំណាយជាក់ស្តែងដើម្បីទាញរកមធ្យមនៃចំណាយក្រៅផ្លូវការ។ ចំណាយក្រៅផ្លូវការសរុបនៅតាមឃុំ/សង្កាត់នីមួយៗត្រូវបានប៉ាន់ស្មាន ដូចខាងក្រោម:

$$TUFC = \sum_{i=1}^{n} \alpha_i * \beta_i$$

- $TUFC =$ ចំណាយក្រៅផ្លូវការសរុបប៉ាន់ស្មានសម្រាប់សេវាឃុំ/សង្កាត់តាមប្រភេទនីមួយៗ។
- $\alpha_i =$ មធ្យមនៃចំណាយក្រៅផ្លូវការតាមសេវានីមួយៗរបស់ឃុំ/សង្កាត់។

  (**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ឆ្នាំ ២០០៦*)។
- $\beta_i =$ ភាពញឹកញាប់ប្រចាំឆ្នាំនៃការប្រើប្រាស់សេវានីមួយៗ។

  (**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ឆ្នាំ ២០០៦*)។

តាមរូបមន្តនេះ ចំណាយក្រៅផ្លូវការត្រូវបានប៉ាន់ស្មានសរុបប្រចាំឆ្នាំមានប្រហែលជា ៨ 000 ដុល្លារ នៅសង្កាត់នាទីក្រុងភ្នំពេញ ៥ ៥00 ដុល្លារ នៅឃុំទីរួមខេត្ត ហើយ ៣ ១00 ដុល្លារ នៅឃុំទីរួមស្រុក និង ១ ៧00 ដុល្លារ នៅឃុំជនបទ។

ដើម្បីផ្ដល់នូវទស្សនៈរួមមួយទៅលើចំណាយក្រៅផ្លូវការចំពោះសេវាឃុំ/សង្កាត់ ចំណាយក្រៅផ្លូវការសរុបប្រចាំឆ្នាំសម្រាប់សេវាឃុំ/សង្កាត់ទូទាំងប្រទេសត្រូវបានប៉ាន់ស្មានតាមរយៈរូបមន្តដូចខាងក្រោម:

$$TUFNW = \alpha_1 * \beta_1$$

- $TUFNW =$ ចំណាយក្រៅផ្លូវការសរុបទូទាំងប្រទេស

- $\alpha_1 =$ ចំណាយក្រៅផ្លូវការជាមធ្យមប្រចាំឆ្នាំដែលគ្រួសារបានបង់ដើម្បីទទួលបានសេវាសាធារណៈតាមឃុំ/សង្កាត់នីមួយៗ។ (**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ឆ្នាំ ២០០៦*)
- $\beta_1 =$ចំនួនឃុំសរុប ។ (**ប្រភព:** *កម្មវិធីសីលា*)

តាមរូបមន្តខាងលើ ចំណាយក្រៅផ្លូវការសរុបសម្រាប់សេវាឃុំ/សង្កាត់ទូទាំងប្រទេសត្រូវបានប៉ាន់ស្មានប្រហែលជា ៥,៦ លានដុល្លារក្នុង ១ ឆ្នាំ។ ការគណនានេះ គឺមិនរាប់បញ្ចូលចំណាយក្រៅផ្លូវការទៅលើការធ្វើពាណិជ្ជកម្មដីធ្លីនៅថ្នាក់ឃុំ/សង្កាត់ឡើយ ។

## ២.៣ កម្រៃក្រៅផ្លូវការនៅសាលាបឋមសិក្សា

### ២.៣.១ កម្រៃក្រៅផ្លូវការ (ករណីសិក្សានៅទីក្រុងភ្នំពេញ)

ដើម្បីប៉ាន់ស្មានការចូលរួមចំណែក នៃចំណាយក្រៅផ្លូវការនៅក្នុងប្រាក់ខែរបស់គ្រូបង្រៀនថ្នាក់បឋមសិក្សានៅភ្នំពេញ យើងផ្អែកទៅលើលទ្ធផលនៃតារាងទី ២.២។ សម្មតិកម្មខាងក្រោមត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យមានភាពងាយស្រួលដល់ការវិភាគៈ

**សម្មតិកម្មៈ** "គ្រូបង្រៀនគ្រប់រូបតម្រូវឱ្យសិស្សបង់ប្រាក់ក្រៅផ្លូវការទាំងបីប្រភេទ ដូចបានបង្ហាញនៅក្នុងតារាងទី ២.២ ខាងក្រោម ហើយសិស្សទាំងអស់ក៏ព្រមបង់តាមប្រភេទនៃការចំណាយទាំងនោះ។"

**តារាងទី ២.២: ចំណាយក្រៅផ្លូវការប៉ាន់ស្មានប្រចាំឆ្នាំនៅទីក្រុងភ្នំពេញ (គិតជារៀល)**

| | |
|---|---|
| ចំណាយទៅលើការចុះឈ្មោះចូលរៀន | ១២០០ |
| ចំណាយទៅលើថ្លៃទឹក និង អគ្គិសនី | ២០០០ |
| ចំណាយដែលគ្រូតម្រូវឱ្យបង់ | ៥០៨០០ |
| **សរុប** | **៥៤០០០** |

**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ឆ្នាំ ២០០៦*

ចំណាយក្រៅផ្លូវការសរុបក្នុងករណីនេះត្រូវបានគណនាដូចខាងក្រោមៈ

$$TUFPE = \alpha_2 * \beta_2$$

- $TUFPE =$ ចំណាយក្រៅផ្លូវការសរុបនៅសាលាបឋមសិក្សា (ករណីសិក្សានៅភ្នំពេញ)
- $\alpha_2 =$ ចំណាយក្រៅផ្លូវការជាមធ្យមប្រចាំឆ្នាំ ដែលគ្រួសារបានបង់ទៅលើសេវាសាលាបឋមសិក្សានៅភ្នំពេញ (**ប្រភព:** *ការស្ទង់មតិរបស់ វ.ស.ក. កក្កដា - សីហា ឆ្នាំ ២០០៦*)

- $\beta_2$ = ចំនួនសិស្សសាលាបឋមសិក្សាសរុបនៅក្នុងទីក្រុងភ្នំពេញ (ប្រភព: *ក្រសួងអប់រំ យុវជន និងកីឡា*)

តាមរយៈរូបមន្ត និងសម្មតិកម្មនេះបានបង្ហាញថាចំណាយក្រៅផ្លូវការសរុបចំពោះសេវាសាលាបឋមសិក្សាមានប្រមាណប្រហែលជា ២ លានដុល្លារ ឬក៏អាចនិយាយបានថា ប្រាក់ដែលគ្រូម្នាក់ៗទទួលបានជាប្រចាំខែប្រហែល ៤៦ដុល្លារ។

## ២.៣.២ ចំណូលពីការបង្រៀនបន្ថែមម៉ោងរបស់គ្រូសាលាបឋមសិក្សា

